ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- មន្ត្រីមណ្ឌលឯកសារកម្ពុជាផ្សព្វផ្សាយអំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ
- ដំណើរទស្សនកិច្ចដើម្បីការផ្សះផ្សា

លេខ ៧១ ខែវិច្ឆិកា ឆ្នាំ២០០៥

# ស្វែងរកការពិត

លេខ៧១ ខែវិច្ឆិកា ឆ្នាំ២០០៥

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រៈ មជ្ឈមណ្ឌលឯកសារកម្ពុជាស្វាគមន៍..............................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ ចិន សួន ហៅ សាន..............................២

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១.................. ៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ.............................................. ៦

◆ រណ្តៅសាកសពនៅក្នុងព្រៃឈើទាង......................................២០

◆ រំឭករឿងរ៉ាវដើម្បីថែរក្សាប្រវត្តិសាស្ត្រ.................................២២

**ផ្នែកច្បាប់**

◆ ពាក្យសុំរបស់មេធាវីចុងចោទ......................................... ២៥

**វេទិកាពិភាក្សាសាធារណៈ**

◆ សេចក្តីថ្លែងការណ៍រួមរវាងឯកឧត្តម......................................២៨

◆ កិច្ចការមួយដែលរួមចំណែក........................................... ៣០

◆ តើអង្គជំនុំជម្រះវិសាមញ្ញបម្រើប្រជាជនបានល្អដែរឬទេ? ...... ៣១

◆ ហេតុអ្វីយើងប្រើពាក្យ “Tribunal”................................ ៣៤

◆ ការវិវត្តថ្មីនៃដំណើរការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ..................៣៦

◆ តើអ្នកដែលមានការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ............................៣៧

◆ ដំណើរទស្សនកិច្ចដើម្បីការផ្សះផ្សា....................................៣៩

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ ខ្ញុំខ្លាចខ្មែរក្រហម........................................................ ៤៨

◆ រូបពីស្លាប់................................................................ ៤៩

◆ធ្វើអ្វីគ្រប់យ៉ាងឲ្យតែបានរស់............................................ ៥២



ហ៊ឹម ហ៊ុយ អតីតសន្តិសុខនៅមន្ទីរសន្តិសុខ ស-២១ (គុកទួលស្លែង) ក្នុងដំណើរទស្សនកិច្ចសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៥

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិបានសម្រេចយកបញ្ជាការដ្ឋានកងទ័ពជើងគោកដែលទើបនឹងសាងសង់ថ្មីនៅឯជាយក្រុងភ្នំពេញធ្វើជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ



## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** វ៉ាន់ថាន់ ពៅដារ៉ា, ឃិន នាន, ញាណ សុជាតិ, គង់ សុកគៀន, ដេង ពង្សរ៉ាស៊ី, ប៉ាង ពីរីន, ស៊ិរ សារីណា, ស៊ឹម សុទ្ធ, មាស ផល្លី, អៀប ឌុច, នូសារ៉ា ថៃថារ៉ាត់, ចន ឆរធីអារី, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ស៊ិរ សារីណា **អ្នកបកប្រែៈ** ដី ទេរិទ្ធិ, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** រ័ត្ន តារាពិដៅ

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# មជ្ឈមណ្ឌលឯកសារកម្ពុជាស្វាគមន៍បុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញ

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមសម្តែងនូវការដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដែលបានធ្វើឲ្យចេញជារូបរាងពិតប្រាកដនូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារការរៀបចំរដ្ឋបាលចុងក្រោយរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងចាប់ផ្តើមឡើងនៅក្នុងខែមករាខាងមុខ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការព្រួយបារម្ភចំនួនបី ។

ទីមួយៈ ខ្ញុំសូមជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិចាត់វិធានការនានាដើម្បីធានាថាប្រជាជនកម្ពុជានឹងទទួលបានព័ត៌មានពេញលេញនូវគ្រប់ផ្នែកទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញ ។ កាលពីឆ្នាំមុន រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើកិច្ចការដ៏ល្អមួយគឺបានបោះពុម្ពផ្សាយកូនសៀវភៅមួយណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ ប្រជាជនកម្ពុជាដែលរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យបានទន្ទឹងរង់ចាំមើលការស្វែងរកយុត្តិធម៌អស់រយៈពេលជាង ២៥ឆ្នាំមកហើយ ។ ដូច្នេះទាំងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិគួរតែផ្សព្វផ្សាយដំណើរការជំនុំជម្រះក្តីនេះតាមវិទ្យុ ទូរទស្សន៍ ការបោះពុម្ពផ្សាយផ្សេងៗ និងស្វែងរកមធ្យោបាយនានាដើម្បីជួយប្រជាជនកម្ពុជាបានចូលរួមនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញតាមរយៈការចូលរួមស្តាប់សវនាការ កិច្ចប្រជុំសាធារណៈ និងមធ្យោបាយផ្សេងៗទៀត ខ្ញុំក៏សូមជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិជួយគាំទ្រដល់កិច្ចការរបស់អង្គការក្រៅរដ្ឋាភិបាលទាំងក្នុងតំបន់ក៏ដូចជាអន្តរជាតិក្នុងការជំរុញឲ្យមានការបង្កើនការយល់ដឹងនិងការចូលរួមរបស់ប្រជាជននៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ប្រសិនបើគ្មានការចូលរួមរបស់ប្រជាជនកម្ពុជាទេនោះ អង្គជំនុំជម្រះវិសាមញ្ញនឹងបាត់បង់តម្លៃនិងអត្ថន័យរបស់ខ្លួនជាមិនខាន ។



ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិបានសម្រេចយកបញ្ជាការដ្ឋានកងទ័ពជើងគោក ដែលទើបនឹងសាងសង់ថ្មីនៅឯជាយក្រុងភ្នំពេញធ្វើជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ

ទីពីរៈ បើពិនិត្យមើលសារសំខាន់នៃការផ្តល់ព័ត៌មាននិងការអប់រំដល់ប្រជាពលរដ្ឋកម្ពុជាអំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ វាកាន់តែមានសារសំខាន់ទៅទៀតដែលបុគ្គលិកទាំងអស់នៅការិយាល័យកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវតែជាអ្នកដែលអាចនិយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ ស្គាល់វប្បធម៌របស់កម្ពុជា និងជាជនជាតិខ្មែរឬមានបុព្វជនជាជនជាតិខ្មែរ ។

ទីបីៈ តម្លាភាពគួរតែចាប់ផ្តើមជាមួយនឹងការជ្រើសរើសចៅក្រម ប្រធានការិយាល័យនិងផ្នែកផ្សេងៗទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ប្រសិនបើចង់ឲ្យប្រព័ន្ធយុត្តិធម៌របស់កម្ពុជារីកចម្រើននិងទទួលបានទំនុកចិត្តពីសាធារណជន អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវតែបង្ហាញថាបុគ្គលិកទាំងអស់នេះត្រូវបានជ្រើសរើសតាមរបៀបចំហ មិនលម្អៀង និងជាអ្នកដែលមិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ចិន សួន ហៅ សាន បណ្ឌិតខាងគរុកោសល្យមកពីប្រទេសបារាំង

ចិន សួន ឈ្មោះបដិវត្តន៍ សាន កើតនៅស្រុកស្វាយទង កម្ពុជាក្រោម នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩២៨ ។

អាយុ១២ឆ្នាំ សួន ធ្វើដំណើរមកប្រទេសកម្ពុជា ហើយរៀននៅខេត្តកំពតនិងខេត្តកំពង់ស្ពឺ ដោយរស់នៅជាមួយបងជីដូនមួយដែលជាភូឈួយខេត្ត ។ នៅឆ្នាំ១៩៤៤ សួន ទៅស្នាក់នៅវត្តបទុមនៅទីក្រុងភ្នំពេញ និងបន្តការសិក្សានៅសាលាឯកជន ព្រោះប្រឡងធ្លាក់នៅសាលារដ្ឋ ។ ឆ្នាំ១៩៤៥ សួន ប្រឡងជាប់សញ្ញាប័ត្របឋមភូមិហើយបានចូលរៀននៅសាលាគរុវិជ្ជា ។

សួន រៀនចប់សាលាគរុវិជ្ជានៅឆ្នាំ១៩៤៩ និងបានទៅបន្តការសិក្សានៅប្រទេសបារាំង ។ សួន រៀននៅសាលាគរុវិជ្ជាក្នុងទីក្រុងម៉ុងពើលីយេ បន្ទាប់មកបន្តការសិក្សានៅមហាវិទ្យាល័យអក្សរសាស្ត្រក្នុងទីក្រុងដដែល ។ សួន បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៦បន្ទាប់ពីរៀនចប់មហាវិទ្យាល័យអក្សរសាស្ត្រ ហើយត្រូវបានតែងតាំងជាសាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ ។

ចុងឆ្នាំ១៩៥៧ សួន បានទទួលការតែងតាំងជានាយកការិយាល័យទីស្តីការនាយករដ្ឋមន្ត្រី ។ ឆ្នាំ១៩៥៨ សួន បានឈរឈ្មោះជាតំណាងរាស្ត្រនិងបានជាប់ជាសមាជិកសភា ។ ថ្វីដ្បិតតែ សួន ជាប់ឆ្នោតជាសមាជិកសភា ប៉ុន្តែគាត់ពុំបានធ្វើការនៅក្នុងរដ្ឋសភាទេ ព្រោះគាត់ជាសមាជិករដ្ឋាភិបាល និងមានមុខនាទីនៅក្នុងរដ្ឋាភិបាល ។ នៅឆ្នាំ១៩៥៨ សួន ជារដ្ឋលេខាធិការក្រសួងអប់រំជាតិ ។ នៅឆ្នាំ១៩៦០គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងឃោសនាការ ។ ពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៦៤ សួន ក្លាយជារដ្ឋមន្ត្រីក្រសួងកសិកម្ម ។ ឆ្នាំ១៩៦៤ សួន ធ្វើជានាយកការិយាល័យព្រះមហាក្សត្រ ហើយនៅឆ្នាំ១៩៦៧ បានបម្រើការជាទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច ។

ដើមឆ្នាំ១៩៦៨ សួន ចាកចេញទៅរស់នៅជាមួយប្រពន្ធនិងកូននៅប្រទេសបារាំង ។ សួន បានបន្តការសិក្សានៅប្រទេសបារាំង រហូតដល់ចប់ថ្នាក់បណ្ឌិតផ្នែកគរុកោសល្យនៅឆ្នាំ១៩៧០ ។ ក្នុងពេលកំពុងតែរៀនយកសញ្ញាប័ត្រថ្នាក់បណ្ឌិត សួន បានឆ្លៀតបង្រៀននៅមហាវិទ្យាល័យមួយនៅ ពេរពីញ៉ង់ ។

នៅចុងខែមេសា ឆ្នាំ១៩៧០ សួន បានធ្វើដំណើរទៅទីក្រុងប៉េកាំងដើម្បីចូលរួមចំណែកបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ។ បន្ទាប់ពីរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាត្រូវបានប្រកាសបង្កើតឡើងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ សួន ត្រូវបានតែងតាំងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការពិសេស ។ ក្នុងចន្លោះឆ្នាំ១៩៧០និង១៩៧៥ សួន ធ្វើដំណើរទៅមកប៉េកាំង-ប៉ារីសជាញឹកញាប់ ។ ចាប់ពីឆ្នាំ១៩៧៣ សួន បានទទួលតួនាទីថ្មីជាតំណាងរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំនៅអឺរ៉ុប ។

## ការវិលត្រឡប់មករកកម្ពុជាប្រជាធិបតេយ្យ

សួន វិលមកប្រទេសកម្ពុជានៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ តាមសេចក្តីអំពាវនាវរបស់អង្គការដែលសូមឲ្យអ្នកចេះដឹងដែលកំពុងតែរស់នៅក្រៅប្រទេសឲ្យវិលត្រឡប់មកជួយកសាងកម្ពុជាប្រជាធិបតេយ្យ ។ មកជាមួយ សួន មានអតីតបុគ្គលិកទូតមួយចំនួនទៀត ។ អ្នកទាំងអស់គ្នាត្រូវអង្គការបញ្ជូនទៅរៀនសូត្រអំពីមាគ៌ានយោបាយរបស់បក្សអស់រយៈពេលបីខែ ។

នៅដំណាច់ខែកុម្ភៈ ឆ្នាំ១៩៧៦ សួន ត្រូវអង្គការបញ្ជូនទៅធ្វើពលកម្មលត់ដំកសាងគោលជំហរនៅមូលដ្ឋានភូមិភាគបូព៌ា ។ ពីខែសីហាឆ្នាំ១៩៧៦ដល់ខែកុម្ភៈឆ្នាំ១៩៧៧ សួន មកធ្វើការនៅមន្ទីរ ម១ ។ ពីខែកុម្ភៈឆ្នាំ ១៩៧៧ សួន ធ្វើការនៅមន្ទីរ ក១៦ រហូតដល់ថ្ងៃត្រូវអង្គការចាប់ខ្លួននៅខែវិច្ឆិកាឆ្នាំដដែល ។

## អំពីក្រុមគ្រួសារ

សួន មានបងប្អូន៧នាក់ ក្នុងចំណោមនោះពីរនាក់កំពុងតែរស់នៅប្រទេសបារាំង ។ ម្តាយរបស់គាត់បានស្លាប់ក្នុងឆ្នាំ១៩៥៣ ចំណែកឪពុកបានបាត់ដំណឹងតាំងពីឆ្នាំ១៩៧៣ ។

សួន រៀបការជាមួយប្រពន្ធរបស់គាត់ឈ្មោះ មោនិក សេងី នៅឆ្នាំ១៩៥៣ នៅប្រទេសបារាំង ក្នុងពេលដែលនៅជានិស្សិតទាំងពីរនាក់ ។ អ្នកទាំងពីរមានកូនស្រី៤នាក់ ។ មួយឆ្នាំ

បន្ទាប់ពី សួន វិលត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៥៦ ប្រពន្ធនិងកូនរបស់គាត់មករស់នៅប្រទេសកម្ពុជាដែរ ។ នៅឆ្នាំ ១៩៦៨ ទាំងអស់គ្នាបានវិលត្រឡប់ទៅរស់នៅប្រទេសបារាំង វិញ ។ ពេលដែល សួន វិលត្រឡប់មកប្រទេសកម្ពុជាជាលើក ទី២នៅខែធ្នូឆ្នាំ១៩៧៥ ប្រពន្ធនិងកូនរបស់គាត់មិនបានមក ជាមួយទេ ពោលគឺរស់នៅប្រទេសបារាំងដដែល ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ សួន បានទទួលការអនុញ្ញាតពី អង្គការ សរសេរសំបុត្រមួយច្បាប់ផ្ញើទៅប្រពន្ធដែលកំពុងតែ រស់នៅប្រទេសបារាំង ។ នៅខែកក្កដា ឆ្នាំដដែល បានទទួល ការអនុញ្ញាតឲ្យសរសេរមួយច្បាប់ទៀត ។ នៅក្នុងលិខិតនោះ សួន អំពាវនាវឲ្យប្រពន្ធកូនរបស់គាត់មករស់នៅប្រទេសកម្ពុជា ។ ក្រោយពីនោះមក សួន ដាច់ការទាក់ទងជាមួយប្រពន្ធរហូត ហើយក៏មិនបានដឹងថាតើប្រពន្ធនិងកូនរបស់គាត់បានមកប្រទេស កម្ពុជាឬក៏អត់ទេ ។

## អង្គការសម្ងាត់ដែល សួន មានទំនាក់ទំនងជាមួយ

សួន បានសារភាពថា អំឡុងពេលដែលខ្លួនធ្វើការនៅក្នុង ប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥ និងអំឡុងពេលដែលខ្លួនបំពេញ ការងារនៅប្រទេសបារាំងនិងនៅទីក្រុងប៉េកាំង ខ្លួនបានធ្វើការឲ្យ អង្គការ SDECE និងសេ.អ៊ី.អា ដោយបានទាក់ទងជាមួយ ជនជាតិបារាំងមួយចំនួនមានឈ្មោះ រីស, បារីយូ, រោប, ម៉ាណាក់, ការីយែ, អូវែតុន, គោលោត ។

ក្នុងអំឡុងពេលរស់នៅមន្ទីរ ម១ និងមន្ទីរ ក១៦, សួន និយាយថាបានទាក់ទងសកម្មភាពក្បត់ជាមួយអតីតបុគ្គលិកទូត មួយចំនួនដែលមកពីក្រៅប្រទេសនិងដែលស្នាក់នៅក្នុងមន្ទីរនោះ ដែរ ។

ក៏ប៉ុន្តែ នៅក្នុងចម្លើយសារភាព រាល់ការពិពណ៌នាអំពីការ ជួបជាមួយខ្មែរយៈនីមួយៗដើម្បីពិភាក្សាអំពីសកម្មភាពក្បត់ មិនបានបង្ហាញឲ្យឃើញការដាក់ឬទទួលផែនការណាមួយឬការ ធ្វើសកម្មភាពណាមួយសំដៅបំផ្លិចបំផ្លាញបដិវត្តន៍របស់ខ្មែរ ក្រហមទាល់តែសោះ ។ រាល់ការជួបជាមួយជនជាតិបារាំង កិច្ចសន្ទនាផ្តោតជុំវិញតែសភាពការណ៍នយោបាយក្នុងនិងក្រៅ ប្រទេសកម្ពុជាប៉ុណ្ណោះ រីឯការជួបជាមួយអតីតបុគ្គលិកទូតមាន តែការនិយាយអំពីការហូបមិនឆ្អែត ការធ្វើពលកម្មហួសកម្លាំង ការបាត់បង់សេរីភាព ការលួចរបស់របរសមូហភាព និងការនឹក រឭកក្រុមគ្រួសារដែលនៅឯបរទេស ។

## ការចាប់ខ្លួននិងចម្លើយសារភាព

ចិន សួន ត្រូវអង្គការចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ១៩៧៧ និងត្រូវសួរចម្លើយមិនតិចជាង១០ដង ។ កាលបរិច្ឆេទនៅលើ ឯកសារមាន ថ្ងៃទី២០ ទី២២ ទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧, ថ្ងៃទី៨ ទី១៩ ទី៣០ ខែធ្នូ ឆ្នាំ១៩៧៧, ថ្ងៃទី២ ទី៥ ទី៨ ខែមករា ឆ្នាំ១៩៧៨ និងឯកសារ៧ជុំទៀតមិនមានចុះកាល បរិច្ឆេទ ។ គ្មានឈ្មោះអ្នកសួរចម្លើយនៅលើឯកសារទេ ប៉ុន្តែ មានឯកសារពីរជុំមានចំណាររបស់អ្នកសួរចម្លើយជូនទៅថ្នាក់លើ និងមួយជុំទៀតមានចំណាររបស់កម្មាភិបាលថ្នាក់ខ្ពស់នៃមន្ទីរ ស-២១ ។

សួន សម្តែងការដឹងកំហុស និងសម្តែងការស្ញើចសរសើរ ចំពោះគោលមាគ៌ាដ៏មហាអស្ចារ្យរបស់បក្សកុម្មុយនិស្តកម្ពុជា ។ នៅក្នុងចម្លើយសារភាពចុះថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៧ សួន សារភាពថា ខ្លួនគ្មានចំណូលចិត្តនឹងសេ.អ៊ី.អាទេ ប៉ុន្តែខ្លួនធ្វើការ បម្រើអង្គការនេះទៅតាមការអូសទាញរបស់ ស៊ឹម វ៉ា និងសម្ភារ ដែលឈ្មោះនេះបានប្រគល់ឲ្យដូចជា រថយន្ត ដី ប្រាក់កាស ។ សួន បន្ថែមថា «បើពិនិត្យខ្លួនខ្ញុំស៊ីជម្រៅទៅឃើញថា ការបម្រើអា CIA ក៏ដូចការបម្រើអា SDECE ជាហេតុផលនៃបរិយាកាសមួយ ក្នុងសង្គមចាស់ ជាហេតុបច្ច័យនៃវណ្ណៈដើមខ្លួនដែលជាវណ្ណៈ សក្តិភូមិ ជាវណ្ណៈក្បត់ជាតិ ក្បត់ប្រជាជន ក្បត់បដិវត្តន៍ ហើយ ក្នុងនេះក៏អត់បានចាំអារម្មណ៍ឲ្យបានជ្រៅជ្រះដែរ ។ ...ដូច្នេះបើ គ្មានពន្លឺនៃបក្សកុម្មុយនិស្តកម្ពុជាដ៏ត្រឹមត្រូវនិងភ្លឺស្វាងមហាអស្ចារ្យ ទេ ខ្លួនខ្ញុំក៏មិនបានចាប់អារម្មណ៍លើអំពើក្បត់ទាំងនេះដែរ ខ្លួនខ្ញុំ សូមសម្តែងអំណរគុណដ៏ជ្រាលជ្រៅដល់បក្សជារៀងរហូតដល់ ជីវិតចុងក្រោយបង្អស់នៃខ្លួន ។ ជយោ! បក្សកុម្មុយនិស្តកម្ពុជាដ៏ ត្រឹមត្រូវនិងភ្លឺស្វាងមហាអស្ចារ្យ!» ។

គ្មានឯកសារឬប្រភពណាមួយដែលអាចបញ្ជាក់ថា ចិន សួន ត្រូវអង្គការសម្លាប់នៅថ្ងៃណាទេ ។

**សាន់ កល្យាណ**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៣៦៩ | ញ៉ឹម សុភ៉ាន់នី ហៅ នឹម (ស្រី) | ប្រពន្ធ អ៊ុក សាមឿន | ពាណិជ្ជកម្ម | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៧០ | តាំង ស៊ីវឡេង (ស្រី) | សាស្ត្រាចារ្យ | ភូមិភាគឧត្តរ | ១៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៧១ | ព្រុំ សៀង (ស្រី) | ប្រពន្ធ ស៊ាន អាន | ការបរទេស | ២៩-១២-៧៦ | ១២-៥-៧៧ |
| ២៣៧២ | អ៊ុត អុន ហៅ ណន | អនុវរសេនាធំ | កងពល៣១០ | ១០-១២-៧៦ | ១២-៥-៧៧ |
| ២៣៧៣ | អ៊ុម ចាន់ថេន ហៅ សំអាត | សមាជិក | រោងចក្រប្រេងកន្ទុក់ | ?-១១-៧៦ | ១២-៥-៧៧ |
| ២៣៧៤ | ខេង សំរួត | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៧៥ | ហៀវ ង៉ូវ | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៧៦ | ឈ្មាង ហាំ | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៧៧ | មិន សឿន ហៅ ឌឿន | ប្រធាននេសាទ | ភាគបស្ចិម | ៣១-១២-៧៦ | ១២-៥-៧៧ |
| ២៣៧៨ | សៀ គ្រប់ | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៧៩ | សាវ បាក់លី | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៨០ | ឈ្មាង ហឿន ហៅ ថាត | ពលទោ | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៨១ | ទុយ ដោក | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៨២ | ដួប ប៊ុនរឿន | ពលទោ | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៨៣ | អែម ឆៃ | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៨៤ | កែវ យ៉េន ហៅ វ៉ែន | យុទ្ធជន | ផែកំពង់សោម | ១-១២-៧៦ | ១២-៥-៧៧ |
| ២៣៨៥ | គង់ វ៉ិន ហៅ អន | ប្រធានរោងចក្រ | តំបន់៣ | ៧-១០-៧៦ | ១២-៥-៧៧ |
| ២៣៨៦ | កែ អួន | ពលទោ | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៨៧ | អ៊ុក សារឿន ហៅ ស៊ាប (ស្រី) | កម្មករថ្មី | រោងចក្រប-៤ | ២២-១០-៧៦ | ១២-៥-៧៧ |
| ២៣៨៨ | យឹម ឡេត | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៨៩ | យូ ហឿន ហៅ ភាព | យុទ្ធជន | ថាមពល | ?-១០-៧៦ | ១២-៥-៧៧ |
| ២៣៩០ | ប៊ុត ហ៊ីន | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៩១ | ព្រុំ ញ៉ូ ហៅ ស្រឿន | បច្ចេកទេសធ្វើថ្នាំ | សង្គមកិច្ច | ២១-៩-៧៦ | ១២-៥-៧៧ |
| ២៣៩២ | ដាញ់ ហេង | លោកសង្ឃ | យួន | ១១-១១-៧៦ | ១២-៥-៧៧ |
| ២៣៩៣ | ប្រុក យឹម | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៣៩៤ | សិទ្ធ រិទ្ធី ហៅ ឈាងគង | យុទ្ធជនចល័ត | តំបន់២៥ | ១៥-១១-៧៦ | ១២-៥-៧៧ |
| ២៣៩៥ | សំ ហ៊ាន ហៅ ស៊ីម | គណៈវប្បធម៌ | តំបន់១០៣ | ១១-១០-៧៦ | ១២-៥-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៣៩៦ | នួន យឿន ហៅ កឿន | សាស្ត្រាចារ្យ | តំបន់១០៣ | ២១-១០-៧៦ | ១២-៥-៧៧ |
| ២៣៩៧ | ដាច់ សូវ៉េ | ប្រជាជន | យួន | ១០-១២-៧៦ | ១២-៥-៧៧ |
| ២៣៩៨ | មាស សារ៉េត ហៅ កឿន | អនុព័ន្ធស្ថានទូត | ក្រសួងការបរទេស | ២៩-១០-៧៦ | ១២-៥-៧៧ |
| ២៣៩៩ | គុយ អិត | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៤០០ | ហុក ឈត | ប្រជាជន | បាត់ដំបង | ២៧-១១-៧៦ | ១២-៥-៧៧ |
| ២៤០១ | រដ្ឋ ង៉ិម ហៅ វុធ | លេខាកងធំ | ភ័ស្តុភារសេនាធិការ | ១១-១២-៧៦ | ១២-៥-៧៧ |
| ២៤០២ | ជុំ ឡាច ហៅ វ៉េង | អនុលេខាកងពល | ភូមិភាគឧត្តរ | ១៨-២-៧៧ | ១២-៥-៧៧ |
| ២៤០៣ | ហ៊ុន ចំរើន ហៅ ណាក់ | សមាជិក | កងពល៣១០ | ២៣-១-៧៧ | ១២-៥-៧៧ |
| ២៤០៤ | ភ៉ាន់ ឌឿន ហៅ សៀន | អនុវរសេនាធំ | ផែកំពង់សោម | ២៣-១-៧៧ | ១២-៥-៧៧ |
| ២៤០៥ | សំរិត ឈិន ហៅ ឈឿង | មេក្រុម | ពាណិជ្ជកម្ម | ២-២-៧៧ | ១២-៥-៧៧ |
| ២៤០៦ | ញឹម សឿន ហៅ ថន | យុទ្ធជន | សេនាធិការ | ១-២-៧៧ | ១២-៥-៧៧ |
| ២៤០៧ | ភា ឆាយ ហៅ ស៊ូ | គណៈបញ្ជី | ពាណិជ្ជកម្ម | ២-២-៧៧ | ១២-៥-៧៧ |
| ២៤០៨ | អ៊ុម កែវ | យុទ្ធជន | ការបរទេស | ១-១-៧៧ | ១២-៥-៧៧ |
| ២៤០៩ | អ៊ាន ហាត ហៅ ហាន | យុទ្ធជន | ពាណិជ្ជកម្ម | ៤-២-៧៧ | ១២-៥-៧៧ |
| ២៤១០ | ប៉ែន មិត្ត ហៅ ជុំ | អនុប្រធានមន្ទីរ | កងពល៣១០ | ៣០-២-៧៧ | ១២-៥-៧៧ |
| ២៤១១ | ស៊ុន ថន ហៅ វ៉ន | យុទ្ធជន | ការបរទេស | ២-២-៧៧ | ១២-៥-៧៧ |
| ២៤១២ | កែវ ផាត់ | មេក្រុម | កងពល៣១០ | ៦-២-៧៧ | ១២-៥-៧៧ |
| ២៤១៣ | អ៊ុច ចាប ហៅ ជី | មេក្រុម | ពាណិជ្ជកម្ម | ៨-២-៧៧ | ១២-៥-៧៧ |
| ២៤១៤ | សាន់ នេន ហៅ ផេង | លេខាកងធំ | ពាណិជ្ជកម្ម | ៧-២-៧៧ | ១២-៥-៧៧ |
| ២៤១៥ | ញឹប ស្រេង ហៅ ហួត | មេពួក | ពាណិជ្ជកម្ម | ៨-២-៧៧ | ១២-៥-៧៧ |
| ២៤១៦ | មុត ម៉េត ហៅ កាក់ ឬ ថុល | ប្រធានកងហ | ពាណិជ្ជកម្ម | ៧-២-៧៧ | ១២-៥-៧៧ |
| ២៤១៧ | ហែក ហ៊ាង ហៅ ហុង | ប្រធានមន្ទីរ | ពាណិជ្ជកម្ម | ៧-២-៧៧ | ១២-៥-៧៧ |
| ២៤១៨ | ប្រាក់ លួន ហៅ សោ | យុទ្ធជន | ពាណិជ្ជកម្ម | ៨-២-៧៧ | ១២-៥-៧៧ |
| ២៤១៩ | ចុង យូម៉េង ហៅ ហ៊ាង | យុទ្ធជន | ដឹកជញ្ជូនទឹក | ៨-២-៧៧ | ១២-៥-៧៧ |
| ២៤២០ | ឯក វុន ហៅ វ៉េន | លេខាកងធំ | ពាណិជ្ជកម្ម | ៧-២-៧៧ | ១២-៥-៧៧ |
| ២៤២១ | អួន យឿង ហៅ សិត | មេក្រុម | ពាណិជ្ជកម្ម | ១២-២-៧៧ | ១២-៥-៧៧ |
| ២៤២២ | នូ ឡុញ ហៅ សាន | មេក្រុមពេទ្យ | ពាណិជ្ជកម្ម | ១០-២-៧៧ | ១២-៥-៧៧ |
| ២៤២៣ | ផៃ ហេង | ស្ថិតិសត្វ | កងពល៣១០ | ១៣-២-៧៧ | ១២-៥-៧៧ |
| ២៤២៤ | ឃួន រ៉ុម ហៅ ម៉ែន | ប្រធានកងហ | ផែកំពង់សោម | ១៥-២-៧៧ | ១២-៥-៧៧ |
| ២៤២៥ | ជុំ ថៃអ៊ី ហៅ ប៊ុក | មេក្រុម | ពាណិជ្ជកម្ម | ១៧-២-៧៧ | ១២-៥-៧៧ |
| ២៤២៦ | សោម ធីម ហៅ យុន | អនុក្រុម | ថាមពល | ៤-២-៧៧ | ១២-៥-៧៧ |

(នៅមានត)

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

**គង់ មារតី អាយុ៥៥ឆ្នាំ**
**អតីតបុគ្គលិកនៅធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម**
**និងជាអតីតគ្រូបង្វឹកកីឡាយូដូ**

*គង់ មារតី គឺជាអ្នកទោសម្នាក់ដែលរួចផុតពីការយកទៅសម្លាប់របស់ខ្មែរក្រហម ។ នៅមុនឆ្នាំ១៩៧៥ មារតី គឺជាបុគ្គលិកនៅធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម និងជាគ្រូបង្វឹកកីឡាយូដូ ។ នៅឆ្នាំ១៩៧៩គាត់បានត្រឡប់ទៅធនាគារដែលគាត់ធ្លាប់ធ្វើការពីមុន ហើយបានឃើញឯកសារចំនួន៤សន្លឹកដែលពាក់ព័ន្ធនឹងគាត់ ហើយឯកសារ២សន្លឹកមានបិទរូបថតពាក់កណ្តាលខ្លួនរបស់គាត់ ។ គាត់បានយកឯកសារទាំងនេះមករក្សាទុក ។ សូមអានរឿងរ៉ាវរបស់ មារតី ខាងក្រោមនេះ ៖*

ស្រុកកំណើតខ្ញុំនៅភូមិអាចារ្យលាក់ ឃុំអាចារ្យលាក់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ខ្ញុំជាកូនកំព្រា គ្មានសាច់ញាតិ គ្មានបងប្អូន ។ ខ្ញុំធ្វើអ្វីៗដោយពឹងផ្អែកលើសមត្ថភាពខ្លួនឯង ។ ឪពុករបស់ខ្ញុំស្លាប់ចោលតាំងពីខ្ញុំមានអាយុ២ឆ្នាំ ។ ក្រោយពីឪពុកខ្ញុំស្លាប់ទៅ ជីវភាពគ្រួសារខ្ញុំមានសភាពដុនដាបឡើងៗ ទើបឪពុកធម៌របស់ខ្ញុំដែលជាចៅហ្វាយស្រុករៀង មកសុំខ្ញុំពីម្តាយខ្ញុំយកទៅចិញ្ចឹម ហើយស្រលាញ់ទុកដូចជាកូនបង្កើតរបស់គាត់ ។ ឪពុកចិញ្ចឹមខ្ញុំស្លាប់នៅពេលដែលខ្ញុំមានអាយុ ១០ឆ្នាំ ចំណែកម្តាយចិញ្ចឹមខ្ញុំស្លាប់នៅឆ្នាំ១៩៦៥ ។ បន្ទាប់ពីឪពុកម្តាយចិញ្ចឹមខ្ញុំស្លាប់ មានព្រះសង្ឃមួយអង្គបានយកខ្ញុំទៅចិញ្ចឹមបន្តទៀត ។ ខ្ញុំរស់នៅក្នុងវត្តមួយនៅក្នុងខេត្តកំពង់ធំបានរយៈពេល១ឆ្នាំខ្ញុំក៏ផ្លាស់មករស់នៅភ្នំពេញដើម្បីបន្តការសិក្សា ។ ខ្ញុំស្នាក់នៅវត្តប្រយុវង្ស កុដិលេខ១ ។ ខ្ញុំចូលរៀននៅសាលាពញាយ៉ាត ក្រោយមកប្តូរទៅជាសាលាទួលស្វាយព្រៃ (នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាលានេះត្រូវបានប្រែក្លាយទៅជាមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង) ហើយបន្តការសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ ពេលចេញពីរៀន ខ្ញុំឆ្លៀតទៅធាក់ស៊ីក្លូនិងលក់នំបុ័ងដើម្បីរកប្រាក់មកផ្គត់ផ្គង់ការរៀនសូត្ររបស់ខ្ញុំ ។ ពេលខ្លះទៀតខ្ញុំដើរបិណ្ឌបាត្រជាមួយព្រះសង្ឃ ។ នៅពេលខ្ញុំរៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រឆ្នាំទី៣ ខ្ញុំបានចូលបម្រើការងារនៅធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម និងជាគ្រូបង្វឹកកីឡាយូដូ ។ ខ្ញុំឆ្លៀតរៀនភាសាបារាំងបន្ថែមនៅក្រៅម៉ោងធ្វើការ ។


គង់ មារតី ក្នុងរបប លន់ នល់

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំកំពុងតែរៀបចំឯកសារការងារប្រចាំថ្ងៃរបស់ធនាគារ ។ កន្លែងធ្វើការរបស់ខ្ញុំស្ថិតនៅខាងជើងផ្សារធំថ្មី ។ មិត្តភក្តិរបស់ខ្ញុំពីរនាក់ងឿងឆ្ងល់ ដោយឃើញប្រជាជនជ្រួលច្របល់ ហើយឃើញកងទ័ពស្លៀកពាក់ខោអាវពណ៌ខ្មៅនិងមួរជើងខោម្ខាងប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់ ។ ខ្មែរក្រហមបានចូលក្នុងធនាគារ ហើយដេញបុគ្គលិកទាំងអស់ចេញ ។ ខ្ញុំនិងមិត្តភក្តិខ្ញុំ២-៣នាក់ បានចាកចេញទៅដោយមិនបានចាក់សោបន្ទប់ ហើយធ្វើដំណើរលាយឡំជាមួយប្រជាជនផ្សេងៗទៀតដែលកំពុងតែចាកចេញពីទីក្រុង ។ នៅតាមផ្លូវខ្ញុំឃើញសាកសពជាច្រើន ហើយខ្ញុំឮកងទ័ពអាវខ្មៅប្រកាសតាមមេក្រូថា “អង្គការត្រូវការអ្នកចេះដឹងនិងអ្នកមានជំនាញបច្ចេកទេស ឬអ្នកដែលមានបណ្ឌាស័ក្តិធ្លាប់ធ្វើការនៅក្នុងរបបលន់នល់ ឲ្យចូលទីក្រុងវិញដើម្បីរៀបចំទីក្រុងឲ្យបានស្អាតល្អ” ។ ខ្ញុំឃើញប្រជាជនជាច្រើនបានទៅចុះឈ្មោះ ភាគច្រើនគឺជាបុរស ។ អង្គការបានលើកទឹកចិត្តដល់អ្នកទាំងនោះដោយផ្តល់ជាអង្ករ ត្រីងៀត សាច់ជ្រូក ទឹកក្រូច

នំប៉័ង ។ ខ្ញុំឈប់សំចតនៅវត្តចំប៉ា នៅស្រុកកៀនស្វាយអស់រយៈពេល១ខែដើម្បីរង់ចាំអង្គការអនុញ្ញាតឲ្យវិលចូលទីក្រុងភ្នំពេញវិញ ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃក្តីសង្ឃឹមកាន់តែតិចទៅៗ ។

ភ្លៀងចាប់ផ្តើមធ្លាក់ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ឲ្យចូលមូលដ្ឋានដើម្បីប្រកបការងារស្រែចម្ការ ។ ពេលនោះអ្នកដែលមានសាច់ញាតិនៅតាមខេត្តបានចេញដំណើរជាបណ្តើរៗ ចំណែកគ្រួសារខ្លះដែលអត់មានសាច់ញាតិនៅតាមបណ្តាខេត្ត នៅបង្អែបង្អង់រេរាមិនដឹងត្រូវទៅទីណាទៀត ។ ខ្ញុំធ្វើដំណើរទៅមុខដោយគ្មានគោលដៅពិតប្រាកដ ។

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំបានឆ្លងទន្លេត្រង់អ្នកលឿង ។ នៅផ្លូវបំបែកទៅព្រៃវែងនិងស្វាយរៀង មានស្នាក់ការធំមួយដែលខ្មែរក្រហមប្រមូលប្រជាជនដាក់តាមមូលដ្ឋាន ។ ខ្ញុំបោះកូនដុំថ្មមួយដុំតូចឡើងទៅលើ ហើយផ្សងថា បើដុំថ្មនោះធ្លាក់មកបញ្ឈរខ្ញុំនឹងទៅតាមផ្លូវទិសខាងកើត ប៉ុន្តែបើវាផ្តេកខ្ញុំនឹងទៅតាមផ្លូវទិសខាងជើង ។ ដុំថ្មនោះធ្លាក់មកបញ្ឈរ ខ្ញុំក៏ធ្វើដំណើរទៅទិសខាងកើតតាមផ្លូវទៅខេត្តស្វាយរៀង ។ ខ្ញុំធ្វើដំណើរទៅដល់ឃុំកំពង់សឹង កងទ័ពខ្មែរក្រហមម្នាក់ចង្អុលមុខខ្ញុំ ហើយបញ្ជាឲ្យខ្ញុំអង្គុយប្រមូលផ្តុំជាមួយប្រជាជនជាច្រើននាក់ទៀតនៅទីនោះ ។ ទាំងអស់គ្នាអង្គុយអត់បានហូបបាយទឹកពេញមួយថ្ងៃ ។ អង្គការចាប់ផ្តើមធ្វើប្រវត្តិរូប ។ ដោយសារមុនឆ្នាំ១៩៧៥ ខ្ញុំធ្លាប់ធ្វើការងាររដ្ឋផងនិងរៀនផង ខ្ញុំសម្រេចដាក់នៅក្នុងប្រវត្តិរូបថាខ្ញុំគឺជានិស្សិត ។ នៅពេលយប់អង្គការចែកអង្ករឲ្យមួយគ្រួសារ១កំប៉ុង ។ ខ្ញុំហូបបាយមិនចូលទេ ពីព្រោះខ្ញុំឃើញកងទ័ពខ្មែរក្រហមចងបណ្តើរមនុស្សទាំងហ្វូងៗមិនដឹងជាយកទៅទីណា ។

មួយថ្ងៃក្រោយមក កងទ័ពខ្មែរក្រហមម្នាក់ប្រកាសថាប្រជាជននៅទីនេះត្រូវទៅលត់ដំមួយរយៈសិន ហើយមិនបាច់យករបស់របរអ្វីទៅតាមទេ ពីព្រោះនៅទីនោះអង្គការមានរបស់របរឧបត្ថម្ភគ្រប់គ្រាន់ហើយ ។ ប្រជាជនដើរជាជួរៗដោយមានឈ្លបកាន់កាំភ្លើងដើរអមពីខាងក្រោយ ។ យើងបានទៅដល់មន្ទីរសន្តិសុខពងទឹកដែលស្ថិតនៅក្បែរទំនប់ពោធិបូរីក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង ។ ខ្មែរក្រហមបញ្ជាឲ្យប្រជាជនអង្គុយជាជួរដើម្បីធ្វើប្រវត្តិរូបឡើងវិញ បន្ទាប់មកបញ្ជូនចូលទៅក្នុងមន្ទីររួចហើយចាក់សោពីខាងក្រៅ ។ នៅក្នុងនោះមានតែកេសគ្រាប់កាំភ្លើងមួយសម្រាប់បន្ទោរបង់ ។ ពេលនោះទើបខ្ញុំដឹងខ្លួនថាខ្ញុំជាប់ឃុំឃាំងហើយ ។

អ្នកទោសដេកក្បាលផ្ទុយគ្នា ហើយជើងត្រូវដាក់ខ្នោះជាប់នឹងដែករនូតមួយយ៉ាងវែងដែលចាក់សោនៅខាងចុង ។ ជារឿយៗអ្នកយាមបញ្ចាំងពិលមើលនិងរាប់ចំនួនអ្នកទោស ។ ខ្ញុំជាប់នៅមន្ទីរសន្តិបាលនេះអស់រយៈពេល១០ថ្ងៃ ទើបអង្គការចម្រាញ់យកអ្នកដែលមានបណ្តាសក្តិចេញអស់ ហើយដោះលែងអ្នកនៅសល់ឲ្យមកធ្វើការនៅតាមការដ្ឋានវិញ ។ ខ្ញុំធ្វើការនៅការដ្ឋានធ្វើថ្នល់ ។ ក្រុមរបស់ខ្ញុំមានសមាជិក៥០នាក់ ។ ការងារនេះចាប់ផ្តើមពីម៉ោង៥ព្រឹកដល់ម៉ោង១២ថ្ងៃត្រង់ និងពីម៉ោង១ដល់ម៉ោង៦ល្ងាច ។ អ្នកទោសដែលធ្វើការនៅក្នុងការដ្ឋាននេះមានចំនួនប្រមាណ៥០០នាក់ ជាអតីត សិស្ស និស្សិត គ្រូបង្រៀន និងទាហានរបបលន់ណុល ។

ក្រោយមក ខ្ញុំនិងអ្នកទោសមួយចំនួនទៀតត្រូវប្តូរទៅជីកស្រះទឹកធំមួយសម្រាប់ស្តុកទឹក ។ យប់ខ្លះខ្ញុំដេកលក់ទាំងទឹកភ្លៀងទទឹកជោក ។ អ្នកទោសចាប់ផ្តើមឈឺនិងបាក់កម្លាំងស្លាប់ជាបន្តបន្ទាប់ ។ បន្ទាប់ពីនោះ អង្គការបានផ្លាស់ខ្ញុំឲ្យរកបន្លែឲ្យចុងភៅនៅផ្ទះបាយ ។ ពេលនោះការហូបចុករបស់ខ្ញុំបានប្រសើរឡើងបន្តិច ។ ពេលយប់ខ្ញុំជួយចាប់សរសៃឲ្យប្រធានក្រុមដាំស្ល មេពួកនិងមេក្រុម ដើម្បីដោះដូរអាហារបន្តិចបន្តួចមកហូប និងកុំឲ្យអ្នកទាំងនោះរាយការណ៍មិនល្អពីខ្ញុំ ។ ខ្ញុំបានប្រាប់ខ្មែរក្រហមថាខ្ញុំចេះចាប់សរសៃ ប៉ុន្តែតាមការពិតខ្ញុំមិនមែនជាអ្នកចាប់សរសៃទេ ។ ពេលដែលខ្ញុំរស់នៅទីក្រុងភ្នំពេញខ្ញុំធ្លាប់ហាត់កីឡា និងជាគ្រូបង្វឹកកីឡាយូដូ ដូច្នេះខ្ញុំអាចដឹងខ្លះៗអំពីសរីរាង្គមនុស្ស ។ យប់មួយ កម្មាភិបាលម្នាក់បានហៅខ្ញុំទៅចាប់សរសៃជង្គង់របស់គាត់ដែលគ្រេច ។ ខ្ញុំស្ទាបត្រង់ក្បាលជង្គង់ដែលឈឺ ហើយទាញឆ្អឹងឲ្យត្រូវសន្លាក់ឡើងវិញ ហើយរឹតជាមួយខ្លាញ់ពស់ថ្លាន់លាយធ្យូងបុកផ្អោបជាមួយបន្ទះឫស្សី ។ កម្មាភិបាលនោះបានឲ្យបាយមួយចម្អែតយ៉ាងឆ្ងាញ់ដល់ខ្ញុំ ។ មួយរយៈខ្លីក្រោយមកខ្ញុំបានប្តូរមកក្រុមពលកម្មវិញ ។ គ្នាខ្ញុំពីមុននៅសល់តែជាង៣០នាក់ប៉ុណ្ណោះ ។

ខ្ញុំបានប្តូរមកធ្វើការនៅការដ្ឋានថ្មីនៅវត្តតាគោកស្ថិតនៅក្នុងឃុំល្វា ។ នៅទីនោះខ្ញុំឃ្លានខ្លាំងណាស់ ។ ពេលខ្លះខ្ញុំដើរចេញពីជួរមកចាប់កង្កែប រើសក្តាម ខ្ចៅ ថ្លែន បង្គួយ យកមកហូប ហើយត្រូវឈ្លបវាយនឹងមែកឫស្សី ។ រាល់យប់មុនពេលចូលក្នុងវិហារវិញ អ្នកទោសត្រូវបង្ហាញខ្លួនហើយរាប់ឈ្មោះឲ្យឈ្លប ។

នៅចុងឆ្នាំ១៩៧៦ អង្គការប្រកាសដោះលែងអ្នកទោសមួយចំនួនឲ្យវិលទៅមូលដ្ឋានវិញ លើកលែងតែអ្នកទោស២០នាក់ដែលអង្គការបានប្រកាសថាមិនទាន់កសាងខ្លួនបាន ។ ខ្ញុំនៅក្នុងចំណោមអ្នកទោស២០នាក់នោះ ។ ប្រធានសន្តិសុខហៅអ្នកទោសទាំង២០នាក់មកឈរតម្រង់ជួរដោយឡែក ចំណែកអ្នកដែលត្រូវដោះលែងត្រូវអង្គការហៅឲ្យឡើងឡានយោធា៣គ្រឿងហើយដឹកចេញទៅបាត់ ។ ក្រោយមកខ្ញុំបានដឹងថាអ្នកទោសដែលឡើងឡានទៅគឺត្រូវបញ្ជូនយកទៅសម្លាប់នៅភ្នំឈើកាច់ ។ ខ្ញុំបានឮឈ្លបជជែកគ្នាអំពីរឿងនេះ ។ អ្នកទោស២០នាក់ដែលនៅសល់មានទាំងខ្ញុំនៅក្នុងនោះផង ត្រូវអង្គការដោះលែងឲ្យវិលមកមូលដ្ឋានវិញ ។ បន្ទាប់ពីរឿងនេះកើតឡើង ក្រុមរបស់ខ្ញុំដែលមានអ្នកទោសសរុប៥០នាក់នៅរស់តែខ្ញុំម្នាក់គត់ ចំណែកក្រុមខ្លះទៀតនៅរស់២-៣នាក់ ។

អង្គការបានឲ្យអង្ករម្នាក់១កំប៉ុងនិងអំបិលខ្លះដល់អ្នកទោសដែលត្រូវដោះលែង ។ ខ្ញុំមិនហ៊ានដាំបាយស្រួយហូបទេ ព្រោះខ្លាចអួលបាយស្លាប់ ។ ថ្ងៃនោះខ្ញុំបានសម្រាកពេញមួយថ្ងៃ ។ ខ្ញុំអាចដកដង្ហើមបានយ៉ាងវែងដើម្បីស្រូបខ្យល់អាកាស ។ ខ្ញុំអាចមើលទេសភាពនៅជុំវិញខ្លួនបានយ៉ាងស្រួលដោយគ្មានឈ្លបឃ្លាំមើល ។

ថ្ងៃបន្ទាប់ អង្គការបានចែកលិខិតដោះលែងឲ្យម្នាក់មួយ ប៉ុន្តែមិនអនុញ្ញាតឲ្យអ្នកទោសបើកលិខិតនោះមើលទេ ។ មុនពេលចេញដំណើរ កម្មាភិបាលគុកបានអប់រំអ្នកទោសថា «ពេលត្រឡប់ទៅដល់មូលដ្ឋានវិញត្រូវខិតខំកសាងខ្លួនបម្រើអង្គការឲ្យអស់ពីចិត្ត កុំក្បត់អង្គការ ហើយកុំឲ្យត្រឡប់មកមន្ទីរកែប្រែនេះសាជាថ្មី» ។

ខ្ញុំបានធ្វើដំណើរមកទីស្នាក់ការឃុំកំពង់សីង ។ ឈ្លបម្នាក់បានឃាត់ខ្លួនខ្ញុំ ។ ខ្ញុំបានហុចលិខិតដោះលែងទៅឲ្យឈ្លបនោះ ។ ពេលអានលិខិតនោះហើយ ឈ្លបនោះខ្សឹបគ្នាជាមួយប្រធានឃុំនិងសម្លឹងមើលមុខខ្ញុំ ។ ប្រធានឃុំបានយកសៀវភៅមកកត់ឈ្មោះខ្ញុំ ហើយសួរសំណួរជាច្រើនអំពីការរស់នៅក្នុងរបបសង្គមរាស្ត្រនិយមនិងរបបលន់នល់ ។ ខ្ញុំនៅតែរក្សាពាក្យសម្តីដដែលៗថា ខ្ញុំគឺជានិស្សិតដែលស្រលាញ់ប្រជាជននិងស្រលាញ់អង្គការបដិវត្តន៍ ។

មកដល់មូលដ្ឋានវិញ អង្គការចាត់តាំងឲ្យខ្ញុំធ្វើការនៅក្នុងក្រុមមនុស្សចាស់ផលិតសម្ភារកសិកម្ម ។ ខ្ញុំខិតខំធ្វើការងារស្ទើរតែគ្មានពេលសម្រាក ព្រោះខ្ញុំដឹងខ្លួនឯងថាអង្គការកំពុងតែតាមដានសកម្មភាពរបស់ខ្ញុំ ។ មួយរយៈក្រោយមក សហករណ៍ភូមិខ្ញុំត្រូវការអ្នករែកទឹកដាក់ក្នុងរោងបាយ ហើយខ្ញុំបានទទួលការចាត់តាំងឲ្យធ្វើការងារនេះ ។ មុនពេលខ្ញុំចាកចេញពីរោងសិប្បកម្ម ប្រជាជនមូលដ្ឋានបានផ្តាំខ្ញុំថា «ត្រូវចេះសម្របខ្លួនតាមកាលៈទេសៈ ហើយត្រូវចេះដាំដើមគ» ។

ខ្ញុំរែកទឹកពីអណ្តូងដែលមានចម្ងាយប្រមាណ៨០០ម៉ែត្រពីរោងបាយ ។ ខ្ញុំធ្វើឧបករណ៍រ៉ៃយោងទឹកពីអណ្តូងជំនួសឲ្យការយោងទឹកដោយដៃ ។ ពេលទំនេរខ្ញុំឆ្លៀតដាំបន្លែបន្ថែមទៀតដើម្បីយកមកផ្គត់ផ្គង់នៅក្នុងសហករណ៍ ។ ពេលខ្លះទៀតខ្ញុំចាប់សសៃឲ្យអ៊ំចាស់ៗ ប្រធានក្រុម ប្រធានភូមិ ប្រធានសហករណ៍ និងប្រធានចុងភៅ ដើម្បីយកចិត្តអ្នកទាំងនោះ ។

ដោយឃើញខ្ញុំខិតខំប្រឹងប្រែងធ្វើការងារ អង្គការបានប្តូរខ្ញុំឲ្យទៅធ្វើជាអ្នកដាំបន្លែនិងចិញ្ចឹមសត្វ ។ ចម្ការដែលខ្ញុំធ្វើស្ថិតនៅឆ្ងាយពីភូមិ ។ ខ្ញុំបានទទួលរបបអាហារហូបចុកគ្រាន់បើជាងកាលដែលរស់នៅក្នុងមូលដ្ឋាន ។

នៅចុងឆ្នាំ១៩៧៧ អង្គការផ្លាស់អ្នកគ្រប់គ្រងថ្មីមកជំនួសអ្នកគ្រប់គ្រងចាស់ ។ ប្រធានសន្តិសុខចាស់ត្រូវជំនួសដោយប្រធានសន្តិសុខថ្មីដែលមកពីភូមិភាគនិរតី ។ អង្គការបានរកឃើញអ្នកដែលជាប់និន្នាការជាមន្ត្រីរាជការក្នុងរបបចាស់ ជនជាតិចាមវៀតណាម និងសាច់ញាតិរាជវង្ស ហើយផ្លាស់ប្តូរអ្នកទាំងនោះទៅភូមិថ្មីទាំងអស់ ។ ខ្ញុំគ្មានឈ្មោះនៅក្នុងបញ្ជីប្តូរភូមិទេ ពីព្រោះខ្ញុំគ្មានសាច់ញាតិណានៅរស់ ។

ទឹកទន្លេចាប់ផ្តើមឡើងយ៉ាងគំហុក ។ ខ្ញុំបាននៅរស់នៅលើ

ទួលកោះខ្វែកជាមួយអ៊ីម្នាក់ដែលត្រូវជាឪពុកបង្កើតរបស់ប្រធានភូមិ ។ ខ្ញុំជាអ្នកមើលការខុសត្រូវសត្វមាន់ ទា ជ្រូក គោ និងក្របី នៅលើកោះនេះ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ពេលដែលមានការសម្លាប់មនុស្សជាខ្សែសង្វាក់ ប្រធានភូមិបានមកលេងឪពុករបស់គាត់នៅលើកោះ ហើយផ្តាំផ្ញើខ្ញុំឲ្យជួយមើលថែរក្សាឪពុករបស់គាត់ផង និងកុំត្រឡប់ទៅភូមិវិញឲ្យសោះ ។ ចាប់តាំងពីពេលនោះមកប្រធានភូមិរូបនោះក៏បាត់ខ្លួនរហូត ។ ដោយសភាពការណ៍កាន់តែតឹងតែងឡើងៗ ពេលថ្ងៃខ្ញុំលាក់ខ្លួននៅក្នុងព្រៃ ពេលយប់ទើបខ្ញុំត្រឡប់មកទីទួលនោះវិញ ។ ខ្ញុំបានឮស្នូរកាំភ្លើងមកពីទិសខាងកើតហើយរំកិលមកកាន់តែជិត ។ ក្រោយមកមានស្នូរយន្តហោះទម្លាក់គ្រាប់បែកនៅត្រង់បន្ទាយរបស់ខ្មែរក្រហម ។ ខ្ញុំបានឃើញកងទ័ពខ្មែរក្រហមបាក់ទ័ពហើយហែលទឹកឆ្លងកាត់ទន្លេទៅត្រើយខាងលិច ។ ប្រជាជនផ្អើលឈូឆរដោយសារនៅត្រើយខាងកើតអ្នកលៀងត្រូវបានកងទ័ពវៀតណាមរំដោះ ។ ខ្ញុំរត់ចេញពីក្នុងព្រៃមកវិញ ហើយស្វែងរកឪពុករបស់ប្រធានភូមិប៉ុន្តែមិនបានជួបគាត់សោះ ។ ខ្ញុំដើរសំដៅមករកផ្លូវជាតិហើយធ្វើដំណើរមកទីក្រុងភ្នំពេញ ។ ពេលនោះមានខិត្តប័ណ្ណជាច្រើននៅរាយប៉ាយពាសពេញផ្លូវ ។ ខ្ញុំត្រឡប់មកដល់ទីក្រុងភ្នំពេញវិញដោយសុវត្ថិភាព ។

ខ្ញុំមិនចង់បានអ្វីសម្រាប់ជាសំណងជំងឺចិត្តទេ ខ្ញុំគ្រាន់តែសង្ឃឹមថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងកើតឡើងក្នុងពេលឆាប់ៗខាងមុខនេះ ។ ខ្ញុំចង់កត់ត្រាទុកនូវរឿងរ៉ាវរបស់ខ្ញុំដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមទុកឲ្យកូនចៅរបស់ខ្ញុំមើលទៅថ្ងៃក្រោយទៀត និងជាឯកសារប្រវត្តិសាស្ត្រ ។ ខ្ញុំមិនដែលនឹកស្មានថាខ្ញុំអាចមានជីវិតរស់នៅទេ ។ ◆◆◆

## សុត នៅ

## អតីតបុគ្គលិកពេទ្យនៅមន្ទីរពេទ្យវិកលចរិតព្រែកត្នោត

នេះគឺជារូបថតរបស់ សុត នៅ ដែលថតនៅក្នុងឆ្នាំ១៩៧២ ក្នុងពេលទទួលមេដាយឥស្សរិយយសពីអភិបាលខេត្តកណ្តាល ។ នៅ ជាអតីតបុគ្គលិកពេទ្យនៅមន្ទីរពេទ្យវិកលចរិតព្រែកត្នោត ។ នៅ និងប្រពន្ធរបស់គាត់ បានស្លាប់ក្នុងឆ្នាំ១៩៧៧ ហើយកូនរបស់គាត់១២នាក់ក្នុងចំណោមកូន១៨នាក់


សុត នៅ ថតឆ្នាំ១៩៧...

ក៏ស្លាប់ជាបន្តបន្ទាប់ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កូនស្រីទី៧របស់ នៅ ឈ្មោះ សុត ម៉ាឡាយ៉ា បានរក្សាទុករូបថតនេះយ៉ាងប្រយ័ត្នប្រយែង ដោយដាក់នៅក្នុងថង់ប្លាស្ទិកហើយលាក់ទុកនៅក្នុងកាបូបស្ពាយដែលដេរពីបាវអង្ករ ។ កងឈ្លបបានមកឆែកផ្ទះរបស់ ម៉ាឡាយ៉ា នៅពេលដែលគាត់មិននៅផ្ទះ ប៉ុន្តែមិនបានប្រទះឃើញរូបថតនេះទេ ។ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ កូនស្រីទី៩របស់ នៅ ឈ្មោះ គីម សុផានី បានយករូបថតនេះមករក្សាទុក ។ ខាងក្រោមនេះជាការរៀបរាប់របស់ គីម សុផានី អំពីរឿងរ៉ាវដែលកើតឡើងនៅក្នុងក្រុមគ្រួសាររបស់គាត់ ÷

ក្នុងចំណោមបងប្អូនរបស់ខ្ញុំទាំង១៨នាក់ព្រមទាំងប៉ាម៉ាក់របស់ខ្ញុំ គឺមានតែខ្ញុំនិងបងស្រីរបស់ខ្ញុំឈ្មោះ ម៉ាឡាយ៉ា ប៉ុណ្ណោះដែលនៅរស់ពីរបបខ្មែរក្រហម ។ ប៉ាម៉ាក់របស់ខ្ញុំស្លាប់នៅក្នុងឆ្នាំតែមួយនៅក្នុងរបបខ្មែរក្រហមដោយសារជំងឺនិងគ្មានអាហារបរិភោគ ចំណែកបងប្អូនខ្ញុំផ្សេងៗទៀតក៏ស្លាប់ដោយសារជំងឺការអត់អាហារ និងជាប់ពាក់ព័ន្ធនឹងការជំរើសសង្គមចាស់ ។

ប៉ាមានរាងស្គម ស្តើង ខ្ពស់ សម្បុរសណ្តែកបាយ ។ ប៉ាមិនសូវនិយាយស្តីច្រើនទេ គាត់ជាមនុស្សម៉ឺងម៉ាត់ ។ ប៉ាស្រលាញ់កូនស្រីច្រើនជាងកូនប្រុស ។ ប៉ាមានស្រុកកំណើតនៅភូមិព្រៃព្រីង ឃុំបែកចាន ស្រុកចោមចៅ ខេត្តកណ្តាល ។

កាលពីក្មេងជីវភាពគ្រួសាររបស់ប៉ាមានការខ្វះខាតព្រោះគាត់មានបងប្អូនច្រើន ។ ប៉ារស់នៅវត្តពោធិសត្ថារាម ។

ប៉ាស្រឡាញ់មុខវិជ្ជាពេទ្យណាស់ ។ ពេលលោកយាយលោកតាឈឺម្តងៗ គាត់មានការពិបាកក្នុងការពឹងពាក់អ្នកដទៃដើម្បីរកលុយមកព្យាបាលជំងឺ ម៉្លោះហើយទើបប៉ាសម្រេចចិត្តចូលរៀនពេទ្យដើម្បីងាយស្រួលព្យាបាលឪពុកម្តាយគាត់ ។ ប៉ារៀនពូកែណាស់ ទាំងភាសាបារាំងទាំងខាងជំនាញថ្នាំពេទ្យ ។

ប៉ាខិតខំប្រឹងប្រែងធ្វើការងារណាស់ទម្រាំតែមានផ្ទះធំទូលំទូលាយ ។ គាត់មិនដែលធ្វេសប្រហែសក្នុងការងារទេ ។ ប៉ា គោរពពេលវេលានិងចូលចិត្តជួយអ្នកក្រីក្រ ។ នៅឆ្នាំ១៩៧២ ក្រសួងសុខាភិបាលបានប្រគល់មេដាយឥស្សរិយយសឲ្យប៉ាដោយសារគាត់ធ្វើការងារបានល្អ ។ ប៉ាបានឡើងឋានៈជាបន្តបន្ទាប់ ។

ប៉ាស្រលាញ់ម៉ាក់ណាស់ ។ ចាប់តាំងពីខ្ញុំដឹងក្តីមក ខ្ញុំមិនដែលឃើញគាត់ទាំងពីរឈ្លោះគ្នាម្តងណាឡើយ ។ ប៉ាខំរកប្រាក់ដើម្បីចិញ្ចឹមម៉ាក់និងកូនៗទាំង១៤នាក់ ។ ប៉ាអាចរកចំណូលបានច្រើនសម្រាប់គ្រួសារ ។ ក្រៅពីធ្វើការនៅមន្ទីរពេទ្យព្រែកត្នោត ប៉ាទៅចាក់ថ្នាំនិងព្យាបាលអ្នកជំងឺឲ្យអ្នកភូមិដើម្បីទទួលបានប្រាក់កម្រៃបន្ថែម ។ ប៉ាបានលក់ឈ្មោះឲ្យអ្នកដទៃដើម្បីបើកហាងលក់ថ្នាំពេទ្យ ។ ម៉ាក់នៅផ្ទះដាំបន្លែយកទៅលក់នៅផ្សារដើម្បីជួយសម្រាលបន្ទុករបស់ប៉ា ។ នៅពេលប៉ាកំពុងធ្វើការនៅពេទ្យ ប៉ាបានរៀនបន្ថែមវគ្គខ្លីៗជាច្រើនវគ្គនៅទីក្រុងភ្នំពេញ ។

នៅមុនថ្ងៃជម្លៀសក្នុងឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញជ្រួលច្របល់ជាខ្លាំង ។ សូរកាំភ្លើងនិងគ្រាប់ផ្លោងលាន់ឮមិនលស់ពេលធ្វើឲ្យរំខានដល់ការសម្រាន្តពេលយប់របស់ប៉ា ។ កាលនោះផ្ទះខ្ញុំនៅម្តុំតាខ្មៅ ។ ជារៀងរាល់យប់ ពេលបាយល្ងាចហើយប៉ាមកសម្រាន្តនៅផ្ទះប្អូនស្រីពៅរបស់ខ្ញុំនៅឯទីក្រុងភ្នំពេញ ចំណែកម៉ាក់និងបងប្អូនខ្ញុំផ្សេងទៀតនៅផ្ទះឯតាខ្មៅ ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ប៉ាមិនបានទៅជួបជុំម៉ាក់និងបងប្អូនខ្ញុំទេ ពីព្រោះថ្ងៃនោះទីក្រុងភ្នំពេញមានការជ្រួលច្របល់ខ្លាំងជាងសព្វមួយដង ។ ព្រឹកថ្ងៃទី១៧ ប៉ាប្រញាប់ចាកចេញពីភ្នំពេញទៅតាខ្មៅ ប៉ុន្តែគាត់ទៅមិនទាន់ ដោយសារចរាចរណ៍កកស្ទះខ្លាំង ។

ពេលដែលប៉ាទៅដល់ផ្ទះ ម៉ាក់និងបងប្អូនខ្ញុំទាំងអស់បានចាកចេញពីផ្ទះផុតទៅហើយ ។ ប៉ានិងប្អូនពៅបានស៊ើបសួរដំណឹងអំពីម៉ាក់ ហើយបានទទួលដំណឹងថាម៉ាក់បាននាំកូនៗធ្វើដំណើរទៅស្រុកកំណើតនៅភូមិព្រែកស្ពាយ ស្រុកស្អាង ខេត្តកណ្តាល ។ ប៉ានិងប្អូនពៅបានទៅជួបម៉ាក់និង បងប្អូនខ្ញុំនៅទីនោះ ។ ប៉ាម៉ាក់ខ្ញុំមានគំនិតថា បើក្រុមគ្រួសារខ្ញុំរស់នៅភូមិព្រែកស្ពាយនោះ យើងពិតជាមិនបានសេចក្តីសុខឡើយ ពីព្រោះអ្នកភូមិភាគច្រើនបានដឹងថាក្រុមគ្រួសារខ្ញុំមានជីវភាពធូរធារ ហើយអ្នកទាំងនោះមានការគុំកួននិងស្អប់ប្រជាជនថ្មី ។ ដូច្នេះអ្នកនៅទីនោះប្រាកដជាធ្វើបាបក្រុមគ្រួសារខ្ញុំជាមិនខាន ។

ក្រោយមក ក្រុមគ្រួសារខ្ញុំធ្វើដំណើរទៅភូមិភាគពាយ័ព្យជាមួយប្រជាជនជម្លៀសជាច្រើនគ្រួសារទៀត ។ យើងចេញដំណើរតាមកប៉ាល់នៅពេលយប់ ។ ព្រលឹមឡើងកប៉ាល់ទៅដល់ខេត្តកំពង់ឆ្នាំង ។ អង្គការប្រាប់ប្រជាជនជម្លៀសឲ្យឡើងគោកហើយស្នាក់នៅទីនោះរយៈពេល១អាទិត្យ ។ បន្ទាប់មកមានរថយន្តមកដឹកប្រជាជនបន្តទៅខេត្តពោធិសាត់និងបាត់ដំបង ។ ឡានឈប់នៅស្រុកមោងឫស្សីមួយយប់ដើម្បីរង់ចាំអង្គការបែងចែកឲ្យរស់នៅតាមភូមិ ។ ខ្ញុំនិងបងប្អូនខ្ញុំចេះតែសួរប៉ាម៉ាក់ខ្ញុំថា «តើពេលណាទើបយើងបានត្រឡប់ទៅផ្ទះវិញ?» ឪពុកម្តាយខ្ញុំឆ្លើយថា «យើងគ្មានសង្ឃឹមថាបានត្រឡប់ទៅផ្ទះវិញទេ» ។ ក្រុមគ្រួសារខ្ញុំបានទៅរស់នៅភូមិសាយ ។ នៅតាមផ្លូវចូលទៅភូមិខ្ញុំឃើញមានព្រៃឫស្សី ផ្នូរខ្មោច និងវត្តបែកបាក់មួយ ។ ភូមិនោះគឺជាភូមិដែលមនុស្សបោះបង់ចោល ។ ក្រុមគ្រួសារខ្ញុំស្នាក់នៅក្នុងវត្តបែកបាក់នោះជាបណ្តោះអាសន្នសិនទម្រាំតែប៉ាកាប់ឫស្សីនិងស្បូវមកធ្វើកូនខ្ទមបានរស់នៅនិងរង់ចាំទទួលបញ្ជាការងារពីអង្គការ ។ ប្រជាជននៅក្នុងភូមិនោះសុទ្ធតែជាប្រជាជនថ្មី មានប្រជាជនមូលដ្ឋានតែមួយគ្រួសារគត់គឺប្រធានភូមិ ។

ដំបូងឡើយ ការរស់នៅនឹងការហូបចុកមិនទាន់តឹងតែងនៅឡើយទេ ។ ក្រោយមកអង្គការដកហូតស្បៀងអាហារនិងរបស់របរប្រើប្រាស់យកទៅដាក់រួមនៅក្នុងសហករណ៍ ហើយបង្ខំឲ្យប្រជាជនធ្វើការនៅតាមការដ្ឋានដែលស្ថិតនៅឆ្ងាយពីភូមិនិងហូបបាយរួម ។ ប៉ាត្រូវធ្វើការងារជាច្រើនគ្មានពេលសម្រាក

គ្រប់គ្រាន់និងបានរបបអាហារតិចតួចបំផុត ។ ប៉ាមានវ័យចំណាស់ គាត់មិនអាចទ្រាំទ្រនឹងការងារទាំងនោះបានឡើយ ។ យប់មួយដោយឃ្លានខ្លាំងពេក ប៉ាបានទៅលួចបេះស្វាយទុំនៅក្រោយបន្ទាយកងទ័ពខ្មែរក្រហមហូប ។ ខ្ញុំព្យាយាមហាមឃាត់ប៉ាដែរ ប៉ុន្តែគាត់មិនព្រមស្តាប់ខ្ញុំ ។ ពេលគាត់ត្រឡប់មកវិញ គាត់យកស្វាយទុំប្រមាណ១០ផ្លែមកផ្ញើកូនៗ ។ សំណាងល្អណាស់ដែលកម្មាភិបាលភូមិចាប់ប៉ាមិនបាន ម្យ៉ាងទៀត យប់នោះមេឃងងឹតហើយមានភ្លៀងខ្លាំងទៀតផង ។ បងប្អូនប្រុសស្រីរបស់ខ្ញុំ ៥នាក់ត្រូវអង្គការបញ្ជូនទៅធ្វើការនៅព្រំដែនកម្ពុជា-ថៃ ហើយស្លាប់ជាបន្តបន្ទាប់ដោយសារតែកង្វះអាហារ ។

ចាប់ពីឆ្នាំ១៩៧៦មក អង្គការឲ្យប្រជាជនហូបតែបបររាវទាំងព្រឹកទាំងល្ងាច ។ ប្រជាជនចាប់ផ្តើមស្លាប់ជាបន្តបន្ទាប់ ។ ឆ្នាំ១៩៧៧ ការហូបចុកកាន់តែខ្វះខាតខ្លាំងឡើងៗ ។ មុនពេលប៉ាស្លាប់ អង្គការបានផ្តាច់របបអង្ករអស់រយៈពេល៣ថ្ងៃ ។ ប្រជាជនអាចរកបន្លែបានតែបន្តិចបន្តួចសម្រាប់ហូប ។ គ្រឿងអលង្ការដែលម៉ាក់យកទៅទាំងប៉ុន្មាន ម៉ាក់យកដូរជាអង្ករ ត្រី ប្រហុក ដូកអស់ហើយ ។ ម៉ាក់គ្មានដល់អ្វីសម្រាប់ដូរទៀតឡើយ ។ ប៉ារបស់ខ្ញុំស្លាប់ដោយគ្មានអាហារបរិភោគ ។ សាកសពរបស់គាត់ត្រូវយកទៅកប់នៅព្រៃស្បូវខាងក្រោយភូមិ ។ នៅពេលកប់សាកសពប៉ា បងស្រីទី៤បានសរសេរឈ្មោះប៉ាហើយដាក់នៅក្នុងដបមួយបិទគម្របយ៉ាងជិតយកទៅកប់នៅក្នុងរណ្តៅជាមួយប៉ា ។ បងខ្ញុំធ្វើបែបនេះព្រោះគាត់គិតថាថ្ងៃណាមួយបងប្អូនរបស់ខ្ញុំណាម្នាក់ដែលនៅរស់អាចទៅគាស់យកឆ្អឹងរបស់ប៉ាមកធ្វើបុណ្យឲ្យបានសមរម្យ ។ ១ខែក្រោយមក ម៉ាក់ស្លាប់ដោយសារខូចចិត្តនឹងមរណភាពរបស់ប៉ានិងបងប្អូនខ្ញុំ ។ បងប្អូនរបស់ខ្ញុំក៏ស្លាប់ជាបន្តបន្ទាប់ទៀតដោយសារអត់អាហារនិងមានជំងឺគ្មានថ្នាំព្យាបាល ។

ក្រោយពីបងប្អូនខ្ញុំស្លាប់អស់ អង្គការបានផ្លាស់ខ្ញុំទៅធ្វើការនៅការដ្ឋានជាច្រើនដូចជា ការដ្ឋានហប់ ភ្នំធិបដេ សង់ទីញ៉ាន និងការដ្ឋានជាច្រើនទៀតនៅជិតព្រំដែនប្រទេសថៃ ។ នៅទីនោះខ្ញុំមានជំងឺជាទម្ងន់គ្មានអ្នកថែរក្សា ។ ខ្ញុំរង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ប៉ុន្តែមានអ្នកជិតខាងម្នាក់ជួយយកអាសាខ្ញុំ ដឹកខ្ញុំតាមរទេះគោទៅមន្ទីរពេទ្យស្រុក ។ ខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យស្រុករហូតបានជាសះស្បើយទើបត្រឡប់មកធ្វើការវិញ ។ អង្គការចាត់តាំងឲ្យខ្ញុំជីកប្រឡាយ លើកទំនប់ និងស្ទូងស្រូវ ទាំងយប់ទាំងថ្ងៃ ។ យប់ខ្លះខ្ញុំមិនបានដេកទេ ពីព្រោះគ្មានដីរាបស្មើដែលអាចដេកបានស្រួល ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានឮដំណឹងខ្សឹបខ្សៀវពីប្រជាជនដែលមានវិទ្យុស្តាប់ថា កងទ័ពវៀតណាមកំពុងតែវាយប្រយុទ្ធដើម្បីរំដោះប្រទេសកម្ពុជា ។ ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហមមានការប្រុងប្រយ័ត្នកាន់តែខ្លាំងឡើងៗ ។ អង្គការចាត់តាំងឲ្យក្រុមកងចល័តខ្ញុំជីកដំបូកដើម្បីរកប់ស្រូវ ត្រីងៀត និងអំបិល ។ ក្រុមមុនៗដែលធ្វើការងារនេះត្រូវខ្មែរក្រហមបាញ់សម្លាប់ចោលទាំងអស់បន្ទាប់ពីបញ្ចប់ការងារ ចំណែកក្រុមរបស់ខ្ញុំ នៅពេលដែលបញ្ចប់ការងារនេះហើយនាំគ្នារត់បែកខ្ញែកគ្នាអស់ ។ កងទ័ពវៀតណាមក៏វាយរំដោះបាន ។

ខ្ញុំធ្វើដំណើរកាត់ព្រៃជាច្រើនថ្ងៃទើបមកដល់ខេត្តកំពង់ឆ្នាំង ។ ខ្ញុំសុំដោយសាររថយន្តដឹកកងទ័ពវៀតណាមមកដល់កំពង់ចម្លងព្រែកក្តាម ។ ខ្ញុំបានជួបម្តាយមីងពីរនាក់នៅស្រុកពញាឮ ក៏ស្នាក់នៅទីនោះជាមួយគាត់អស់រយៈពេលជិតមួយឆ្នាំទើបធ្វើដំណើរមកតាខ្មៅដើម្បីមើលផ្ទះដែលខ្ញុំធ្លាប់រស់នៅ ហើយបានជួបបងស្រីបង្កើតខ្ញុំម្នាក់ដែលបែកគ្នាពេលចេញពីព្រៃ ។

រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំនិងបងស្រីខ្ញុំនៅតែមិនអាចទៅយកឆ្អឹងរបស់ប៉ានៅឡើយ ពីព្រោះផ្នូរនៅទីនោះច្រើនពេក យើងមិនដឹងថាផ្នូរមួយណាជាផ្នូររបស់ប៉ា ។ ម្យ៉ាងទៀតពេលវេលាកន្លងទៅយូរឆ្នាំកន្លែងនោះមានការប្រែប្រួលច្រើនណាស់ ។

ខ្ញុំនៅតែមិនអាចបំភ្លេចរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមបាន ។ ថ្វីត្បិតតែក្រុមគ្រួសាររបស់ខ្ញុំមិនបានស្លាប់ដោយសារការវាយនឹងដំបង ប៉ុន្តែស្លាប់ដោយសារការបង្អត់អាហារ ឈឺគ្មានថ្នាំសម្រាប់ព្យាបាលគ្រប់គ្រាន់ និងការធ្វើបាបផ្លូវចិត្តដោយពង្រាត់ឲ្យរស់នៅបែកគ្នាហើយបង្ខំឲ្យធ្វើការងារហួសកម្លាំង ។ ទាំងនេះជាអំពើឃោរឃៅដែលខ្មែរក្រហមប្រព្រឹត្តមកលើក្រុមគ្រួសារខ្ញុំក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ ។ ខ្ញុំចង់បានតុលាការមួយដ៏ត្រឹមត្រូវដើម្បីរកយុត្តិធម៌ឲ្យក្រុមគ្រួសារខ្ញុំ ។ ◆◆◆

## ខៀវ នឿន អតីតទាហានលន់នល់

ខៀវ នឿន ត្រូវខ្មែរក្រហមសម្លាប់នៅខេត្តបាត់ដំបង ចំណែក ខៀវ នឹម អតីតយុទ្ធជនកាន់គេអូរបស់ខ្មែរក្រហម បាត់ខ្លួននៅក្នុងសមរភូមិ ។ ក្រោយពេលរបបខ្មែរក្រហមត្រូវបញ្ចប់ ខៀវ ណេង បានទៅរកហោរាឲ្យទស្សន៍ទាយអំពីជោគវាសនាបងប្រុសម្នាក់ឈ្មោះ ខៀវ នឹម ដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម ។ គ្រូទាយនោះបាននិយាយប្រាប់ថា នឹម មិនត្រឡប់មកវិញទេ ។ ចាប់តាំងពីពេលនោះមក ខៀវ ណេង អស់សង្ឃឹមក្នុងការទន្ទឹងរង់ចាំបងប្រុសរបស់គាត់ ។ គាត់យល់ឃើញថា នឹម ពិតជាស្លាប់ហើយ ។ រហូតមកដល់សព្វថ្ងៃ ណេង នៅសល់តែរូបថតរបស់ នឿន និង នឹម មួយចំនួនដែលគាត់ខំរក្សាទុក ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ម្តាយរបស់ ខៀវ ណេង ឈ្មោះ ឈុន ទូច ដាក់តាំងរូបថតទាំងនោះនៅក្នុងផ្ទះ ។ ពេលដែលឈ្លបខ្មែរក្រហមមកឆែកឆេរផ្ទះរបស់គាត់បានឃើញរូបថតទាំងនោះ ឈ្លបបានចោទប្រកាន់ថាក្រុមគ្រួសារគាត់នៅស្រលាញ់របបចក្រពត្តិ ។ ឈ្លបបានបញ្ជាឲ្យ ទូច យករូបថតទាំងនោះទុក ព្រមទាំងគំរាមយកគាត់ទៅសម្លាប់ បើនៅតែចចេសដាក់តាំងទៀត ប៉ុន្តែ ទូច បានប្រកែកតវ៉ាមិនព្រមយករូបថតនោះទុកឡើយ ហើយប្រាប់ទៅឈ្លបវិញថាគាត់មិនខ្លាចស្លាប់ទេ ។ ខៀវ ណេង រំឭកថា ម្តាយរបស់គាត់ធ្លាប់លេបថ្នាំពុលសម្លាប់ខ្លួនពេលដែលអង្គការដកហូតយកអស់ទ្រព្យសម្បត្តិរបស់គាត់ ហើយបំបែកកូនរបស់គាត់ទៀត ប៉ុន្តែដោយបានសាច់ញាតិជួយសង្គ្រោះទាន់ពេលវេលា ទើបម្តាយរបស់គាត់រួចផុតពីសេចក្តីស្លាប់ ។ ខៀវ ណេង រំឭករឿងរ៉ាវអំពី នឿន និង នឹម ថា ៖


ខៀវ នឿន

បងនឿន រៀននៅសាលាសិរីមង្គលក្នុងវត្តដំរីស ។ គាត់រៀនពូកែណាស់ ។ គាត់រៀននៅដល់ថ្នាក់ឌីប្លូម ។ ក្រោយពេលរដ្ឋប្រហារឆ្នាំ១៩៧០ នៅក្នុងភូមិនិងនៅក្នុងសាលារៀនមានភាពជ្រួលច្របល់ បងនឿន បានស្ម័គ្រចិត្តចូលធ្វើកុម្មង់ដូដើម្បីយាមសាលានៅពេលយប់ ពេលថ្ងៃគាត់រៀនធម្មតា ។ ក្រុមរបស់គាត់មានសមាជិក៣០នាក់ ។ គាត់ទទួលបានប្រាក់ឧបត្ថម្ភ ៥០០រៀល ក្នុង១ខែ ។

នៅឆ្នាំ១៩៧២ ដោយសារមានគ្រាប់ផ្លោងចូលភូមិខ្លាំង បងនឿន ឈប់រៀនហើយផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ ។ គាត់បានស្ម័គ្រចិត្តធ្វើទាហានលន់នល់ ។ ក្រោយមកគាត់ត្រូវបញ្ជូនទៅហ្វឹកហាត់ទាហាននៅខេត្តឡុងហាយ ប្រទេសវៀតណាម រយៈពេល៣ខែ ។ ពេលគាត់មកលេងផ្ទះម្តង១ គាត់យករបស់របរមកផ្ញើអ្នកផ្ទះ មានដូចជា ចង្ក្រាន សម្លៀកបំពាក់និងរបស់របរជាច្រើនទៀត នៅក្នុងនោះក៏មានយករូបថតរបស់គាត់ដែលស្លៀកសម្លៀកបំពាក់ឯកសណ្ឋានទាហាន ប៉ុន្តែខ្ញុំហែករូបទាំងនោះចោលអស់ហើយ ព្រោះខ្លាចរដ្ឋអំណាចភូមិឃុំរករឿង ។ គាត់មកលេងផ្ទះម្តង១ បានតែ២-៣ថ្ងៃប៉ុណ្ណោះ ក៏ត្រឡប់ទៅវិញ ។ បន្ទាប់មកគាត់បានផ្លាស់ទៅធ្វើការនៅខេត្តបាត់ដំបងជាមួយបងប្អូនជីដូនមួយរបស់ខ្ញុំ ២-៣នាក់ ។ នៅទីនោះគាត់ធ្វើការខាងទាហានអាកាសចរទទួលតំណែងជានាយទាហានស័ក្តិ១ ហើយរៀបការជាមួយនារីម្នាក់ឈ្មោះ រឿន ។ បងរឿន គឺជាអ្នកស្រុកស្វាយស៊ីសុផុននិងជាគ្រូបង្រៀន ។ ក្រុមគ្រួសារខ្ញុំនៅទីនេះមិនបានទទួលដំណឹងអំពីមង្គលការរបស់គាត់ទេ ព្រោះទំនាក់ទំនងត្រូវកាត់ផ្តាច់ដោយសារសង្គ្រាម ។ ខ្ញុំបានដឹងដំណឹងអំពីបងនឿន តាមរយៈបងប្អូនជីដូនមួយ២-៣នាក់ដែលធ្វើការនៅទីនោះដែរ ។

នៅឆ្នាំ១៩៧៥ បងនឿន និងប្រពន្ធគាត់ ត្រូវខ្មែរក្រហមជម្លៀសទៅស្វាយស៊ីសុផុន ។ អង្គការចាត់តាំងឲ្យ បងនឿន ធ្វើការខាងភ័ស្តុភារ ដឹកជញ្ជូនសម្ភារដាក់សហករណ៍ ។ ថ្ងៃមួយ បងនឿន បានធ្វើឲ្យបាក់រទេះដឹកសម្ភារ ។ ប្រធានកងប្តឹងអង្គការអំពីរឿងនេះ ហើយរាយការណ៍បន្ថែមថា បងនឿន ជាអតីត



ខៀវ ធឿន និងមិត្តភក្តិកាលនៅរៀន

ទាហានពាក់សក្តិ១ ។ អង្គការចាប់ បងធឿន យកទៅសម្លាប់ ។ បងវឿន ចេះតែរង់ចាំមើលផ្លូវប្តីគាត់ត្រឡប់មកវិញ ប៉ុន្តែចាំបាត់ៗមិនបានទទួលដំណឹងអ្វីសោះ ។ បងវឿន ជឿជាក់ថាប្តីរបស់គាត់ពិតជាត្រូវអង្គការសម្លាប់ហើយ ។ បន្ទាប់ពីសម្លាប់ បងធឿន រួចហើយ ប្រធានកងរូបនោះបានស្នើសុំរៀបការជាមួយ បងវឿន ហើយគំរាម បងវឿន ថា បើគាត់មិនព្រមរៀបការជាមួយទេ ខ្លួនគាត់និងក្រុមគ្រួសារនឹងត្រូវអង្គការយកទៅសម្លាប់ជាបន្តបន្ទាប់ទៀត ។ ដោយការភ័យខ្លាច បងវឿន ក៏យល់ព្រម ។ បងវឿន មានកូនប្រុសម្នាក់ជាមួយ បងធឿន រួចទៅហើយ ។ កូននោះអាយុ២ឆ្នាំ ។

ក្រោយពេលរបបខ្មែរក្រហមដួលរលំ បងវឿន លែងលះជាមួយប្តីក្រោយ ។ គាត់បានផ្ញើរូបថតមកឲ្យក្រុមគ្រួសារខ្ញុំ ហើយទាក់ទងសុំបុត្រមកជាហូរហែ ។ កាលនោះ បងវឿន លក់ខោអាវនៅខេត្តបាត់ដំបង ។ ក្រុមគ្រួសារខ្ញុំក៏បានស្គាល់ បងវឿន តាមរយៈរូបថតដែលគាត់ផ្ញើមក ។ បន្ទាប់មកគាត់មកលេងនៅស្រុកកំណើតរបស់ខ្ញុំនៅភូមិពាម ស្រុកមុខកំពូល ខេត្តកណ្តាល ។

នេះគឺជា បងធីម បងប្រុសទី២របស់ខ្ញុំ ។ ពេលរៀនចប់វិទ្យាល័យនៅជំនាន់លន់នល់គាត់បានទៅបន្តការសិក្សាផ្នែកវេជ្ជសាស្ត្រនៅទីក្រុងភ្នំពេញហើយស្នាក់នៅបឹងទំពុន ។ នៅថ្ងៃជិតចូលឆ្នាំ ខែមេសា ឆ្នាំ១៩៧៥ បងធីម បានមកលេង ពុកម៉ែខ្ញុំនៅភូមិពាម ។ ពេលនោះគាត់មិនទាន់រៀនចប់នៅឡើយទេ ។ មកលេងបាន១ថ្ងៃ គាត់បម្រុងវិលត្រឡប់ទៅភ្នំពេញវិញ ប៉ុន្តែទាហានខ្មែរក្រហមបានឃាត់ខ្លួនគាត់មិនឲ្យទៅ ។ គាត់បន្តរស់នៅជាមួយក្រុមគ្រួសារខ្ញុំនៅក្នុងភូមិ ។ ១ឆ្នាំក្រោយមក អង្គការបានជ្រើសរើស បងធីម ឲ្យធ្វើជាឈ្លបភូមិ ។ ក្រោយមកមិត្តភក្តិម្នាក់របស់ បងធីម បានរាយការណ៍ប្រាប់អង្គការថា បងធីម ធ្លាប់រៀនសូត្របានជ្រៅជ្រះ ហើយចេះទាំងភាសាបារាំងនិងអង់គ្លេសផង អង្គការក៏ចាត់តាំងឲ្យ បងធីម ធ្វើទាហាន កាន់ខាងគេអូ ។ ពេលមួយអង្គការបានកុហក បងធីម ថាឲ្យគាត់ទៅប្រូតស្រូវឆ្ងាយពីភូមិ ។ ចាប់តាំងពី បងធីម ចេញទៅ យើងមិនដែលឃើញគាត់ត្រឡប់មកផ្ទះវិញទេ ។

ពុកម៉ែនិងបងប្អូនខ្ញុំចេះតែរង់ចាំមើលផ្លូវ បងធីម ប៉ុន្តែការរង់ចាំចេះតែបន្ទាយពេលយូរទៅៗ ។ បុរសម្នាក់ដែលចេញទៅ

ជាមួយ បងនឹម បានអះអាងថា អង្គការមិនបានបញ្ជូន បងនឹម ទៅច្រូតស្រូវទេ គឺបញ្ជូនទៅច្បាំងនៅព្រំដែនវៀតណាម ។ ម្នាក់នោះបានបញ្ជាក់ទៀតថា គាត់បានជួប បងនឹម នៅពេលរត់គេចពីគ្រាប់កាំភ្លើង ។ ពេលនោះ បងនឹម ស្ពាយ គេអូមួយធំនៅជាប់នឹងខ្លួនហើយមានអូសខ្មែរទៀតផង ។ គាត់បបួល បងនឹម រត់មកផ្ទះដែរ ប៉ុន្តែ បងនឹម ប្រាប់ថានឹងមកតាមក្រោយ ហើយក៏រត់បែកគ្នាទៅ ។ បុរសនោះត្រូវអង្គការចាប់យកទៅសម្លាប់ចោលពេលគាត់ត្រឡប់មកភូមិវិញ ។ ពេលនោះសភាពការណ៍នៅក្នុងភូមិខ្ញុំមានការជ្រួលច្របល់ខ្លាំងដោយខ្មែរក្រហមចោទប្រកាន់ថាប្រជាជនខាងភូមិភាគបូព៌ាក្បត់ ។ ចាប់តាំងពីពេលនោះមកក្រុមគ្រួសារខ្ញុំមិនដែលបានទទួលដំណឹងពី បងនឹម ទៀតទេ ។

រហូតមកដល់សព្វថ្ងៃ ខ្ញុំគ្មានសង្ឃឹមថា បងនឹម នៅរស់ទេ ។ ប្រសិនបើគាត់នៅរស់ គាត់ពិតជាវិលមករកក្រុមគ្រួសារខ្ញុំវិញហើយ ។ ក្នុងចំណោមបងប្អូនខ្ញុំ១០នាក់ នៅរស់តែ៧នាក់ប៉ុណ្ណោះ ។ ◆◆◆

## ម៉េង ឆេង ហៅ គា សុធី
## អតីតអ្នកត្រួតពិនិត្យឃ្លាំងទំនិញនៅអាកាសចរស៊ីវិល

នៅចំណោមបងប្អូនទាំង៨នាក់ របស់ ម៉េង ឆេង ៥នាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមដោយសារកង្វះអាហារនិងទារុណកម្ម ។ ភាគច្រើននៃអ្នកដែលស្លាប់ជាអតីតបុគ្គលិកនៅអាកាសចរស៊ីវិលកម្ពុជានិងធ្លាប់មានជីវភាពធូរធារ ។ ម៉េង ឆេង បាននិយាយថា ÷



ឆេង ម៉េង ថតឆ្នាំ១៩៧១ អាយុ២៧ឆ្នាំ

ឪពុករបស់ខ្ញុំស្លាប់តាំងពីសង្គមរាស្ត្រនិយម ដោយសារជំងឺចាស់ជរា ។ ខ្ញុំជាមនុស្សមានសំណាងដែលបានរួចផុតពីសេចក្តីស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំបានកុហកអង្គការថាខ្ញុំគឺជាអ្នករត់ម៉ឺក ។ បើខ្ញុំប្រាប់តាមត្រង់នោះ ខ្ញុំពិតជាត្រូវស្លាប់ទាំងគ្រួសារហើយ ។ ឈ្មោះដើមរបស់ខ្ញុំគឺ ម៉េង ឆេង ។ នៅសម័យរដ្ឋកម្ពុជាពេលខ្ញុំដាក់ពាក្យចូលធ្វើការ ខ្ញុំបានប្តូរឈ្មោះទៅជា គា សុធី វិញ ពីព្រោះ ឆេង គឺជាឈ្មោះចិន ខ្ញុំលំបាកក្នុងការរកការងារធ្វើ ។

ស្រុកកំណើតរបស់ខ្ញុំគឺស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ខ្ញុំរៀននៅសាលាបឋមសិក្សាស្វាយរមៀត ។ បន្ទាប់មក ខ្ញុំមករៀននៅសាលាវត្តជីរសនិងសាលាព្រែកតាមាក់ ។ នៅឆ្នាំ១៩៦២ ខ្ញុំមកបន្តការសិក្សានៅសាលាយុគន្ធរនៅទីក្រុងភ្នំពេញ ។ ខ្ញុំស្នាក់នៅផ្ទះជួលជាមួយបងស្រីឈ្មោះ គា យូហាក់ នៅម្តុំបឹងកេងកង១ ។ ក្រោយពីខ្ញុំប្រឡងបាក់អងជាប់ ខ្ញុំបានផ្លាស់មកនៅជាមួយបង គា ឈុន ហើយគាត់បានបណ្តុះបណ្តាលខ្ញុំនិងយកខ្ញុំឲ្យចូលធ្វើការជាមួយគាត់ ។

ឆ្នាំ១៩៧០ ខ្ញុំបានរៀបការជាមួយនារីម្នាក់ឈ្មោះ តាំង សុដានី ជាអ្នកស្រុកកំពង់ថ្ម ខេត្តកំពង់ធំ ។ ប្រពន្ធខ្ញុំជាអ្នកលក់គ្រឿងទេស ។ ផ្ទះរបស់ខ្ញុំនៅក្បែរពោធិចិនតុង ។

ខ្ញុំធ្វើការជាមួយ បងឈុន នៅអាកាសចរស៊ីវិលកម្ពុជានៅឆ្នាំ១៩៧១ ។ ខ្ញុំជាអ្នកត្រួតពិនិត្យទំនិញចេញ-ចូល និងត្រួតពិនិត្យចំនួនមនុស្សពេលដែលយន្តហោះចេញដំណើរទៅតាមខេត្តម្តងៗ ។ ខ្ញុំប្រឹងរៀនភាសាបារាំងនិងអង់គ្លេសបន្ថែមទៀតក្រៅម៉ោងធ្វើការដើម្បីងាយស្រួលធ្វើការ ព្រោះអ្នកបើកយន្តហោះនៅទីនោះភាគច្រើនជាជនជាតិឡាវ ។ យន្តហោះហោះហើរពីភ្នំពេញទៅខេត្តកោះកុង កំពត បាត់ដំបង សៀមរាប និងស្វាយរៀងអាចផ្ទុកមនុស្សបានពី៣៥នាក់ទៅ៦០នាក់ ។

ចាប់ពីឆ្នាំ១៩៧៣មក ប្រជាជនភាគច្រើនមិនអាចធ្វើដំណើរតាមផ្លូវគោកឬផ្លូវទឹកបានទេ ពីព្រោះមានការប្រយុទ្ធគ្នាជាញឹកញាប់នៅតាមផ្លូវ ដែលអាចបង្កឲ្យមានគ្រោះថ្នាក់ ។ ពេលខ្លះប្រយុទ្ធគ្នារហូតវាយផ្តាច់ផ្លូវក៏មាន ។ ដូច្នេះប្រជាជនធ្វើដំណើរទៅខេត្តតាមយន្តហោះ ។

នៅម៉ោង៨ព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំទៅជាមួយយន្តហោះមួយដែលចុះចតនៅខេត្តកំពង់ឆ្នាំងដើម្បីដឹក

អីវ៉ាន់មកទីក្រុងភ្នំពេញ ។ ពេលដែលយន្តហោះបម្រុងនឹងចេញដំណើរមកភ្នំពេញ ស្រាប់តែអស់សាំង ។ ក្រោយពេលចាក់សាំងហើយអ្នកគ្រប់គ្រងនៅព្រលានមិនអនុញ្ញាតឲ្យយន្តហោះវិលមកទីក្រុងភ្នំពេញទេ ពីព្រោះភ្នំពេញមានភាពជ្រួលច្របល់ខ្លាំង ។ ពេលនោះអ្នកបើកយន្តហោះជនជាតិឡាវនិយាយថា គាត់នឹងត្រឡប់ទៅប្រទេសឡាវវិញ ហើយថែមទាំងបបួលខ្ញុំទៅជាមួយផង ប៉ុន្តែខ្ញុំមិនទៅ ។ ខ្ញុំសម្រេចចិត្តធ្វើដំណើរទៅស្រុកកំណើតរបស់ខ្ញុំ ។ នៅមុនថ្ងៃទី១៧ ខែមេសា ខ្ញុំបានដឹងថាសភាពការណ៍មិនសូវល្អ ខ្ញុំបានពិភាក្សាជាមួយប្រពន្ធខ្ញុំថា បើមានរឿងអ្វីមិនស្រួលត្រូវធ្វើដំណើរទៅស្រុកកំណើតនៅស្រុកខ្សាច់កណ្តាល ។

នៅពេលជម្លៀស ប្រពន្ធខ្ញុំពកូនប្រុសខ្ញុំដើរទៅស្រុកកំណើត ។ ដោយសារអាកាសធាតុក្តៅខ្លាំងនិងខ្វះចំណីអាហារបរិភោគ កូនខ្ញុំក៏ស្លាប់នៅតាមផ្លូវ ។ ខ្ញុំធ្វើដំណើរ១ខែកន្លះទើបមកដល់ស្រុកកំណើតហើយជួបប្រពន្ធខ្ញុំនៅទីនោះ ។ ក្រោយពេលខ្ញុំទៅដល់ទីនោះបានមួយរយៈខ្លី អង្គការជម្លៀសក្រុមគ្រួសារខ្ញុំទៅស្រុកដូនទាវ ខេត្តបាត់ដំបង ។ មុនពេលជម្លៀសអង្គការបានសួរអំពីប្រវត្តិរូបខ្ញុំពីមុនមក ។ ខ្ញុំឆ្លើយថាខ្ញុំជាអ្នករត់រ៉ឺម៉ក ។

ខ្ញុំបានធ្វើដំណើរតាមកប៉ាល់កាត់តាមគីឡូលេខ៦ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ ហើយបានមកដល់ខេត្តបាត់ដំបង ។ អង្គការបែងចែកឲ្យខ្ញុំនិងប្រពន្ធធ្វើការនៅក្នុងសហករណ៍ ។ អ្នកធ្វើការនៅទីនោះបានឲ្យថ្នាំជក់ដល់ខ្ញុំ ។ ខ្ញុំយកថ្នាំជក់ទៅដូរយកម្ហូបពីព្រោះពេលទៅដល់ភូមិខ្ញុំមិនទាន់រកអ្វីមកហូបបានទេ ។ អង្គការចាត់តាំងឲ្យខ្ញុំនៅលាយឡំចម្រុះគ្នាជាមួយប្រជាជនចាស់ ។ ប្រជាជនចាស់ធ្វើការងារតិចជាងប្រជាជនថ្មី ។ អ្នកទាំងនោះមានរបបអង្ករផ្ទាល់ខ្លួន ចំណែកប្រជាជនជម្លៀសអត់មានទេ ។ បើអង្គការឆែកឆេរឃើញអង្ករយើងពិតជាស្លាប់ហើយ ។ ប្រជាជនចាស់ហូបបាយ ចំណែកប្រជាជនថ្មីហូបបបរ ។ ខ្ញុំបានហូបបាយតែពេលណាមានពិធីបុណ្យទាន ។ អង្គការបានបំបែកខ្ញុំនិងប្រពន្ធមិនឲ្យរស់នៅជាមួយគ្នាទេ ។ ខ្ញុំអាចជួបប្រពន្ធខ្ញុំតែពេលមានប្រជុំនិងបុណ្យទានប៉ុណ្ណោះ ។

អេន ជាប្រធានសហករណ៍ ជាមនុស្សកាចសាហាវណាស់ ។ ពេលខ្លះ អេន បានចាប់កូនអ្នកស្រុកយកទៅរំលោភ ជួនកាល



ថៅង សួត ម្តាយរបស់ ឆេង ម៉េង

សម្លាប់មនុស្សពុះទ្រូងយកថ្លើមមកឆាស៊ី ។ ខ្ញុំបានឃើញ អេន ចាប់កូនក្រមុំពេទ្យម្នាក់ធ្វើបាបហើយសម្លាប់ចោល ។ អេន បានសហការជាមួយឈួបដើម្បីធ្វើកិច្ចការនេះ ។ ពេលឆាថ្លើមម្តងៗ ភ្នែកអ្នកទាំងនោះឡើងក្រហម ។

មានពេលមួយខ្ញុំស្ទើរតែបាត់បង់ជីវិតដោយសារអ្នកមូលដ្ឋានរាយការណ៍ទៅថ្នាក់លើថាខ្ញុំទម្រន់ការងារ ។ ឈួបបានយកកន្សែងឧបខ្ញុំទៅកាប់ព្រៃរនាម ។ អ្នកភូមិប្រាប់ខ្ញុំថា ឈួបយកទៅគឺអាចស្លាប់អាចរស់ ។ ខ្ញុំបានផ្តាំផ្ញើនឹងប្រពន្ធខ្ញុំថា បើមានឱកាសខ្ញុំនឹងរត់ ។ ឈួបនោះមានកាំភ្លើង ចំណែកខ្ញុំមានតែកាំបិតមួយ ។ ពេលខ្ញុំទៅដល់ព្រៃរនាម ឈួបបានបញ្ជាឲ្យខ្ញុំកាប់ឆ្ការព្រៃដើម្បីយកដីធ្វើស្រែ ។ នៅទីនោះសម្បូរត្រីណាស់ ខ្ញុំអាចចាប់ដោយដៃទទេ ។ ខ្ញុំធ្វើការនៅទីនោះបានរយៈពេល៣ខែ អង្គការក៏បញ្ជូនខ្ញុំទៅកាប់ឫស្សីនៅស្រុកបវេល ។

ខែមករា ឆ្នាំ១៩៧៩ មេកងបានហៅប្រជាជនទៅប្រជុំហើយនិយាយថា "ស្រុកយើងជិតសម្បូរសប្បាយវិញហើយ សូមមិត្តកុំប្រកែកប្រកាន់អី ខ្ញុំមិនបាននៅទេ ខ្ញុំត្រូវទៅធ្វើការនៅកន្លែងផ្សេងហើយ" ។ ខែមករា ឆ្នាំ១៩៧៩ ស្គរកាំភ្លើងលាន់ខ្ទរពេញនៅខេត្តបាត់ដំបង សន្ធឹកឡានខ្មែរក្រហមបើករត់លាន់រំពងព្រៃ ។ ខ្ញុំយកវិទ្យុដែលកប់លាក់ទុកនៅក្នុងដីមកលួចបើកស្តាប់ ហើយបានឮការផ្សាយថាមានខ្មែរតស៊ូមួយក្រុមកំពុងតែរំដោះប្រជាជន ។

វិទ្យុចាក់បទចម្រៀង «ទិដ្ឋាល្អុង» ។ ក្រោយមកភ្នំពេញត្រូវបានរំដោះ ។ ខ្ញុំបានធ្វើដំណើរជាមួយប្រពន្ធខ្ញុំត្រឡប់មកទីក្រុងភ្នំពេញវិញ ។ ខ្ញុំបានជួបតែបងស្រីម្នាក់និងប្អូនស្រីម្នាក់ប៉ុណ្ណោះ ។ បងប្អូនដទៃទៀតស្លាប់អស់ហើយ ។

បង គា ឈុន ក៏ស្លាប់បាត់បង់ជីវិតនៅក្នុងសម័យខ្មែរក្រហមដែរ ។ បងឈុនជាបងប្រុសទី២ ។ នៅក្នុងចំណោមបងប្អូនរបស់ខ្ញុំទាំង៨នាក់ បងឈុន បានធ្វើការងារធំជាងគេ ។ គាត់ឆ្លាតណាស់ ហើយរៀនពូកែទៀតផង ។ គាត់អាចនិយាយភាសាបរទេសបានជាច្រើនភាសា ។ គាត់បានចេញទៅរៀននៅប្រទេសជាច្រើនដូចជាប្រទេស អាល្លឺម៉ង់ អាមេរិក បារាំង អូស្ត្រាលី និងប៉ុលហ្គារី ។ បងឈុន គ្រប់គ្រងអ្នកបើកយន្តហោះទាំងអស់នៅអាកាសចរស៊ីវិល ។ បងឈុន បានជួយខ្ញុំនិងប្អូនប្រុសម្នាក់ឈ្មោះ គា ម៉េងលាង ឲ្យធ្វើជាអ្នកត្រួតពិនិត្យទំនិញនៅក្រុមហ៊ុនអាកាសចរស៊ីវិល និងជួយប្អូនស្រីខ្ញុំ២នាក់ទៀតឲ្យបម្រើការងារនៅលើយន្តហោះ ។ បងឈុន មានវីឡាមួយនៅម្តុំទួលគោក ។ ប្រពន្ធរបស់គាត់ឈ្មោះ អ៊ិន ម៉ារី ជាអតីតគ្រូបង្រៀននៅសាលាពោធិ៍ ។

នៅឆ្នាំ១៩៧៥ បងឈុន មានកូន៥នាក់ ។ ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុង បងឈុន បានធ្វើដំណើរទៅស្រុកកំណើតខាងប្រពន្ធរបស់គាត់នៅស្រុកមុខកំពូល ខេត្តកណ្តាល ។ បងឈុន បានយកឡានមួយដើម្បីដឹករបស់របរខ្លះ ប៉ុន្តែគាត់ទុកចោលនៅម្តុំព្រែកព្នៅ ព្រោះគាត់មិនអាចយកឡានឆ្លងទឹកបាន ។ នៅឯស្រុកកំណើត អ្នកភូមិស្គាល់ក្រុមគ្រួសាររបស់ បងឈុន ច្បាស់ ពីព្រោះឪពុកក្មេករបស់គាត់ក៏ធ្លាប់ជាគ្រូបង្រៀនដែរ ។ ពេលនោះខ្ញុំនៅខាងព្រែកតាមាក់ ហើយគាត់នៅខាងមុខកំពូល យើងនៅត្រើយម្ខាងម្នាក់នៃទន្លេ ។ ប្រពន្ធខ្ញុំបានបបួលក្រុម គ្រួសារ បងឈុន មករស់នៅជាមួយយើងដែរប៉ុន្តែគាត់មិនព្រម ។ គាត់ត្រូវខ្មែរក្រហមជម្លៀសបន្តទៅដល់ស្រុកសង្កែ ខេត្តបាត់ដំបង ។

នៅទីនោះ មានបុរសម្នាក់ធ្លាប់ធ្វើការជាមួយគាត់ពីមុនបានរាយការណ៍ទៅថ្នាក់លើថា បងឈុន ធ្លាប់មានតំណែងស័ក្តិ៥នៅព្រលានយន្តហោះ ។ បងរបស់ខ្ញុំយល់ថា អង្គការដឹងប្រវត្តិរបស់គាត់ ហើយម្យ៉ាងទៀតគាត់មិនអាចទ្រាំទ្រនឹងការលំបាកនិងកង្វះខាតអាហារផង គាត់បានលួចរត់ទៅព្រៃនាមចំនួន២ដង ។ លើកទី១ ព្រៃនោះធំពេកគាត់រកផ្លូវចេញមិនបាន អង្គការចាប់គាត់បាន ហើយយកគាត់មកកសាងថា «ថ្ងៃក្រោយកុំលួចរត់ទៀត បើខ្វះស៊ីត្រូវប្រាប់អង្គការឲ្យបានដឹង» ។ ចាប់តាំងពីពេលនោះមក អង្គការចាត់មនុស្សតាមដាន បងឈុន ។ បងឈុន លួចរត់ជាលើកទី២ ។ ម្តងនេះអង្គការចាប់បានទៀត ហើយយកដាក់ទណ្ឌកម្មឲ្យគាត់រែកទឹកនឹងកំប៉ុងទឹកដោះគោឲ្យពេញ១ពាងក្នុងរយៈពេល១ថ្ងៃ ។ បងឈុន ធ្វើមិនបានតាមបញ្ជា ។ អង្គការបន្ថែមទម្ងន់ទណ្ឌកម្មទៀតគឺឲ្យគាត់រែកឲ្យបាន២ពាងក្នុង១ថ្ងៃ ។ បងឈុន នៅតែធ្វើមិនបាន ។ គាត់ហេវហត់អស់កម្លាំងផង ណាមួយហូបមិនឆ្អែតទៀត ។ បងឈុន ត្រូវអង្គការសម្លាប់នៅក្បែរពាងទឹក ។ ប្រពន្ធរបស់ បងឈុន ត្រូវអង្គការតាមទាន់កំពុងលួចបាយហូបនៅរោងបាយ ហើយក៏ត្រូវអង្គការចាប់យកទៅសម្លាប់ចោលដែរ ។

ក្រោយឆ្នាំ១៩៧៩ ឈ្មោះ ទ្រី ដែលនៅក្នុងកងជាមួយ បងឈុន និយាយថាកូនរបស់ បងឈុន នៅរស់៣នាក់ ។ ខ្ញុំទៅស្វែងរកឃើញក្មួយទាំងបី ហើយយកមកចិញ្ចឹម ។

នេះជារូបថតបងប្អូនខាងម្តាយខ្ញុំ ។ មីងរបស់ខ្ញុំឈ្មោះ ថៅង ស្លូត៍ មានជំងឺសរសៃប្រសាទតាំងពីសង្គមចាស់ ដែលអ្នកស្រុកតែងតែហៅថា ព្រាយក្រឡាភ្លើង ។ នៅពេលគាត់ធ្វើអ្វីមួយគាត់តែងតែស្រែក ។ អង្គការចោទប្រកាន់ថាគាត់ធ្វើពុត ក៏យកមុងរុំគាត់ហើយដុតទាំងរស់ ។

ម្តាយរបស់ខ្ញុំត្រូវជម្លៀសទៅស្រុកគងពិសី ខេត្តកំពង់ស្ពឺជាមួយបងប្រុសទី១ឈ្មោះ គា ឈាន់ ។ ក្រោយមកអង្គការជម្លៀសគាត់ទាំងពីរនាក់ទៅភូមិព្រៃផ្អាវ ខេត្តតាកែវ ។ នៅក្នុងឆ្នាំ១៩៧៨ ម្តាយខ្ញុំនិងបងប្រុសខ្ញុំបានស្លាប់បាត់បង់ជីវិតដោយសារកង្វះអាហារបរិភោគ ។

ម្តាយមីងរបស់ខ្ញុំនៅឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម បានលាក់រូបថតទាំងនោះទុក ។ ពេលនោះផ្ទះរបស់គាត់ត្រូវខ្មែរក្រហមយកធ្វើជាសហករណ៍ធំ ។ ក្រោយពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានទៅលេងផ្ទះរបស់គាត់ ។ គាត់បានប្រគល់រូបថតទាំងនេះឲ្យខ្ញុំ ។ ◆◆◆

# អ៊ុំ សៀ្បាង

## អតីតប្រធានសហករណ៍ខេត្តព្រៃវែងនៅក្នុងសង្គមរាស្ត្រនិយម

អ៊ុំ ស្បៀង ត្រូវខ្មែរក្រហមសម្លាប់ដោយសារតែបានធ្វើឲ្យងាប់គោមួយក្បាល ។ ស្បៀង បន្សល់ទុករូបថតមួយសន្លឹក នោះគឺរូបថតនៅក្នុងពិធីមង្គលការរបស់គាត់នៅស្រុកខ្សាច់កណ្តាល ខេត្តកំពង់ស្ពឺ ក្នុងឆ្នាំ១៩៧២ ។ រូបថតនោះរក្សាទុកដោយប្អូនស្រីរបស់គាត់ ឈ្មោះ អ៊ុំ សារ៉េត ។ ក្រៅពីរូបថតរបស់ អ៊ុំ ស្បៀង, សារ៉េត មានរូបថតមួយសន្លឹកទៀត គឺជារូបថតឪពុករបស់ដែលថតក្នុងឆ្នាំ១៩៧៣ ។ អ៊ុំ សារ៉េត រៀបរាប់អំពីក្រុមគ្រួសាររបស់គាត់ថា÷

បងស្បៀង ស្រឡាញ់ខ្ញុំណាស់ ។ ពេលខ្ញុំឈឺ គាត់ធ្វើដំណើរពីស្រុកខ្សាច់កណ្តាលមកយកខ្ញុំនៅឃុំកន្ទួតមកព្យាបាលជំងឺនៅទីក្រុងភ្នំពេញ ។ ពេលខ្ញុំមករៀននៅភ្នំពេញ ខ្ញុំស្នាក់នៅជាមួយសាច់ញាតិនៅក្បែររោងកុនគីរីរម្យ ចំណែកគាត់ស្នាក់នៅវត្តមហាមន្ត្រីជាមួយលោកតា អ៊ុំ ទិត ។ គាត់តែងតែគិតដល់ខ្ញុំជានិច្ច ។ ពេលខ្ញុំមិនសប្បាយចិត្តម្តងៗ គាត់លួងលោមខ្ញុំនិងលើកទឹកចិត្តខ្ញុំ ។

ក្នុងចំណោមបងប្អូនខ្ញុំ៧នាក់ បងស្បៀង ជាបងដែលមានសំណាងជាងគេ និងធ្វើការមានមុខតំណែងធំ ។ គាត់រៀនពូកែ បងខ្ញុំពូកែខាងភាសាបារាំងណាស់ ។ នៅក្នុងសង្គមរាស្ត្រនិយម គាត់បានប្រឡងជាប់ជ្រើសរើសឲ្យទៅបម្រើការងារជាប្រធានសហករណ៍នៅខេត្តព្រៃវែង ។ គាត់មើលការខុសត្រូវលើប្រព័ន្ធកសិកម្មទូទាំងខេត្ត ។

នៅឆ្នាំ១៩៧២ បងស្បៀង រៀបការជាមួយជីដូនមួយខ្ញុំ ឈ្មោះ ប៊ូ សារ៉េត ។ នៅថ្ងៃចុងសប្តាហ៍ គាត់ជិះម៉ូតូម៉ាកហុងដាពណ៌ក្រហមរបស់គាត់ពីព្រៃវែងទៅសួរសុខទុក្ខប្រពន្ធរបស់គាត់នៅខ្សាច់កណ្តាល ។

នៅក្នុងសម័យសង្គ្រាមពីឆ្នាំ១៩៧០-៧៤ នៅក្នុងស្រុកភូមិរបស់ខ្ញុំមានភាពជ្រួលច្របល់ខ្លាំងដោយមានការទម្លាក់គ្រាប់បែកផងនិងមានក្រុមខ្មែររំដោះចូលមកអុកឡុកផង ។ ដូច្នេះ ប្រជាជននៅក្នុងភូមិក៏ដូចជាក្រុមគ្រួសារខ្ញុំមិនអាចរស់នៅដោយសេចក្តីសុខឡើយ ។ សាលារៀនត្រូវបិទទ្វារ ហើយប្រជាជនមិនអាចធ្វើដំណើរទៅណាបានតាមចិត្ត ។

នៅឆ្នាំ១៩៧៤ ក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជនជាច្រើនទៀតត្រូវទាហានលន់នល់កៀរឲ្យទៅនៅវត្តទេពប្រណម្យក្នុងស្រុកពញាឮ ខេត្តកណ្តាល ដើម្បីគេចពីការប្រយុទ្ធគ្នារវាងកងទ័ពរំដោះនិងទាហានលន់នល់ ។ យើងស្នាក់នៅទីនោះអស់រយៈពេល ១៤ថ្ងៃ ។ ដោយមានភាពជ្រួលច្របល់ខ្លាំង ប្រជាជនទាំងអស់រត់គេចចេញពីទីនោះ ។ ក្រុមគ្រួសារខ្ញុំរត់បែកគ្នា ។ ខ្ញុំនិងប្តីព្រមទាំងកូនត្រូវកងទ័ពរំដោះជម្លៀសទៅដល់ភូមិព្រៃចារក្នុង ខេត្តកំពង់ចាម ។ ចំណែកឪពុកម្តាយនិងបងប្អូនប្រុស-ស្រីរបស់ខ្ញុំត្រូវទាហានលន់នល់ជម្លៀសតាមកប៉ាល់ទៅទីក្រុងភ្នំពេញ ។ ប្អូនស្រីខ្ញុំឈ្មោះ



អ៊ុំ ស្បៀង និង ប៊ូ សារ៉េត ក្នុងពិធីមង្គលការរបស់គាត់នៅស្រុកខ្សាច់កណ្តាល ខេត្តកំពង់ស្ពឺ ក្នុងឆ្នាំ១៩៧២

សារី ជាមួយប្តីនិងកូន២នាក់ រត់ទៅដល់ខេត្តពោធិសាត់ ។

នៅឆ្នាំ១៩៧៥ ឪពុកម្តាយរបស់ខ្ញុំរួមទាំង បងស្បោង បានធ្វើដំណើរទៅស្រុកកំណើតវិញ ប៉ុន្តែគាត់មិនអាចរស់នៅក្នុងផ្ទះចាស់របស់យើងបានទេ ពីព្រោះផ្ទះនោះឆេះខ្ទេចខ្ទីអស់ទៅហើយ ។ ម្តាយខ្ញុំបានសុំអង្គការរស់នៅក្នុងភូមិដដែល ប៉ុន្តែអង្គការមិនអនុញ្ញាត ។ អង្គការសង្ស័យថាគ្រួសារខ្ញុំជាអ្នកមាន ហើយបងប្អូនខ្ញុំសុទ្ធតែធ្វើការងារមានមុខតំណែងធំ ។ បងស្បោង ត្រូវអង្គការចោទប្រកាន់ថាធ្លាប់ធ្វើទាហានពាក់សក្តិ៥ ព្រោះគាត់មានមាឌធំខ្ពស់ ។ ក្រោយមក គាត់ត្រូវអង្គការយកទៅសម្លាប់ ដោយសារគាត់ធ្វើឲ្យគោរបស់អង្គការមួយក្បាលធ្លាក់ចូលទៅក្នុងស្នឹងលង់ទឹកងាប់ ។ មិនយូរប៉ុន្មាន អង្គការបានយកទាំងប្រពន្ធនិងកូនរបស់គាត់ទៅសម្លាប់ជាបន្តបន្ទាប់ទៀត ។

នៅចុងឆ្នាំ១៩៧៥ ខ្ញុំនិងប្តីខ្ញុំបានទទួលដំណឹងថាឪពុកខ្ញុំត្រូវជម្លៀសទៅស្រុកខ្សាច់កណ្តាល ។ ពេលនោះខ្ញុំកំពុងតែរស់នៅព្រៃចារក្នុង ។ ប្តីខ្ញុំបានសុំការអនុញ្ញាតពីប្រធានភូមិដើម្បីយកអង្ករនិងប្រហុកខ្លះមកឲ្យឪពុកម្តាយខ្ញុំពីសា ។ ប្តីខ្ញុំសុំច្បាប់គេបានតែរយៈពេល៣ថ្ងៃប៉ុណ្ណោះ ។ គាត់ផាក់កង់យ៉ាងប្រញាប់ប្រញាល់ ។ ឪពុកខ្ញុំបានប្រាប់ប្តីខ្ញុំកុំឲ្យមកខ្សាច់កណ្តាលទៀត ព្រោះបងប្អូនខ្ញុំភាគច្រើនជាមុខសញ្ញាដែលខ្មែរក្រហមតាមស្វែងរកនិងចាប់ខ្លួន ។

នៅឆ្នាំ១៩៧៦ ឪពុកខ្ញុំទ្រាំមិនបាននឹងការស្រេកឃ្លាន គាត់បានយកបង្គីទៅដួសកូនក្អុកមកស្ងោរហូប ។ គាត់គិតថានោះគឺជាកូនត្រី ទោះបីម្តាយខ្ញុំប្រាប់យ៉ាងម៉េចក៏គាត់នៅតែមិនជឿ ។ ពេលមួយគាត់ឃើញកម្មាភិបាលខ្មែរក្រហមសម្លាប់ពស់វែកមួយក្បាលហើយយកមកទុកចោលនៅលើរបង គាត់ក៏យកពស់នោះមកស្ងោរពិសារហូតដល់ហើមដៃជើងហើយស្លាប់នៅពេលនោះ ។ គាត់បានដឹងដែរថាពស់នោះមានពិស ប៉ុន្តែគាត់នៅតែពិសាទៀត ។ នៅមុនពេលឪពុកខ្ញុំស្លាប់ គាត់បានស្រែកហៅឈ្មោះខ្ញុំនិងប្អូនសារី ។

ប្អូនស្រីរបស់ខ្ញុំឈ្មោះ សារី និងប្តីព្រមទាំងកូន២នាក់ ត្រូវជម្លៀសទៅដល់ខេត្តពោធិសាត់តាំងពីឆ្នាំ១៩៧៤ ។ ក្រោយពេលទៅដល់ទីនោះបានមួយរយៈខ្លី ប្តីរបស់វាឈ្មោះ កូវ ធីម បានរត់ឡើងខ្ទម្កាគចក្រពេលដែលកំពុងតែធ្វើការនៅការដ្ឋាន ។ ចំណែកប្អូនស្រីខ្ញុំនិងកូននៅផ្ទះដែលឆ្ងាយពីការដ្ឋាន ។ ដូច្នេះ ធីម មិនអាចទៅហៅប្អូនស្រីខ្ញុំនិងក្មួយខ្ញុំបានទេ ។ ធីម គិតថាចាកចេញពីទីនោះសិនសឹមត្រឡប់ទៅយកប្រពន្ធកូននៅពេលក្រោយ ។ មកដល់ភ្នំពេញ ធីម ស្នាក់នៅជាមួយឪពុកម្តាយរបស់ខ្ញុំ ។ ធីម មានបំណងត្រឡប់ទៅយកប្រពន្ធកូនដែរ ប៉ុន្តែគាត់ខ្លាចខ្មែរក្រហមសម្លាប់ចោល ព្រោះគាត់រត់មកចូលខាងលន់នល់ ។ ក្រោយឆ្នាំ១៩៧៥ ធីម នៅតែមិនហ៊ានទៅទទួលយក សារី និងក្មួយៗខ្ញុំមកទៀត រហូតដល់អ្នកទាំងពីរស្លាប់ដោយសារកង្វះអាហារ បន្សល់ទុកកូនម្នាក់ឈ្មោះ ធារី ។

នៅព្រៃចារ មិត្តរ៉េត ជាប្រធាននារីភូមិ បានសួរពីប្រវត្តិរូបរបស់ខ្ញុំនិងប្តីខ្ញុំ ។ ពេលនោះខ្ញុំបែកញើសជោក ។ ខ្ញុំឆ្លើយថាប្តីខ្ញុំជាអ្នករត់ម៉ូតូ ចំណែកខ្ញុំលក់ដូរបន្តិចបន្តួច ។ ប៉ុន្តែ មិត្តរ៉េត មិនជឿខ្ញុំទេ ថែមទាំងនិយាយថា “មិនបាច់ភរទេ អង្គការដឹងហើយថាមិត្តឯងធ្វើគ្រូបង្រៀនទាំងប្តីទាំងប្រពន្ធ” ។ មុនពេល មិត្តរ៉េត ហៅទៅសួរ ខ្ញុំបានប្រាប់ម្ចាស់ផ្ទះដែលខ្ញុំនៅជាមួយថា ខ្ញុំធ្លាប់ធ្វើគ្រូបង្រៀន ។ ខ្ញុំមិនដឹងច្បាស់ថាម្ចាស់ផ្ទះនោះរាយការណ៍ឬក៏អត់ទេ ។ ក្រោយមក គ្រួសារខ្ញុំត្រូវផ្លាស់ទៅភូមិប្រធាតុដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦ ។ យើងសង់កូនខ្ទមនៅលើដីទួលមួយដែលអង្គការចែកឲ្យ ។ កម្មាភិបាលភូមិបានស្នើយកកង់កញ្ចាស់ដែលជាទ្រព្យសម្បត្តិតែមួយគត់របស់យើងដើម្បីយកទៅប្រើប្រាស់នៅក្នុងសហករណ៍ ។ ទោះបីជាប្តីខ្ញុំសុំអង្វរយ៉ាងណាក៏ដោយ កម្មាភិបាលនោះនៅតែយកកង់ខ្ញុំទៅ ។ នៅពេលដែលប្តីខ្ញុំចេញទៅធ្វើការនៅការដ្ឋានម្តងៗ ខ្ញុំបារម្ភពីគាត់ណាស់ ពីព្រោះភូមិនោះសភាពស្ងាត់ជាងភូមិដទៃ ។ ខ្ទមនីមួយៗស្ថិតនៅឆ្ងាយដាច់ពីគ្នា ។ យើងធ្វើស្រែពីកន្លែងមួយទៅកន្លែងមួយ ប៉ុន្តែយើងមិនដែលបានហូបគ្រប់គ្រាន់ទេ ។ កូនៗខ្ញុំឃ្លានយំគ្រប់ៗគ្នា ចំណែកខ្ញុំធ្លាក់ខ្លួនឈឺជាទំងន់ប៉ុន្តែបានអ្នកជិតខាងជួយយកអាសារ ។

ក្រោយមកក្រុមគ្រួសារខ្ញុំត្រូវអង្គការជម្លៀសទៅភូមិព្រីងជ្រុំ ។ ប្រធានភូមិបានចាត់តាំងឲ្យគ្រួសារខ្ញុំរស់នៅលើដីទួលមួយកន្លែងដែលនៅក្បែរនោះមានទីស្នាក់ការភូមិ ផ្ទះកងឈ្លប រោងសិប្បកម្ម រោងបាយរួម រោងកិនស្រូវ និងរោងដាំអង្ករ ។

ប្ដីខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅលើកទំនប់នៅការដ្ឋានឆ្ងាយពីភូមិ ចំណែកខ្ញុំដេរស្លឹកកណ្ដប ហើយកូនៗរបស់ខ្ញុំក៏ទៅជាមួយខ្ញុំដែរ ។ ជារៀងរាល់ថ្ងៃបុណ្យខួប ១៧ មេសា អង្គការអនុញ្ញាតឲ្យប្រជាជនឈប់សម្រាករយៈពេល៣ថ្ងៃ ។ អំឡុងពេល៣ថ្ងៃនោះ យើងបានហូបឆ្អែតគ្រប់ៗគ្នា ។ ប្ដីរបស់ខ្ញុំបានមកសួរសុខទុក្ខខ្ញុំនិងកូននៅផ្ទះ ។

នៅទីនោះពិបាករកអុសដាំស្លណាស់ ។ ពេលប្ដីខ្ញុំត្រឡប់មកពីធ្វើការនៅការដ្ឋានម្ដងៗ គាត់រកអុសចងបាច់លីចម្ងាយរាប់គីឡូមកឲ្យខ្ញុំនៅផ្ទះ ។ ក្រោយពីបញ្ចប់ការដកស្ទូងស្រូវ អង្គការចាត់តាំងឲ្យធ្វើជីយកទៅដាក់ស្រែ ។ ខ្ញុំដើររកកាប់ទន្រ្ទានខែត្រយកមកចិញ្រ្ចាំលាយជាមួយដីដំបូកដេះ លាមកសត្វ និងលាមកមនុស្ស ។ ជីលាមកមនុស្សគួរឲ្យខ្ពើមរអើមណាស់ ប៉ុន្តែខ្ញុំត្រូវតែទ្រាំធ្វើ ព្រោះបើខ្ញុំមិនធ្វើខ្ញុំពិតជាត្រូវស្លាប់ ។ ឈ្លបតាមឃ្លាំមើលខ្ញុំរហូត ។ នៅទីនោះមានការលំបាកណាស់ក្នុងការហូបចុក ។ ពេលខ្លះខ្ញុំកាត់ដើមត្រាវព្រៃដែលដុះនៅក្បែរភូមិមករំងាស់លាយជាមួយអំបិលនិងអង្ករខ្លះ ។ ពេលហូបហើយរមាស់ពេញខ្លួន កូនៗខ្ញុំយំទ្រហឹងពេញផ្ទះ ។ ខ្ញុំអាណិតកូនខ្ញុំណាស់ មិនដឹងរកអ្វីមកឲ្យវាហូប ។ ពេលខ្លះខ្ញុំទៅស្ទូចត្រី ប្រធានកងគំរាមខ្ញុំថា «ធ្វើបុកថោកទាបទៅអង្គុយស្ទូចត្រី ប្រយ័ត្នអង្គការយកទៅសម្លាប់ចោល» ។ មិនត្រឹមតែគ្រួសារខ្ញុំទេ ប្រជាជនទូទាំងភូមិក៏ជួបការលំបាកដូចខ្ញុំដែរ ។ ដោយការខ្វះខាតអាហារ កូនរបស់ខ្ញុំម្នាក់ធ្លាក់ខ្លួនឈឺរាគមួលជាទម្ងន់ ។ ខ្ញុំបានជួបជាមួយអតីតគ្រូពេទ្យម្នាក់មកពីភ្នំពេញ ។ គាត់ប្រាប់ខ្ញុំថា អាការៈជំងឺកូនស្រីរបស់ខ្ញុំបណ្ដាលមកពីខ្វះអាហារយូរខែទើបបណ្ដាលឲ្យរលាកប្រព័ន្ធរំលាយអាហារ ។ ខ្ញុំបានយកខ្សែកមាសចុងក្រោយដែលខ្ញុំនៅសល់ ទៅដូរយកអង្ករពីភូមិផ្សេងមកដាំបាយឲ្យកូនខ្ញុំហូប ។ កូនខ្ញុំហូបបាយច្រើនណាស់ ។ ក្រោយពីហូបបាយហើយ ជំងឺរបស់វាកាន់តែធ្ងន់ធ្ងរឡើងជាលំដាប់ ។ កូនខ្ញុំ២នាក់ទៀតក៏ឈឺ ប្ដីខ្ញុំក៏ឈឺដែរ ។ មេកងប្រាប់ឲ្យក្រុមគ្រួសារខ្ញុំទៅមន្ទីរពេទ្យទាំងអស់គ្នា ។ នៅមន្ទីរពេទ្យបាន៣ថ្ងៃ កម្មាភិបាលពេទ្យបង្ខំឲ្យប្ដីខ្ញុំទៅរកកាប់អុសសម្រាប់ប្រើប្រាស់នៅរោងបាយ ។ យប់មួយខ្ញុំដេកឱបកូនស្រីខ្ញុំជាប់ ។ វាស្រែកខ្សាវៗដាក់ត្រចៀកខ្ញុំទាររកទឹកផឹក ។ ពេលខ្ញុំចាក់ទឹកឲ្យវាផឹក វារឹងអណ្ដាតផឹកទឹកមិនបាន ។ ឃើញអាការៈកូនខ្ញុំបែបនេះខ្ញុំដាស់ប្ដីខ្ញុំឲ្យក្រោកឡើង ។ ពេលនោះកូនខ្ញុំបិទភ្នែក ហើយដង្ហើមក៏តិចទៅៗរហូតដល់ផុត ។ ខ្ញុំនិងប្ដីខ្ញុំយំរហូតទល់ភ្លឺ ។ ប្ដីខ្ញុំទៅសុំក្ដារចាស់ៗពីកងឈ្លបដើម្បីយកមកធ្វើក្ដារមឈូសដាក់ខ្មោចកូន ប៉ុន្តែឈ្លបមិនអនុញ្ញាត ។ ឈ្លបនោះលីចបហើយហៅប្ដីខ្ញុំបីសពកូនស្រីខ្ញុំដើរតាមក្រោយទៅព្រៃខាងក្រោយមន្ទីរពេទ្យ ។ ឈ្លបនោះកាប់ដីបាន២-៣ចប ក៏ប្រគល់ចបឲ្យប្ដីខ្ញុំកាប់ដីកប់ខ្មោចកូនដោយខ្លួនឯង ។

នៅចុងឆ្នាំ១៩៧៨ ភ្លៀងធ្លាក់ខ្លាំងបណ្ដាលឲ្យលិចសន្ទូងនិងខូចខាតស្រូវអស់ជាច្រើន ។ ពេលនោះការហូបចុកកាន់តែខ្វះខាតឡើង ប៉ុន្តែខ្ញុំបានត្រៀមរបស់ហូបចុកបានខ្លះទុកឲ្យកូនៗរបស់ខ្ញុំ ។ មិត្តនារីម្នាក់ឈ្មោះ សាង បានលួចស្ដាប់វិទ្យុថា នៅពេលឆាប់ៗខាងមុខនេះនឹងមានកងទ័ពរណសិរ្សមករំដោះប្រជាជន ។ យើងសប្បាយចិត្តខ្លាំងណាស់ ។ ស្នូរសម្លេងរថក្រោះ កាំភ្លើងធំនិងក្បួនរថយន្តទ័ព បានចូលមកដល់ទីរួមស្រុកស្គន់ កម្មាភិបាលខ្មែរក្រហមបាននាំគ្នារត់ភៀសខ្លួនចូលព្រៃអស់ ។ ពេលនោះប្ដីខ្ញុំកំពុងតែកាប់ព្រៃដែលស្ថិតនៅឆ្ងាយពីភូមិ ។ កូនខ្ញុំយំទ្រហឹងសួររកឪពុក ។ ពេលនោះប្រជាជននាំគ្នាទៅយកស្រូវនៅទីលានបោកស្រូវ ។ ខ្ញុំក៏ទៅយកស្រូវបានខ្លះមកទុក ។ ខ្ញុំមិនទាន់ចាកចេញភ្លាមទេ ។ ខ្ញុំនៅរង់ចាំប្ដីខ្ញុំអស់រយៈពេលជាង១០ថ្ងៃ ទើបឃើញគាត់មករកខ្ញុំនិងកូន ។ គាត់ដើរស្ទើរតែមិនរួច ខ្លួនប្រាណប្រឡាក់សុទ្ធតែដីក្រហមស្រម៉េកស្រម៉ក ។ ក្រោយពេលប្ដីខ្ញុំជាសះស្បើយ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរមកទីក្រុងភ្នំពេញ ។ ប្រជាជនមួយចំនួនឃាត់យើងឲ្យរស់នៅភូមិនេះភូមិនោះ ប៉ុន្តែគោលដៅរបស់យើងគឺទីក្រុងភ្នំពេញ ។ ប្ដីខ្ញុំមិនចង់វិលទៅស្រុកកំណើតវិញទេ ព្រោះគាត់យល់ថានៅទីក្រុងងាយស្រួលរកការងារធ្វើជាងនៅខេត្ត ។

អ្វីដែលខ្ញុំស្ដាយបំផុត គឺមិនបានជួបមុខឪពុកខ្ញុំនិងបងស្បោងជាលើកចុងក្រោយ ។ ខ្ញុំគួរតែបានជួបគាត់ទាំងពីរនាក់មុនពេលដែលគាត់ស្លាប់ ។ ◆◆◆

**ប៉ាង ពីច័ន និង ស៊ីរ សាទីណា**

# រណ្តៅសាកសពនៅក្នុងព្រៃឈើនាង

ចាប់តាំងពីថ្ងៃទី២៣រហូតដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៥ ប្រជាជនជាច្រើននាក់មកពីភូមិពោធិ៍ព្រេង ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បាននាំគ្នាផ្ដើលឈូសរទៅជីកកកាយរណ្តៅសាកសពមួយកន្លែងនៅក្នុងព្រៃឈើនាងដើម្បីរកមាស ។ មូលហេតុនៃការជីកកកាយនេះគឺដោយសារកុមារីម្នាក់រើសបានក្រវិលមាសម្ខាងពីក្នុងរណ្តៅនោះ ។

សៀម ផល អាយុ១៥ឆ្នាំ បានរើសក្រវិលមាសម្ខាងពីក្នុងរណ្តៅសាកសពនៅពេលដែលនាងចុះទៅរើសឡេវអាវដែលដាច់ដោយសារប្រឡែងគ្នាជាមួយ រ៉ា និង លីម ។ ផល បានយកមាសដែលខ្លួនរើសបានទៅប្រគល់ឲ្យជីដូនទុក រួចនាងត្រឡប់មកកន្លែងរណ្តៅម្តងទៀតជាមួយ បាន បឿន, សាយ ស្ដើង និង ផន ភឿន ។ ក្នុងរយៈពេលដ៏ខ្លី អ្នកទាំងបីរើសបានមាសចំនួន៨ជី គឺខ្សែក ចំនួនពីរខ្សែ ចិញ្ចៀនមួយវង់ និងក្រវិលមួយគូ ពីក្នុងជាយអាវរហែករយ៉ៃមួយបន្ទាប់ពីបានចាប់ទាញខ្សែនីឡុងមួយចេញពីក្នុងរណ្តៅនោះ ។

ដំណឹងនេះបានលេចឮដល់ប្រជាជនឯទៀតនៅក្នុងភូមិ ហើយការគាស់កកាយក៏ចាប់ផ្ដើម ។ រណ្តៅជាច្រើនត្រូវបានគាស់បំផ្លាញ ។ ហែម ហន រើសបានមាសសន្លឹកចំនួនពីរសន្លឹកទម្ងន់៨ជី ។ ប៊ិន ខុំ រើសបានមាសសន្លឹក១សន្លឹកនិងក្រវិលមាសម្ខាង ។ ភិន ប៊ី រើសបានក្រវិលមាសម្ខាង ។ ប្រជាជនមួយចំនួនទៀតខំជីកកាយដែរប៉ុន្តែរកមិនបានអ្វីសោះ ។ ម៉ាន់ សាម៉ែន និយាយថា “ខ្ញុំអត់មានរើសបានអ្វីបន្តិចទាល់តែសោះ” ។

នៅល្ងាចថ្ងៃទី២៦ការជីកកកាយនេះបានផ្អាកទៅវិញ ។ មេឃុំក្រាំងដីវ៉ាយឈ្មោះ វ៉ វ ខាំ បានហាមប្រាមប្រជាជនឲ្យឈប់គាស់កកាយរណ្តៅទាំងនោះតទៅទៀត ព្រោះជាការរំខានដល់ព្រលឹងខ្មោច ។ វ៉ វ ខាំ បានធ្វើកំណត់ហេតុស្ដីអំពីការគាស់រណ្តៅសាកសពទាំងនោះ និងបានជូនដំណឹងដល់សមត្ថកិច្ច ។

ឆ្អឹងសាកសពដែលត្រូវគាស់ចេញពីក្នុងរណ្តៅមានចំនួនប្រហែល៦០នាក់ ។ ឆ្អឹងលលាដ៍ក្បាលនិងឆ្អឹងផ្សេងៗត្រូវបានអ្នកគាស់រើសបោះគរទៅជ្រុងម្ខាងនៃរណ្តៅបង្កើតបានជាឆ្អឹងបីគំនរ ។ ឆ្អឹងលលាដ៍ក្បាលបានបែកជាបំណែកៗ មានតែលលាដ៍ក្បាលចំនួនបីប៉ុណ្ណោះដែលពុំបែកបាក់ ។ ក្រៅពីនេះមានសម្លៀកបំពាក់ចាស់ៗដែលរហែករយ៉ៃ ឆ្អឹងស្មងដៃស្មងជើង ឆ្អឹងជំនីរ និងបំណែកលលាដ៍ក្បាលជាច្រើនទៀតស្ថិតនៅរាយប៉ាយក្នុងរណ្តៅ ។

រយៈពេល២៦ឆ្នាំបានកន្លងផុតទៅបន្ទាប់ពីរបបកម្ពុជា


ទីតាំងរណ្តៅសាកសពនៅក្នុងព្រៃឈើនាងដែលត្រូវប្រជាជនគាស់កកាយ

ប្រជាធិបតេយ្យដួលរលំ រឿងរ៉ាវស្តីអំពីទីតាំងសម្លាប់មួយកន្លែងនេះទើបតែត្រូវបានបើកកកាយជាលើកដំបូង ។ មុនឆ្នាំ១៩៧៥ ដីនៅត្រង់ទីតាំងនេះបានបាក់ស្រុតដោយសារទឹកភ្លៀងហូរច្រោះ បង្កើតបានជារណ្តៅធំៗជាច្រើនដែលមានជម្រៅជិតបីម៉ែត្រ ។ ប្រជាជនហៅរណ្តៅទាំងនោះថា «រលុះ» ។ នៅរដូវភ្លៀង រលុះគឺជាកន្លែងទទួលទឹកភ្លៀងដែលហូរមកពីកន្លែងផ្សេងៗ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឈ្លបខ្មែរក្រហមបានសម្លាប់ប្រជាជនទម្លាក់ក្នុងស្នាមរលុះទាំងនេះហើយមិនបានលប់ដីពីលើឡើយ ។ វ៉ែ ខាំ និងប្រជាជនចំណាស់ៗក្នុងភូមិពោធិ៍ព្រេង បានរំឭកថាជនរងគ្រោះដែលត្រូវខ្មែរក្រហមសម្លាប់ដាក់ក្នុងស្នាមរលុះនេះគឺជាប្រជាជនថ្មីដែលត្រូវជម្លៀសមកពីទីក្រុងភ្នំពេញ ។ រយៈពេលជាច្រើនឆ្នាំ ទឹកភ្លៀងបានហូរនាំដីមួយចំនួនមកលប់ពីលើសាកសពដែលនៅក្នុងរណ្តៅ ហើយកូនឈើតូចៗក៏ដុះព័ទ្ធទីតាំងនេះជុំជិត ។ ក្រោមកម្តៅថ្ងៃ ខ្យល់ និងទឹកភ្លៀង សាកសពបានរលេះរលួយនៅសល់តែគ្រោងឆ្អឹង ហើយដីក៏ហូរច្រោះទៅទៀតបណ្តាលឲ្យលេចចេញឆ្អឹងមួយចំនួន ។

ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ កម្រមានប្រជាជនដើរឆ្លងកាត់កន្លែងនេះណាស់ លើកលែងតែកុមារឃ្វាលគោនិងអ្នករកខសប៉ុណ្ណោះ ។ កុមារឃ្វាលគោចូលចិត្តលោតចុះលោតឡើងនៅកន្លែងនេះដើម្បីឆ្លងទៅលេងនៅវាលទំនាបមួយដែលនៅក្បែរនោះ ។ សៀម ផល ដែលមករកខសនៅទីនេះ ជារៀងរាល់ថ្ងៃជាមួយមិត្តភក្តិរបស់នាង បានប្រាប់ថា «ខ្ញុំបានជូនប្អូនខ្ញុំឈ្មោះ រ៉ា និង លឹម ទៅមើលក្បាលខ្មោចដែលលេចចេញពីក្នុងដី ។ ខ្ញុំមិនដឹងថាក្បាលខ្មោចដែលខ្ញុំឃើញរាល់ថ្ងៃនេះជាក្បាលរបស់អ្នកណាទេ ហើយក៏មិនដឹងថាស្លាប់តាំងពីពេលណាដែរ» ។ ម៉ាន់ សាម៉េន រៀបរាប់ថា កាលពីអំឡុងឆ្នាំ១៩៨០ កូនឈើដែលដុះជុំវិញបរិវេណរណ្តៅនេះមានសភាពល្អជាងនៅកន្លែងដទៃៗទៀតក្នុងព្រៃឈើនាង ។ បច្ចុប្បន្នកូនឈើទាំងនោះត្រូវអ្នករកអុសកាប់ជម្រះអស់ នៅសល់តែដើមឈើធំៗដែលផ្តល់ម្លប់សាខាដល់កុមារឃ្វាលគោនិងអ្នករកខស ។ ម្យ៉ាងទៀត ការកាប់នេះក៏ក្នុងគោលបំណងឲ្យងាយមើលឃើញស្នាមរលុះទាំងនោះចៀសវាងមនុស្សធ្លាក់ចូលផង ។

២៦ឆ្នាំហើយ ព្រលឹងខ្មោចដែលស្លាប់នៅក្នុងព្រៃឈើនាងនៅតែពុំអាចចាកចេញពីទីកន្លែងដែលខ្លួនត្រូវសម្លាប់ ខណៈដែលយុត្តិធម៌នៅតែពុំទាន់រកឃើញ ។ ម្យ៉ាងទៀតក៏ពុំធ្លាប់មាននរណាម្នាក់និមន្តព្រះសង្ឃមកបង្សុកូលឬធ្វើបុណ្យឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធអ្នកដែលស្លាប់នៅទីនេះដែរ ។ វ៉ែ ខាំ ជឿជាក់ថាព្រលឹងខ្មោចទាំងអស់នេះស្រេកឃ្លានទើបបន្តឲ្យកើតមានហេតុចម្លែកៗចំពោះប្រជាជននៅក្នុងភូមិពោធិ៍ព្រេង ។ កាលពីរដូវកាន់បិណ្ឌ ឆ្នាំ២០០៤ កុមារីម្នាក់បានយល់សប្តិឃើញថា ព្រលឹងខ្មោចមួយមកប្រាប់ឲ្យនាងទៅយកមាសក្នុងរណ្តៅសាកសពនៅក្នុងព្រៃឈើនាង ប៉ុន្តែនាងមិនហ៊ានទៅតាមការប្រាប់នោះឡើយព្រោះខ្លាច ម្យ៉ាងនាងគិតថាគ្រាន់តែជាការយល់សប្តិប៉ុណ្ណោះ ។ អ្នកភូមិពោធិ៍ព្រេងមានជំនឿថា ព្រឹត្តិការណ៍ដ្អើលគាស់រណ្តៅសាកសពនេះកើតឡើងគឺដោយសារព្រលឹងខ្មោចនាំកុមារី សៀម ផល ឲ្យឃើញមាសនៅក្នុងរណ្តៅ ដើម្បីជាថ្នូរនឹងការដាក់សែនចំណីអាហារដល់ខ្លួនដែលស្រេកឃ្លានអស់រយៈពេលជាងម្ភៃឆ្នាំមកហើយ ។ មុយ យឿន អាយុ៦០ឆ្នាំ ជាមេភូមិក្រសាំងខ្ពស់និយាយថា រឿងរ៉ាវដែលកើតមានឡើងនៅក្នុងទីតាំងសម្លាប់ព្រៃឈើនាងគឺពិតជាមកពីព្រលឹងខ្មោចដែលស្លាប់កាលពីរបបកម្ពុជាប្រជាធិបតេយ្យចង់ឲ្យអ្នកដែលនៅរស់អើពើនឹងភាពស្រេកឃ្លានរបស់ខ្លួន និងអើពើនឹងយុត្តិធម៌ដែលខ្លួនពុំទាន់បានទទួល ។

នៅរដូវកាន់បិណ្ឌឆ្នាំ២០០៥ នេះគឺជាលើកទី១ ហើយដែលប្រជាជននៅក្នុងភូមិពោធិ៍ព្រេងបាននិមន្តព្រះសង្ឃទៅសូត្រមន្តបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៅក្នុងព្រៃឈើនាង ។ មេឃុំក្រាំងដីវ៉ាយ និយាយថា ចាប់ពីឆ្នាំនេះតទៅប្រជាជនក្នុងឃុំរបស់គាត់នឹងនិមន្តព្រះសង្ឃទៅសូត្រមន្តបង្សុកូលនិងសែនចំណីអាហារដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅទីនេះនៅរៀងរាល់រដូវបិណ្ឌភ្ជុំ ។ មេឃុំក្រាំងដីវ៉ាយមានគម្រោងដឹកនាំការកសាងស្តូបមួយនៅក្បែរទីតាំងសម្លាប់នេះដើម្បីតម្កល់ឆ្អឹងទាំងប៉ុន្មានដែលប្រជាជនបានគាស់កកាយ ។

នេះគឺជាទីតាំងសម្លាប់ទី៣៨១ ដែលបានចុះក្នុងបញ្ជីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ផេង ពងរ៉ាស៊ី**

# រំឭករឿងរ៉ាវដើម្បីថែរក្សាប្រវត្តិសាស្ត្រ


ចក់ ធឿន

ចក់ ធឿន អាយុ៥០ឆ្នាំ គឺជាអតីតអ្នកទោសម្នាក់នៅគុកសង់ដែលមានទីតាំងនៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ធឿន កើតនៅភូមិជើងព្រៃ ឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុករបស់គាត់ឈ្មោះ យិម ចក់ ម្តាយឈ្មោះ ម៉ៅ នុត ។ ធឿន មានបងប្អូន៤នាក់ ។ នៅក្នុងឆ្នាំ១៩៧០ ធឿន មានអាយុ១៤ឆ្នាំ បានបួសជាសង្ឃនៅវត្តវិហារបិទមាស នៅក្នុងស្រុកស្អាង ខេត្តកណ្តាល គម្រប់រយៈពេលមួយវស្សាទើបទៅបន្តការសិក្សាវិបស្សនានៅវត្តកោះខែល ។

មួយខែក្រោយពីខ្មែរក្រហមគ្រប់គ្រងអំណាចទូទាំងប្រទេស ធឿន ត្រូវមេឃុំស្អាងបង្ខំឲ្យលាចាកសិក្ខាបទ ដោយព្រមានថា "ទោះជាព្រះអង្គមិនចង់សឹកក៏ត្រូវតែផ្សឹកដែរ ស្អែកខានស្អែកអង្គការដើរបកស្បង់ជីពរលោកសង្ឃហើយ" ។ ព្រះសង្ឃទាំង៣៨អង្គដែលគង់នៅក្នុងវត្តនោះបានសឹកនៅក្នុងថ្ងៃតែមួយ ។

បន្ទាប់ពីលាចាកសិក្ខាបទ ធឿន បានទៅរស់នៅជាមួយមេឃុំម្នាក់ឈ្មោះ គាទិត្យ ។ បីខែក្រោយមក គាទិត្យ ត្រូវអង្គការហៅទៅបាត់រហូត ហើយក៏បញ្ជូន ធឿន ឲ្យទៅរស់នៅក្នុងកងចល័ត ។ ធឿន ត្រូវធ្វើការធ្ងន់ធ្ងរជាច្រើនម៉ោងក្នុងមួយថ្ងៃ រីឯការហូបចុកគឺបបរជាមួយសម្លត្រកួនឬស្ពៃ ទឹកសម្លខ្មៅកខ្វក គ្មានសាច់ឬត្រីនៅក្នុងនោះ ។

ម៉ោង៨ព្រឹក ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ កងទ័ពពីរនាក់បានមកប្រាប់ ធឿន ឲ្យទៅធ្វើបត្តី ប៉ុន្តែមិនបានបញ្ជាក់ថាធ្វើនៅឯណាទេ ។ ធឿន ត្រូវបញ្ជូនឡើងឡានដែលនៅក្នុងនោះមានមនុស្ស៤៨នាក់ គឺបុរស៤៤នាក់ ស្ត្រី៤នាក់ ។ គ្មាននរណាម្នាក់ជាប់ចំណងឬខ្នោះទេ ។ នៅពេលឡានទៅដល់គោលដៅគឺគុកសង់ ឆ្មាំបានហៅមនុស្សទាំងអស់ឲ្យចុះពីលើឡានដោយភ្ជង់នឹងកាំភ្លើង ហើយបញ្ជាឲ្យលើកដៃឡើងលើ ។ បន្ទាប់មក ឆ្មាំយកក្រមានិងខ្សែគោមកចងស្លាបសេកមនុស្សទាំងអស់ព្រមទាំងទាត់ធាក់ផង ។ អ្នកទោសទាំង៤៨នាក់ត្រូវបានបែកចែកទៅតាមកំរិតទោស ហើយឃុំខ្លួនក្នុងកន្លែងផ្សេងៗគ្នា ។ ធឿន បញ្ជាក់ថា អ្នកទោសនៅក្នុងគុកចែកចេញជាបីកម្រិតគឺ កម្រិតធ្ងន់ កម្រិតមធ្យម និងកម្រិតស្រាល ។ អ្នកទោសកម្រិតធ្ងន់ត្រូវជាប់ក្នុងគុកងងឹតដែលបន្ទប់នីមួយៗដាក់តែមនុស្សម្នាក់តែប៉ុណ្ណោះ ។ អ្នកទោសកម្រិតមធ្យមត្រូវដាក់ឲ្យនៅក្នុងបន្ទប់ដែលអាចដាក់មនុស្សប្រមាណម្នាក់ឬពីរនាក់ ហើយជាប់ខ្នោះដៃខ្នោះជើងរហូត ។ ចំណែកអ្នកទោសកម្រិតស្រាលត្រូវដាក់នៅក្នុងមួយបន្ទប់ដែលមានគ្នា៣០-៤០នាក់ ។ អ្នកទោសស្រាលត្រូវឆ្មាំបញ្ចេញឲ្យទៅធ្វើការនៅខាងក្រៅនៅពេលថ្ងៃ ។ នៅក្នុងគុកមានអគារធំៗចំនួនបួនដាក់អ្នកទោសតាមវ័យនិងភេទដូចជា យុវជន យុវនារី និងវ័យចំណាស់ ។

ធឿន ជាប់ក្នុងគុកកម្រិតមធ្យមនៅក្នុងបន្ទប់មួយតែម្នាក់ឯង ។ អ្នកយាមឲ្យគាត់ហូបបាយមួយថ្ងៃម្តង ថ្ងៃខ្លះអ្នកយាមគុកភ្លេចយកបាយមកឲ្យ ធឿន ត្រូវអត់បាយ ។ ធឿន និយាយថា ពេលខ្លះគាត់ស្រេកទឹកខ្លាំងពេកគាត់ផឹកទឹកនោមខ្លួនឯង ។

ធឿន ត្រូវឈ្មោះ ជឿន យកទៅចម្លើយជាច្រើនដងនៅក្នុងបន្ទប់ស្ងាត់មួយ ។ ពេលនោះទើប ធឿន បានដឹងថា មូលហេតុដែលអង្គការចាប់ទៅទីនោះដោយសារមានអ្នកភូមិរាយការណ៍ថាគាត់គឺជានាយទាហានសក្តិ១និងជាសេ.អ៊ី.អារបស់អាមេរិកាំង ។ នៅពេលដែល ធឿន ប្រកែកមិនទទួលសារភាពថាគាត់ជានាយទាហាននិងជាសេ.អ៊ី.អា ជឿន បានវាយគាត់រហូតដល់សន្លប់

រួចបញ្ជាឲ្យឆ្មាំអូស ធឿង យកទៅដាក់ក្នុងគុកវិញ ។

បន្ទាប់ពីជាប់នៅក្នុងគុកសង់បានមួយខែ ធឿង បានដឹងថាឪពុកម្តាយរបស់គាត់ក៏ជាប់ក្នុងគុកសង់ដែរ ហើយឪពុករបស់គាត់បានស្លាប់បាត់បង់ជីវិតនៅក្នុងគុកនេះទៅហើយ ។

បីខែក្រោយមក ធឿង ត្រូវឈ្លបបញ្ចេញឲ្យមកនៅគុកកម្រិតស្រាល ។ ពេលនោះ ធឿង ត្រូវបញ្ជូនទៅធ្វើការនៅក្នុងក្រុមផលិតជីដែលមានសមាជិក១៧នាក់ ។ ជារៀងរាល់ថ្ងៃពេលទៅធ្វើការនិងពេលត្រឡប់មកវិញ ឆ្មាំគុកឈ្មោះ ឈឿន ជិះលើ-ករបស់ ធឿង ។ ពេលចេញទៅធ្វើការម្តងៗ អ្នកទោសភេទប្រុសត្រូវដាក់ច្រវាក់ជើង ចំណែកអ្នកទោសភេទស្រីមិនដាក់ខ្នោះទេ ។ ច្រវាក់ដែលជាប់នឹងកជើងរបស់ ធឿង ត្រូវថ្ងៃក្តៅបណ្តាលឲ្យជើងរបស់គាត់រលាករហូតក្លាយទៅជាដំបៅ ។ ឈ្លបម្នាក់ទៀតឈ្មោះ តាំ ចំណាយពេលទំនេរមកមួលស្លឹកត្រចៀករបស់ ធឿង លេងរហូតធ្វើឲ្យត្រចៀកម្ខាងរបស់គាត់ទៅជាថ្លង់រហូតដល់សព្វថ្ងៃ ។

ធឿង បានទទួលរបបហូបចុកពីរដងក្នុងមួយថ្ងៃ ម្តងបានបបរមួយវែក ។ ពេលចុងភៅចែកបបរម្តងៗ បើមានបបរកំពប់ទៅលើដី ធឿង សុខចិត្តប្រមូលកើបយកមកដាក់ចានហូបវិញ ។ អ្នកទោសទាំងអស់ត្រូវដេកផ្ទាល់ដីដែលមានស្នាមគាស់ឥដ្ឋការ៉ូក្រហេងក្រហូង និងដែលសម្បូរទៅដោយសត្វស្រមោចនិងច្រមឹមព្រះ ។ អ្នកទោសដេកជាជួរៗដោយដាក់ខ្នោះជើងវែងរួមគ្នា ។ នៅក្នុងបន្ទប់មួយមានពាងមួយសម្រាប់ដាក់លាមកនិងទឹកនោម ។ ប្រសិនបើនរណាម្នាក់ចង់បន្ទោរបង់ ត្រូវបន្ទោរបង់ដាក់ក្នុងដុំថ្មមួយ រួចហុចបន្តគ្នារហូតដល់អ្នកដែលដេកនៅជិតពាងដើម្បីចាក់ចូលទៅក្នុងពាង ។ ធឿង និយាយថា គាត់គឺជាអ្នកដែលដេកនៅជិតពាងសម្រាប់ដាក់លាមក ហើយក្បាលរបស់គាត់ទល់នឹងពាងនោះតែម្តង ។

ប្រហែលមួយខែមុនរបបខ្មែរក្រហមដួលរលំ អង្គការផ្លាស់ប្តូរអ្នកគ្រប់គ្រងនៅគុកសង់ ។ ប្រធានគុកដែលទើបមកដល់ឈ្មោះ តាណៃវ ។ ក្រោមការគ្រប់គ្រងរបស់ តាណៃវ ការហូបចុករបស់អ្នកទោសមានសភាពប្រសើរជាងមុនមួយកម្រិត ការធ្វើទារុណកម្មក៏ត្រូវកាត់បន្ថយ ។ ថ្ងៃមួយឆ្មាំគុកឈ្មោះ ឈឿន ប្រើ ធឿង ឲ្យទៅកាប់ទំពាំងនៅព្រៃឬស្សីខាងក្រោយគុក ។ ពេលនោះ ធឿង មិនសូវស្គាល់ផ្លូវទេ គាត់ដើរតាមច្រកផ្លូវតូចៗហើយជុងធ្លាក់ទៅក្នុងរណ្តៅមួយកប់ត្រឹមភ្លៅទាំងពីរ ។ ពេលដែល ធឿង ចេញពីរណ្តៅមកវិញ ជើងរបស់គាត់ជាប់ជង្គង់ជាច្រើននិងមានក្លិនស្អុយយ៉ាងខ្លាំង ។ ធឿង ពិនិត្យរណ្តៅនោះទើបដឹងថាជារណ្តៅសាកសពរួមដែលទើបតែកប់មិនយូរប៉ុន្មានឡើយ ។ ដោយខ្លាចមានអ្នកដឹងរឿងនេះ ពេលត្រឡប់មកវិញ ធឿង ចូលទៅត្រាំនៅក្នុងអាងជីលាមកដើម្បីបំបាត់ក្លិនគំរង់ខ្មោច ។ ធឿង លាក់រឿងនេះរហូតដល់ឆ្នាំ១៩៧៩ សូម្បីតែម្តាយរបស់គាត់ឬមិត្តភក្តិដែលធ្វើការជាមួយគ្នាក៏គាត់មិនហ៊ានប្រាប់ឲ្យដឹងដែរ ខ្លាចខ្មែរក្រហមយកគាត់ទៅសម្លាប់ ។

ពេលដែលរបបខ្មែរក្រហមទើបតែដួលរលំថ្មីៗ ធឿង មិនហ៊ានដេកនៅក្នុងផ្ទះរបស់គាត់ទេ ព្រោះគាត់ឮអ្នកភូមិនិយាយថាអតីតឆ្មាំនៅគុកសង់ជិះសេះស្វែងរកអ្នកដែលសេសសល់ជីវិតពីគុកសង់ដើម្បីយកទៅសម្លាប់ចោល ។ ជារៀងរាល់យប់ ធឿង ទៅដេកនៅក្នុងព្រៃ ព្រោះខ្លាចអ្នកដែលធ្លាប់ធ្វើការក្នុងគុកសង់តាមមកសម្លាប់គាត់ទៀត ។ ធឿង ភ័យខ្លាចរហូតដល់ដេកយល់សប្តិឃើញខ្មែរក្រហមដេញតាមសម្លាប់គាត់ជារឿយៗ ។

បច្ចុប្បន្ននេះ ធឿង បានជ្រើសរើសយកការស្តាប់ធម៌ដើម្បីដោះស្រាយបញ្ហាផ្លូវចិត្តរបស់គាត់ ។ ធឿង ទៅស្តាប់ព្រះសង្ឃទេសនានៅវត្តនៅរៀងរាល់ថ្ងៃសីល និងជួបជុំជជែកលេងជាមួយមិត្តភក្តិដែលមានវ័យស្របាលៗគ្នា ។ ធឿង មិនសងសឹកនឹងអ្នកដែលបានធ្វើខុសមកលើគាត់និងក្រុមគ្រួសាររបស់គាត់ទេ ប៉ុន្តែគាត់ត្រូវការឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវតាមផ្លូវច្បាប់ ។

ធឿង លើកយករឿងរ៉ាវរបស់គាត់នៅក្នុងរបបខ្មែរក្រហមមកនិយាយប្រាប់កូនចៅនិងក្មេងៗនៅក្នុងភូមិរបស់គាត់ឲ្យបានដឹង ។ គាត់មិនមានចេតនាឲ្យកូនចៅរបស់គាត់ចងគំនុំនឹងខ្មែរក្រហមទេ ផ្ទុយទៅវិញគាត់ចង់ឲ្យមនុស្សជំនាន់ក្រោយបានដឹងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ ធឿង ចង់ឲ្យមានកម្មវិធីសិក្សាអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហមដើម្បីកុមារជំនាន់ក្រោយបានរៀន ។

**គង់ សុភគឿន**

# ស្វែងរករូបថតជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ FM102MHz ទីក្រុងភ្នំពេញ វិទ្យុ FM93.25MHz ខេត្តកំពត វិទ្យុ FM99MHz ខេត្តព្រះវិហារ និងវិទ្យុFM ១០៣.២៥MHz ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះយើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួនតែប៉ុណ្ណោះ ។ រូបថតទាំងនោះចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នក បន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។


ក្រុមគ្រួសាររបស់ ខៀវ ធឿន

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthpivoine@dccam.org ។

សូមអរគុណ ។

# ពាក្យសុំរបស់មេធាវីចុងចោទ សេចក្តីសន្និដ្ឋានការពារសារណា និងសេចក្តីសង្ខេបបណ្តឹងសាទុក្ខ

## ១) សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជា មេធាវីមិនត្រូវបានអនុញ្ញាតឲ្យផ្តល់កសិណជំនួសកូនក្តីរបស់ខ្លួននៅក្នុងតុលាការទេ ប៉ុន្តែលទ្ធភាពក្នុងការធ្វើទំនាក់ទំនងយ៉ាងមានប្រសិទ្ធិភាពជាមួយតុលាការក្នុងនាមតំណាងឲ្យកូនក្តីរបស់ខ្លួន គឺចាំបាច់ត្រូវតែមាន ។ មធ្យោបាយសាមញ្ញបំផុតដែលមេធាវីទំនាក់ទំនងជាមួយតុលាការ (គឺតាមរយៈពាក្យសុំឬពាក្យបណ្តឹង) សេចក្តីសន្និដ្ឋានការពារសារណា និងបណ្តឹងសាទុក្ខ ។

លិខិតូបករណ៍ច្បាប់ទាំងនេះប្រហែលជាអាចគំរាមកំហែងដល់អ្នកមិនដឹងអំពីនីតិវិធីតុលាការ ។ គោលបំណងរបស់លិខិតទាំងនេះមិនស្មុគស្មាញទេ ហើយលិខិតទាំងនេះត្រូវដាក់ជូនតុលាការនៅក្នុងរបៀបមួយផ្ទាល់ ច្បាស់ ងាយស្រួលមើល និងមិនបច្ចេកទេសពេក ។

## ២) ពាក្យសុំ ឬពាក្យបណ្តឹង

### ក) គោលបំណង

គោលបំណងទូទៅនៃរាល់ពាក្យសុំទាំងអស់ដែលធ្វើឡើងក្នុងនាមជនជាប់ចោទ គឺដើម្បីសុំឲ្យចៅក្រមចាត់វិធានការដែលជាប្រយោជន៍ដល់ជនជាប់ចោទ ។ បើទោះបីជាមេធាវីជឿជាក់ថាតុលាការនឹងបដិសេធពាក្យសុំរបស់ខ្លួនក៏ដោយ ក៏មេធាវីត្រូវតែដាក់ពាក្យសុំនេះដែរ ដើម្បីឲ្យមានពាក្យសុំនេះនៅក្នុងសំណុំឯកសាររបស់តុលាការក្នុងករណីដែលសំណុំរឿងនេះត្រូវប្តឹងសាទុក្ខ ។ គោលបំណងពិសេសរបស់ពាក្យសុំនេះគឺអាស្រ័យទៅលើអ្វីដែលមេធាវីចង់សំណូមពរទៅតុលាការនៅពេលដាក់ពាក្យសុំ ។ ពាក្យសុំភាគច្រើនមានមូលដ្ឋានលើការពិចារណាអំពីភាពយុត្តិធម៌នៃដំណើរការកាត់ក្តី ។

ពាក្យសុំឬពាក្យបណ្តឹងដែលមេធាវីដាក់នៅក្នុងសាលាជំនុំជម្រះក្តីបទល្មើសអន្តរជាតិមុនៗៈ

- បណ្តឹងជំទាស់ទៅនឹងយុត្តាធិការរបស់តុលាការក្នុងការជំនុំជម្រះរឿងក្តីណាមួយ
- បណ្តឹងសុំបដិសេធភស្តុតាង
- បណ្តឹងស្នើសុំកោះហៅសាក្សី
- បណ្តឹងសុំការពារសាក្សី
- ពាក្យសុំធានាជនល្មើសឲ្យនៅក្រៅឃុំបណ្តោះអាសន្ន
- ពាក្យសុំឲ្យព្រះរាជអាជ្ញាបង្ហើបព័ត៌មាន
- ពាក្យសុំឲ្យព្រះរាជអាជ្ញាលើកលែងបទចោទប្រកាន់ណាមួយប្រឆាំងចុងចោទ
- បណ្តឹងបង្ខំឲ្យអាជ្ញាធររដ្ឋាភិបាលបញ្ចេញភស្តុតាងដោះបន្ទុក
- ពាក្យសុំបន្ថែមឬដកមេធាវី
- ពាក្យសុំពន្យារកាលបរិច្ឆេទសវនាការដើម្បីផ្តល់ពេលវេលាបន្ថែមទៀតដល់មេធាវីក្នុងការរៀបចំការការពារក្តីរបស់ខ្លួន ។ (ឧទាហរណ៍ៈ ប្រសិនបើមេធាវីចុងចោទរកឃើញសាក្សីសំខាន់យឺតពេល មេធាវីអាចស្នើសុំពេលវេលាបន្ថែមទៀតដើម្បីរៀបចំសាក្សី) ។

ពាក្យសុំឬពាក្យបណ្តឹងផ្សេងទៀតដែលមេធាវីទំនងជាដាក់ជូនអង្គជំនុំជម្រះវិសាមញ្ញៈ

- ប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសង្កេតក្នុងការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន
- ពាក្យសុំឲ្យដោះលែង ប្រសិនបើមានភស្តុតាងបន្ថែមបញ្ជាក់អំពីមូលហេតុដែលជនជាប់ចោទមិនគួរត្រូវឃុំខ្លួនបណ្តោះអាសន្ននោះទេ (សេចក្តីសម្រេចរបស់តុលាការទាក់ទងនឹងបញ្ហានេះអាចប្តឹងទៅសាលាកំពូលរបស់អង្គជំនុំជម្រះវិសាមញ្ញបាន)
- ពាក្យស្នើសុំឲ្យចៅក្រមបដិសេធភស្តុតាងរបស់ព្រះរាជអាជ្ញាដែលទទួលបានដោយមិនត្រឹមត្រូវ
- ពាក្យស្នើសុំឲ្យចៅក្រមស៊ើបអង្កេតចាត់វិធានការ ស៊ើបអង្កេតពិសេស

◆ បណ្តឹងសុំបដិសេធបទចោទប្រកាន់លើជនល្មើស

◆ បណ្តឹងបដិសេធដើម្បីបញ្ឈប់ចៅក្រម ។ បណ្តឹងនេះធ្វើឡើងនៅពេលដែលចៅក្រមស៊ើបអង្កេតឬចៅក្រមជំនុំជម្រះមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនឬបានរំលោភក្រមយុត្តិធម៌ដោយចេតនា ។

◆ បណ្តឹងជំទាស់ចិត្ត ក្នុងករណីដែលចៅក្រមស៊ើបអង្កេតឬចៅក្រមជំនុំជម្រះមានទំនាស់ផលប្រយោជន៍ ឬក្នុងករណីដែលចៅក្រមជំនុំជម្រះបំពេញតួនាទីជាចៅក្រមស៊ើបអង្កេតនៅក្នុងរឿងក្តីនោះ

### ខ) ទម្រង់

ពាក្យសុំឬពាក្យបណ្តឹងអាចធ្វើឡើងដោយមាត់ទទេឬជាលាយលក្ខណ៍អក្សរ ។ ព្រះរាជអាជ្ញាអាចជំទាស់ទៅនឹងពាក្យសុំរបស់មេធាវីចុងចោទតាមមាត់ទទេឬជាលាយលក្ខណ៍អក្សរ ។ បន្ទាប់មក ចៅក្រមនឹងចេញសេចក្តីសម្រេចបដិសេធដោយផ្នែក (ឬទាំងស្រុង) ឬគាំទ្រពាក្យសុំនោះដោយផ្នែក (ឬទាំងស្រុង) ។ សេចក្តីសម្រេចរបស់ចៅក្រមនេះអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេក៏បាន ។

### គ) ចំណុចសំខាន់ៗ

ពាក្យសុំគួរតែមានបញ្ជាក់ឲ្យបានច្បាស់លាស់នូវអ្វីដែលមេធាវីចុងចោទស្នើសុំចង់ឲ្យតុលាការធ្វើ ព្រមទាំងបញ្ជាក់អំពីមូលហេតុដែលតុលាការគួរតែគាំទ្រពាក្យសុំរបស់ខ្លួន ។ ពាក្យសុំនេះត្រូវយោងទៅដល់ច្បាប់ឬអង្គហេតុដែលពាក់ព័ន្ធទាំងឡាយដែលអាចមានឥទ្ធិពលលើសេចក្តីសម្រេចរបស់ចៅក្រម ។

## ២) សេចក្តីសន្និដ្ឋានការពារសារណា

### ក) គោលបំណង

គោលបំណងនៃសេចក្តីសន្និដ្ឋានការពារសារណាគឺដើម្បីៈ

◆ អះអាងអំពីទ្រឹស្តីនៃសំណុំរឿង ដោយបង្ហាញអំពីយុទ្ធសាស្ត្ររបស់មេធាវីចុងចោទក្នុងសវនាការទាំងមូល ។ ប្រការនេះគួរតែបញ្ចូលនូវការអះអាងល្អៗទាំងឡាយដែលបង្ហាញថាហេតុអ្វីបានជាជនជាប់ចោទគួរតែដោះលែង និងហេតុអ្វីបានព្រះរាជអាជ្ញាខកខានមិនបានបំពេញភារកិច្ចក្នុងការបង្ហាញភស្តុតាង ។

◆ ប្រមូលភស្តុតាងទាំងឡាយដែលតុលាការអាចទទួលយកបាន និងបង្ហាញអំពីអង្គហេតុទាំងមូលដែលថាហេតុអ្វីបានជាចុងចោទគួរតែត្រូវបានលើកលែងការចោទប្រកាន់ ។

### ខ) ទម្រង់

បើយោងទៅតាមច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា នៅពេលដែលសាក្សីទាំងអស់ត្រូវបានកោះហៅនិងភស្តុតាងទាំងអស់ត្រូវបានដាក់ជូនតុលាការរួចហើយ មេធាវីរបស់ជនរងគ្រោះ អ្នកតំណាងការិយាល័យព្រះរាជអាជ្ញា មេធាវីរបស់អ្នកទទួលខុសត្រូវស៊ីវិល និងមេធាវីរបស់ជនជាប់ចោទ នឹងថ្លែងផ្ទាល់មាត់នូវសេចក្តីសន្និដ្ឋានការពារសារណា ។ ដោយសារវាមិនទាន់ច្បាស់លាស់នៅឡើយទេថាតើជនរងគ្រោះមានសិទ្ធិធ្វើជាភាគីនៅក្នុងតុលាការខ្មែរក្រហម ឬតើជនជនរងគ្រោះមានសិទ្ធិធ្វើជាភាគីនៅក្នុងតុលាការខ្មែរក្រហមតាមរបៀបណានោះទេ នីតិវិធីប្រហែលជាខុសគ្នាបន្តិចបន្តួច នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។

មេធាវីអាចដាក់សេចក្តីថ្លែងសំអាងជាលាយលក្ខណ៍អក្សរដើម្បីឲ្យច្បាស់ថាសេចក្តីថ្លែងសំអាងរបស់ខ្លួនត្រូវបានដាក់បញ្ចូលទៅក្នុងឯកសាររបស់តុលាការក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍ ។

### គ) ចំណុចសំខាន់ៗ

នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានការពារសារណា មេធាវីត្រូវតែ÷

◆ អះអាងពីទ្រឹស្តីច្បាប់នៃសំណុំរឿងជាថ្មីម្តងទៀត ដោយបង្ហាញអំពីមូលហេតុដែលតុលាការគួរតែដោះលែងជនជាប់ចោទ

◆ រំឭកចៅក្រមអំពីភស្តុតាងដោះបន្ទុកដែលបានដាក់ជូនតុលាការ

◆ ឆ្លើយតបទៅនឹងភស្តុតាង និងការអះអាងផ្នែកច្បាប់របស់ព្រះរាជអាជ្ញា និងបង្ហាញថាហេតុអ្វីបានជាភស្តុតាង និងការអះអាងរបស់ព្រះរាជអាជ្ញាមិនគួរនាំទៅដល់ការផ្តន្ទាទោសជនជាប់ចោទ

◆ ពន្យល់ថាហេតុអ្វីបានជាព្រះរាជអាជ្ញាខកខានមិនបានបំពេញកាតព្វកិច្ចបង្ហាញភស្តុតាង

◆ បង្ហាញមូលហេតុដែលទោសរបស់ជនជាប់ចោទគួរតែត្រូវបន្ធូរបន្ថយប្រសិនបើចៅក្រមសម្រេចផ្តន្ទាទោសជនជាប់ចោទ

◆ យោងទៅលើតែភស្តុតាងទាំងឡាយដែលបានដាក់ជូនតុលាការរួចហើយ ។ អង្គហេតុថ្មីៗមិនអាចដាក់បញ្ចូលទៅក្នុងសេចក្តីសន្និដ្ឋានការពារសារណាទេ ។

## ៤) សេចក្តីសង្ខេបបណ្តឹងសាទុក្ខ

### ក) គោលបំណង

បណ្តឹងសាទុក្ខនឹងត្រូវធ្វើឡើងដោយមេធាវីចុងចោទ ប្រសិនបើមេធាវីមិនសុខចិត្តជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ។

គោលបំណងដែលមេធាវីចុងចោទធ្វើបណ្តឹងសាទុក្ខនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីបញ្ចុះបញ្ចូលអង្គជំនុំជម្រះវិសាមញ្ញនៃសាលាកំពូលឲ្យផ្លាស់ប្តូរសេចក្តីសម្រេចរបស់សាលាដំបូងដោយសារកំហុសអង្គហេតុឬអង្គច្បាប់ ។

ប្រសិនបើជនជាប់ចោទត្រូវលើកលែងការចោទប្រកាន់ ហើយព្រះរាជអាជ្ញាឬដើមចោទ (ប្រសិនបើដើមចោទត្រូវបានអនុញ្ញាត) ប្តឹងសាទុក្ខចំពោះការលើកលែងចោទប្រកាន់នេះ មេធាវីត្រូវសរសេរសេចក្តីសង្ខេបបណ្តឹងសាទុក្ខមួយឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខដែលធ្វើឡើងដោយព្រះរាជអាជ្ញាឬដើមចោទ (ប្រសិនបើដើមចោទត្រូវបានអនុញ្ញាត) ដើម្បីបញ្ជាក់អំពីមូលហេតុដែលតុលាការគួរតែរក្សាទុកសេចក្តីសម្រេចលើកលែងចោទប្រកាន់ឲ្យនៅដដែល ។

### ខ) ទម្រង់

នៅក្រោមច្បាប់កម្ពុជា បណ្តឹងសាទុក្ខអាចធ្វើដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ ប៉ុន្តែសេចក្តីសង្ខេបត្រូវតែធ្វើជាលាយលក្ខណ៍អក្សរឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខនៅចំពោះមុខតុលាការកំពូល ។ ប៉ុន្តែដោយសារអង្គជំនុំជម្រះវិសាមញ្ញនៃសាលាកំពូលដើរតួជាសាលាខទ្ទរណ៍និងបិទផ្លូវតវ៉ាផងនោះ សេចក្តីសង្ខេបទំនងជាធ្វើនៅក្នុងដំណាក់កាលខទ្ទរណ៍ ។

### គ) ចំណុចសំខាន់ៗ

សេចក្តីសង្ខេបបណ្តឹងសាទុក្ខត្រូវតែៈ

◆ បញ្ជាក់ឲ្យបានច្បាស់អំពីគោលបំណងរបស់ម្ចាស់បណ្តឹងសាទុក្ខ ជាពិសេសអ្វីដែលមេធាវីចង់ឲ្យតុលាការកំពូលផ្លាស់ប្តូរឬរក្សាទុកនៅដដែល

◆ សង្ខេបអំពីអង្គហេតុនៃសំណុំរឿង

◆ សង្ខេបអំពីអង្គច្បាប់ដែលពាក់ព័ន្ធ

◆ ផ្តល់ឲ្យនូវការអះអាងជាលាយលក្ខណ៍អក្សរដែលគួរឲ្យជឿមួយអំពីរបៀបដែលច្បាប់ទាំងនោះគួរតែអនុវត្តនៅក្នុងសំណុំរឿងនោះ

◆ ដោះស្រាយរាល់មូលហេតុទាំងអស់សម្រាប់ការប្តឹងសាទុក្ខ

### ទម្រង់នៃសេចក្តីសង្ខេបបណ្តឹងសាទុក្ខ

### ១) សេចក្តីផ្តើម

សេចក្តីសង្ខេបអំពីមូលហេតុនៃការប្តឹងសាទុក្ខ

### ២) សេចក្តីសំអាងរបស់សំណុំរឿង

អង្គហេតុរបស់សំណុំរឿងចេញពីការយល់ឃើញរបស់ជនជាប់ចោទ

### ៣) ការអះអាងផ្នែកច្បាប់

◆ ហេតុអ្វីបានជាសេចក្តីសម្រេចគួរតែផ្លាស់ប្តូរ

◆ អ្វីខ្លះជាច្បាប់ដែលពាក់ព័ន្ធ

◆ របៀបដែលអង្គច្បាប់ត្រូវអនុវត្តទៅនឹងអង្គហេតុ

### ៤) សេចក្តីសន្និដ្ឋាន

សេចក្តីសំអាងសង្ខេបអំពីអ្វីដែលម្ចាស់បណ្តឹងសាទុក្ខស្នើសុំឲ្យតុលាការផ្លាស់ប្តូរសេចក្តីសម្រេចពីលើកមុន ។

**ឯកសារហ្វឹកហ្វឺនផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# សេចក្តីថ្លែងការណ៍រួមរវាងឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងលោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ

## (នៅទីក្រុងភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៥)

**អង្គជំនុំជម្រះវិសាមញ្ញឈានដល់ការរៀបចំដំណាក់កាលចុងក្រោយ**

***ឯកឧត្តម ស៊ាន វិសុទ្ធៈ*** នៅក្នុងសប្តាហ៍នេះ យើងបានឈានទៅដល់ដំណាក់កាលថ្មីមួយទៀតនៅក្នុងដំណើរការដ៏វែងឆ្ងាយក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដោយមានជំនួយនិងការចូលរួមពីអន្តរជាតិ ។

លោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាលដែលទើបតែទទួលការតែងតាំងថ្មីៗ កំពុងតែដឹកនាំគណៈប្រតិភូរបស់អង្គការសហប្រជាជាតិបំពេញបេសកកម្មជាលើកដំបូងនៅប្រទេសកម្ពុជាចាប់ពីថ្ងៃទី៦ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ ។ គណៈប្រតិភូនេះមានសមាជិក៧នាក់រួមមាន ប្រធានដែលទើបតែទទួលការតែងតាំងថ្មីៗចំនួន៤នាក់ទទួលបន្ទុកកិច្ចការសន្តិសុខ, បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍, ថវិកានិងហិរញ្ញវត្ថុ, និងសេវាកម្មទូទៅ និងមន្ត្រីដទៃទៀតមកពីទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ក្នុងនោះមាន អេនម៉ារី អ៊ីបាណេ មកពីផ្នែកកិច្ចការនយោបាយរបស់អង្គការសហប្រជាជាតិ បំពេញតួនាទីជាអ្នកនាំពាក្យរបស់គណៈប្រតិភូនេះ និងលោក ដេវីដ ហាត់ឈិនសាន់ មកពីការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ ។

ដូចគ្នានឹងសមាជិករបស់លេខាធិការដ្ឋាននៃក្រុមការងារជំនុំជម្រះក្តីខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជាដែរ គណៈប្រតិភូកម្ពុជារួមមាន អ្នកតំណាងមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងដែនដីនគររូបនីយកម្ម រៀបចំក្រុង និងសំណង់, និងគណៈកម្មការសន្តិសុខសម្រាប់អង្គជំនុំជម្រះវិសាមញ្ញរបស់ក្រសួងមហាផ្ទៃ និងអាជ្ញាធរអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ជាតិ *(Nida)* ។

ចាប់ពីដំណើរទស្សនកិច្ចលើកចុងក្រោយរបស់ក្រុមការងាររបស់អង្គការសហប្រជាជាតិទទួលបន្ទុកជួយអង្គជំនុំជម្រះវិសាមញ្ញ *(UNAKRT)* មកកាន់កម្ពុជាកាលពីមួយឆ្នាំមុនមក មានរឿងរ៉ាវជាច្រើនបានកើតឡើង ។ អ្វីដែលសំខាន់បំផុតនៅក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះគឺការចូលជាធរមាននៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ បន្ទាប់ពីសន្និសីទរៃអង្គាសថវិកាដ៏ជោគជ័យនៅទីក្រុងញូវយ៉កកាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ ។

ចំណុចគន្លឹះផ្សេងទៀតគឺការតែងតាំងតំណែងរដ្ឋបាលជាន់ខ្ពស់របស់ភាគីទាំងសងខាង ការជ្រើសរើសមន្ត្រីច្បាប់ទាំងខាងកម្ពុជានិងអន្តរជាតិ ការបន្តរៀបចំធនធានសម្ភារៈសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនិងសម្រាប់ព័ត៌មានសាធារណៈ ក៏ដូចជាការហ្វឹកហ្វឺនចៅក្រមនិងមេធាវីកម្ពុជា ។

នៅខាងផ្នែកកម្ពុជា យើងមានអារម្មណ៍ថា ឥឡូវនេះយើងបានមកដល់ដំណាក់កាលចុងក្រោយនៃដំណើរការបង្កើតអង្គជំនុំជម្រះវិសាមញ្ញហើយ ។ យើងរង់ចាំសហការជាមួយក្រុមការងាររបស់អង្គការសហប្រជាជាតិនៅក្នុងដំណាក់កាលចុងក្រោយនៃការរៀបចំ និងបន្ទាប់មកឈានទៅដំណាក់កាលមួយទៀតដែលជាគោលបំណងរបស់យើងក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាចំពោះហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសរបស់យើងកាលពី២៥ឆ្នាំមុន ។ ខ្ញុំដឹងថាខ្ញុំអាចតំណាងឲ្យក្រុមការងារខាងភាគីកម្ពុជាថ្លែងអំណរគុណចំពោះសហគមន៍អន្តរជាតិដែលតំណាងដោយអង្គការសហប្រជាជាតិ

ដែលបានចូលរួមជាមួយយើងក្នុងកិច្ចការជាប្រវត្តិសាស្ត្រនេះ ។

**លោកស្រី មីសែល លី:** គោលបំណងរបស់គណៈប្រតិភូរបស់អង្គការសហប្រជាជាតិនៅពេលនេះគឺដើម្បីជំរុញការរៀបចំទាំងនេះឲ្យឈានទៅដល់ដំណាក់កាលថ្មីមួយទៀត តាមរយៈការពិនិត្យមើលឯកសារដែលបានរៀបចំនៅក្នុងអំឡុងពេលនៃបេសកកម្មបច្ចេកទេសទាំងបីលើករបស់ក្រុមការងាររបស់អង្គការសហប្រជាជាតិទទួលបន្ទុកជួយអង្គជំនុំជម្រះវិសាមញ្ញធៀបទៅនឹងអ្វីដែលមាននៅពេលនេះ, តាមរយៈការមើលឲ្យពិស្តារអំពីរបៀបនិងពេលវេលាដែលអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមដំណើរការរបស់ខ្លួន, និងដើម្បីឈានទៅរកការបញ្ចប់កិច្ចព្រមព្រៀងបន្ទាប់បន្សំពីរបន្ថែមទៀតស្តីអំពីការប្រើប្រាស់សម្ភារៈអគារ និងសេវាកម្ម និងអំពីសន្តិសុខនិងសុវត្ថិភាព ដែលមានចែងរួចហើយនៅក្នុងកិច្ចព្រមព្រៀងចម្បងដែលបានចុះហត្ថលេខានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ និងដែលអនុម័តរួចហើយដោយមហាសន្និបាតអង្គការសហប្រជាជាតិនិងរដ្ឋសភាជាតិរបស់កម្ពុជា ។

ពីម្សិលមិញ គណៈប្រតិភូរបស់យើងមានកិត្តិយសបានជួបជាមួយលោកឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារជំនុំជម្រះក្តីខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្លាស់ប្តូរយោបល់ទៅវិញទៅមក ។

បេសកកម្មនេះចាប់ផ្តើមដោយគណៈប្រតិភូពីរដែលបានធ្វើកិច្ចប្រជុំដ៏មានផ្លែផ្កាជាលើកទីមួយ ដើម្បីបង្កើតរបៀបវារៈសម្រាប់បេសកកម្មដែលមានរយៈពេល១០ថ្ងៃនេះ និងបង្កើតបរិយាកាសកក់ក្តៅសម្រាប់ទំនាក់ទំនងការងាររបស់ភាគីទាំងពីរ ។ ចាប់តាំងពីកិច្ចប្រជុំដំបូងនេះមក ប្រតិភូអង្គការសហប្រជាជាតិបានធ្វើទស្សនកិច្ចទៅកាន់ប្រទេសម្ចាស់ជំនួយធំៗនិងរដ្ឋដែលចាប់អារម្មណ៍ ។ ការឆ្លើយតបចំពោះដំណើរទស្សនកិច្ចទាំងនេះគឺវិជ្ជមាន ហើយសហគមន៍អន្តរជាតិបានយល់ព្រមផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់យើងតាមមធ្យោបាយជាក់ស្តែងនៅពេលដែលយើងចាប់ផ្តើមការងារ ។

នៅពេលដែលសមាជិកទាំងអស់របស់គណៈប្រតិភូអង្គការសហប្រជាជាតិបានមកដល់ ដំណើរទស្សនកិច្ចមួយនឹងរៀបចំឡើងទៅកាន់ទីតាំងសម្រាប់រៀបចំជាអង្គជំនុំជម្រះវិសាមញ្ញនៅឃុំកំបូល ហើយកិច្ចប្រជុំជំនាញមួយចំនួននឹងត្រូវធ្វើឡើងដើម្បីរៀបចំផែនការល្អិតល្អន់សម្រាប់ការឈានចូលទៅដល់ដំណាក់កាលដំណើរការនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅពេលខាងមុខ ។

ឧបសគ្គសំខាន់បំផុតដែលនៅសល់គឺទាក់ទងទៅនឹងការស្វែងរកមូលនិធិសម្រាប់ធានាដំណើរការរយៈពេលបីឆ្នាំរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ នៅពេលបច្ចុប្បន្ននេះ ទឹកប្រាក់៤៣លានដុល្លារដែលជាចំណែកថវិការបស់អង្គការសហប្រជាជាតិគឺនៅខ្វះតែបន្តិចបន្តួចទៀតប៉ុណ្ណោះ ប៉ុន្តែខាងភាគីកម្ពុជានៅខ្វះថវិកាចំនួន១០,៨លានដុល្លារទៀត ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែអំពាវនាវទៅរដ្ឋាភិបាលផ្សេងៗរកជំនួយទ្វេភាគីជាបន្ទាន់ដើម្បីបំពេញចំណែកថវិកាដែលខ្វះខាតនេះ ។ ប្រទេសមួយចំនួនកំពុងតែពិចារណាអំពីរបៀបដែលខ្លួនអាចឆ្លើយតបយ៉ាងពេញចិត្តចំពោះការអំពាវនាវនេះ ហើយយើងសង្ឃឹមថា បញ្ហានេះនឹងអាចដោះស្រាយបានក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ ។

យើងមានសេចក្តីសប្បាយរីករាយ និងត្រៀមខ្លួនរួចជាស្រេចដើម្បីចាប់ផ្តើមការងារនេះ ។ យើងដឹងថា នេះជាកិច្ចការដ៏លំបាក ប៉ុន្តែជាកិច្ចការមួយដែលយើងបានប្តេជ្ញាចិត្តថានឹងប្រឹងប្រែងបំពេញឲ្យអស់លទ្ធភាពរបស់យើង ។ ខ្ញុំបានជ្រើសរើសសមាជិកសំខាន់ៗរបស់ក្រុមការងារវាយតម្លៃបឋមរបស់អង្គការសហប្រជាជាតិពីក្នុងចំណោមអ្នកមានសមត្ថភាពបំផុតនៅក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ដោយមើលជាពិសេសទៅលើបទពិសោធន៍ជំនាញរបស់អ្នកទាំងនោះនៅក្នុងសាលាជំនុំជម្រះក្តីចម្រុះនិងសាលាជំនុំជម្រះក្តីអន្តរជាតិផ្សេងៗ ។ យើងចង់ចែករំលែកការអនុវត្តល្អៗបំផុត និងសហការណ៍ជាមួយភាគីកម្ពុជា ក្នុងគោលបំណងដើម្បីបង្កើតប្រវត្តិវិជ្ជមាននៅក្នុងប្រទេសនេះ ប៉ុន្តែយើងក៏ដឹងដែរថាមានអ្វីៗជាច្រើនដែលយើងត្រូវការរៀនសូត្រអំពីប្រពៃណីវប្បធម៌ដែលមានលក្ខណៈបុរាណនិងសម្បូរបែបរបស់កម្ពុជា ។

# កិច្ចការមួយដែលរួមចំណែកធ្វើឱ្យតុលាការខ្មែរក្រហមអាចទទួលយកបាន

តាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌក្នុងស្រុកក៏ដូចជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ផ្នែកមួយដ៏សំខាន់ដែលនឹងធ្វើឲ្យដំណើរការកាត់សេចក្ដីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យអាចទទួលយកបាន គឺសិទ្ធិរបស់ចុងចោទឬជនជាប់ចោទដែលច្បាប់បានកំណត់ជូន ត្រូវបានធានាឲ្យបានល្អឥតខ្ចោះតាមដែលអាចធ្វើទៅបាន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើកិច្ចការនេះតាមរយៈការរៀបចំឲ្យមានវគ្គហ្វឹកហ្វឺនច្បាប់ ។

នេះជាលើកទី៤នៅក្នុងឆ្នាំ២០០៥ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំឲ្យមានវគ្គហ្វឹកហ្វឺនច្បាប់ដែលផ្ដោតការយកចិត្តទុកដាក់ទៅលើប្រធានបទដើម្បីតម្រូវតាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌដូចបានបង្ហាញជូន ។ ក្នុងឆ្នាំ២០០៥នេះ វគ្គហ្វឹកហ្វឺនច្បាប់បានបញ្ចប់ជាស្ថាពរកាលពីថ្ងៃសុក្រទី៣០ ខែកញ្ញា ក្រោមការជួយឧបត្ថម្ភពីការិយាល័យទទួលបន្ទុកការងារសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនៃក្រសួងការបរទេសសហរដ្ឋអាមេរិក តាមរយៈជំនួយអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋមេរិក រដ្ឋាភិបាលហុល្លង់ និងរដ្ឋាភិបាលស៊ុយអែដ ។

វគ្គហ្វឹកហ្វឺននេះមានសិក្ខាកាមចូលរួមយ៉ាងហោចណាស់ចំនួន៨៤នាក់មកពីអង្គការក្រៅរដ្ឋាភិបាលនានា អ្នកកាសែត មេធាវី និស្សិតច្បាប់ និស្សិតមេធាវី ព្រមទាំងប្រជាពលរដ្ឋសាមញ្ញដែលធ្លាប់រងគ្រោះក្នុងរបបវាលពិឃាដមកពីតាមបណ្ដាខេត្តមួយចំនួនដូចជា ខេត្តព្រៃវែង កំពង់ចាម កំពត កណ្ដាល ពោធិ៍សាត់ កំពង់ធំ និងស្វាយរៀង ។

ផ្អែកលើគោលការណ៍ច្បាប់ព្រហ្មទណ្ឌខាងលើ វគ្គហ្វឹកហ្វឺនច្បាប់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំឡើងដោយប្រយ័ត្នប្រយែងបានផ្ដោតការយកចិត្តទុកដាក់ទៅលើ «ការការពារចុងចោទនៅក្នុងបរិបទយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិជាទូទៅ និងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ដែលហៅកាត់ថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ។

ពិស្ដារជាងនេះ សិក្ខាកាមបានយល់ជ្រួតជ្រាបថែមទៀតទាក់ទិនទៅនឹងៈ សេចក្ដីផ្ដើមទូទៅអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម, សិទ្ធិរបស់ចុងចោទ, តួនាទីរបស់មេធាវីចុងចោទ, ការលំបាកចម្បងៗមេធាវីចុងចោទអាចប្រឈមមុខ, សិទ្ធិនិងកាតព្វកិច្ចរបស់មេធាវីចុងចោទនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម, ប្រភេទផ្សេងៗនៃការការពារក្ដី, បណ្ដឹងស្នើសុំរបស់មេធាវីចុងចោទមុនពេលបើកសវនាការ, និង ការធ្វើទន្ទឹករណ៍ចុងក្រោយរបស់មេធាវីចុងចោទនៅពេលបើកសវនាការ ។

ប្រធានបទទាំងប៉ុន្មានដែលរៀបរាប់ខាងលើត្រូវបានបង្ហាត់បង្រៀនដោយគ្រូឧទ្ទេសនាមខ្មែរពីររូបនិងបរទេសប្រាំបួនរូបដែលមានបទពិសោធន៍ខ្ពស់ទាក់ទិននឹងការការពារក្ដីចុងចោទពីបទឧក្រិដ្ឋកម្មនៅតុលាការក្នុងស្រុករបស់ខ្លួន ដូចជានៅតុលាការប្រទេសអាមេរិក ហុល្លង់ អង់គ្លេស បារាំង និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (អាយស៊ីធីវ៉ាយ) រ៉្វាន់ដា (អាយស៊ីធីអ័រ) តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន និងតុលាការសិទ្ធិមនុស្សសម្រាប់សហគមន៍អឺរ៉ុបជាដើម ។

នៅថ្ងៃបញ្ចប់វគ្គហ្វឹកហ្វឺន សិក្ខាកាមទាំងអស់តម្រូវឲ្យបំពេញទម្រង់វាយតម្លៃម្នាក់មួយសន្លឹក ដែលតាមរយៈនេះមានសិក្ខាកាមខ្លះសរសេរថា «ខ្ញុំចូលចិត្តមេរៀនអំពីតួនាទីរបស់មេធាវីចុងចោទនៅចំពោះមុខតុលាការកាត់សេចក្ដីមេដឹកនាំខ្មែរក្រហម» ខ្លះទៀតសរសេរថា «ខ្ញុំចូលចិត្តមេរៀនអំពីសិទ្ធិរបស់ចុងចោទ» «ខ្ញុំចូលចិត្តវគ្គហ្វឹកហ្វឺននេះពីព្រោះថាធ្វើឲ្យខ្ញុំយល់ជ្រួតជ្រាបអំពីច្បាប់ដែលនឹងត្រូវយកទៅអនុវត្តនៅក្នុងតុលាការខ្មែរក្រហម និងយល់ជ្រួតជ្រាបអំពីមាត្រា១៤និង១៥នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ» «ការបង្ហាត់បង្ហាញអំពីសិទ្ធិចុងចោទនិងតួនាទីរបស់មេធាវីចុងចោទ ជួយឲ្យប្រជាពលរដ្ឋយល់ដឹងអំពីដំណើរការតុលាការ និងកាត់បន្ថយការគាបសង្កត់ផ្នែកសង្គមទៅលើមេធាវីចុងចោទ» ។ល។

**ឌ៉ាន់ថាន់ ពៅ ដារ៉ា**

# តើអង្គជំនុំជម្រះវិសាមញ្ញបម្រើប្រជាជនបានល្អដែរឬទេ?

ថ្ងៃនេះ អង្គការសហប្រជាជាតិបានចាប់ផ្តើមប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាម្តងទៀត ។ លើកនេះ បេសកកម្មរបស់ក្រុមការងារអង្គការសហប្រជាជាតិគឺដើម្បីរៀបចំកិច្ចការភ័ស្តុភារសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលបានពន្យារពេលយូរមកហើយក្នុងការកាត់សេចក្តីមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យដែលទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនជិតពីរលាននាក់ក្នុងចន្លោះពីខែមេសាឆ្នាំ១៩៧៥ដល់ខែមករាឆ្នាំ១៩៧៩ ។

ក្រុមការងាររបស់អង្គការសហប្រជាជាតិដែលដឹកនាំដោយលោកស្រី មីសែល លី ដែលទទួលការតែងតាំងកាលពីខែសីហានឹងបំពេញការងាររបស់ខ្លួនដោយសម្របសម្រួលជាមួយក្រុមការងាររដ្ឋាភិបាលទទួលបន្ទុករៀបចំអង្គជំនុំជម្រះវិសាមញ្ញ ។ លោកស្រី លី នឹងធ្វើសន្និសីទកាសែតលើកទីមួយនៅថ្ងៃទី៩ ខែធ្នូ នៅទីក្រុងភ្នំពេញ ជាមួយនឹងឯកឧត្តម ស៊ាន វិសុទ្ធ ដែលទើបតែទទួលការតែងតាំងដោយព្រះរាជក្រឹត្យនាពេលថ្មីៗនេះឲ្យធ្វើជាប្រធានការិយាល័យរដ្ឋបាល ។

បើយោងតាមសម្តីរបស់អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិ ស្តេហ្វាន ឌូចារិក បានឲ្យដឹងថា ការងារនេះធ្វើឡើងទន្ទឹមគ្នានឹងពេលដែលអង្គការសហប្រជាជាតិកំពុងតែធ្វើសម្ភាសន៍បេក្ខជនដែលជាប់ក្នុងជម្រើសលើកទីមួយរួចហើយ សម្រាប់តំណែងចៅក្រម សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិនិងចៅក្រមអន្តរជាតិ សម្រាប់អង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

កាលពីដើមសប្តាហ៍នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាស្ថាប័នឯករាជ្យមិនរកប្រាក់ចំណេញស្រាវជ្រាវអំពី«របបវាលពិឃាត» បានសម្តែងនូវការព្រួយបារម្ភជុំវិញបញ្ហាតម្លាភាពនៃដំណើរការកាត់សេចក្តីនិងរចនាសម្ព័ន្ធមិនគ្រប់គ្រាន់សម្រាប់ការចូលរួមរបស់ប្រជាជនកម្ពុជា ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាសហការីរបស់លោក ជឿជាក់ថា ជោគជ័យរបស់អង្គជំនុំជម្រះវិសាមញ្ញជាសំខាន់គឺត្រូវមើលអំពីរបៀបដែលប្រជាជនកម្ពុជាដោះស្រាយជាមួយអារម្មណ៍និងក្តីសង្ឃឹមរបស់គាត់ ។

នៅក្នុងចំណោមប្រជាជាតិដែលជួបប្រទះអំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រទំនើបនេះ ប្រជាជនកម្ពុជាបានរង់ចាំមើលការបិទទំព័រប្រវត្តិសាស្ត្រនេះនិងរង់ចាំយុត្តិធម៌អស់រយៈពេល២៦ឆ្នាំមកហើយ ពោលគឺខុសគ្នាពីជនរងគ្រោះដែលរួចជីវិតពីក្រុមណាហ្ស៊ីនៅប្រទេសអាល្លឺម៉ង់ ជនរងគ្រោះពីរបបមេឡូសេវិកនៅប្រទេសយូហ្គោស្លាវី ជនរងគ្រោះហ៊ូទូរបស់ប្រទេសរ៉ាន់ដា និងជនរងគ្រោះរបស់សាដាមនៅប្រទេសអ៊ីរ៉ាក់ ។

ការរង់ចាំអស់រយៈពេលយូរដូច្នេះមានន័យថា អង្គជំនុំជម្រះវិសាមញ្ញមានន័យផ្សេងសម្រាប់ប្រជាជនកម្ពុជា ។ នេះបើពិនិត្យមើលតួលេខនៃការវាយតម្លៃដែលធ្វើឡើងដោយគម្រោងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺ«គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្ម» ដែលទទួលការឧបត្ថម្ភមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ថាប្រជាជនកម្ពុជាប្រមាណពីរនាក់ក្នុងចំណោមប្រាំនាក់មានជំងឺបាក់ស្បាត (PTSD) ។

អ្នកការទូតបស្ចិមប្រទេសម្នាក់បានផ្តល់យោបល់ថា នៅក្រោមការគ្រប់គ្រងរយៈពេលបីឆ្នាំប្រាំបីខែម្ភៃថ្ងៃរបស់ខ្មែរក្រហមប្រជាជនជិតពីរលាននាក់នៅក្នុងចំណោមប្រជាជនសរុប៨លាននាក់បានស្លាប់បាត់បង់ជីវិតមិនថាអ្នកទាំងនោះជា«ជនរងគ្រោះឬជាជនដៃដល់ (ជាអតីតខ្មែរក្រហម)»ទេ ។

អ្នកសង្កេតការណ៍ដែលមានទស្សនៈវិជ្ជមានចំពោះសាលាជំនុំជម្រះក្តីនេះបាននិយាយថា ថ្វីត្បិតតែអង្គជំនុំជម្រះវិសាមញ្ញ

ប្រាកដជាអាចធ្វើឲ្យប៉ះពាល់ដល់ជំរៅចាស់ក៏ពិតមែន ប៉ុន្តែវាប្រាកដជាអាចជួយឲ្យប្រជាជនកម្ពុជាឆ្លើយតបទៅនឹងសំណួរមួយចំនួនទាក់ទងនឹងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា ។ម្យ៉ាងទៀត អង្គជំនុំជម្រះវិសាមញ្ញក៏អាចបង្កើតជាការពិភាក្សាជាច្រើននៅក្នុងចំណោមប្រជាជនកម្ពុជាអំពីប្រព័ន្ធយុត្តិធម៌ដែលគាត់ចង់បាន និងអំពីថាតើប្រព័ន្ធយុត្តិធម៌របស់គាត់មានដំណើរការឬទេ ។

អង្គជំនុំជម្រះវិសាមញ្ញអាចជាការរំឭកដល់ប្រជាជនកម្ពុជាជំនាន់ក្រោយអំពីឧក្រិដ្ឋកម្មដែលមិនអាចរកពាក្យរៀបរាប់បាន ដែលឪពុកម្តាយបងប្អូនរបស់ខ្លួនបានឆ្លងកាត់នៅក្រោមរបបខ្មែរក្រហម ហើយប្រហែលជាអាចជំរុញឲ្យមនុស្សជំនាន់ក្រោយកសាងប្រទេសកម្ពុជាមួយដែលពោរពេញទៅដោយសន្តិភាពនិងស្ថិរភាព ។

កន្លងមក រដ្ឋាភិបាលកម្ពុជាបានទុកសាលាជំនុំជម្រះក្តីនេះជា "ប្រធានបទមួយដែលមិនសូវចង់ឲ្យសាធារណជនដឹង" នៅក្នុងគោលនយោបាយព័ត៌មានសាធារណៈរបស់ខ្លួន ។ រាជរដ្ឋាភិបាលមិនទាន់ធ្វើសេចក្តីប្រកាសណាមួយអំពីគោលនយោបាយព័ត៌មានសាធារណៈចំពោះអង្គជំនុំជម្រះវិសាមញ្ញនៅឡើយ ។ នៅក្នុងការជូនដំណឹងសាធារណជនអំពីអង្គជំនុំជម្រះវិសាមញ្ញកាលពីឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលបានបោះពុម្ពកូនសៀវភៅមួយដែលណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។

មានលេចឮសម្តីនៅក្នុងទីក្រុងភ្នំពេញថា បេក្ខជនដែលបានជ្រើសរើសឲ្យធ្វើជាប្រធានកម្មវិធីព័ត៌មានសាធារណៈរបស់រដ្ឋាភិបាលជុំវិញអង្គជំនុំជម្រះវិសាមញ្ញគឺជាជនបរទេស ។ ការណ៍នេះធ្វើឲ្យចុះថយនូវភាពមធ្យ័តក្នុងការធានាតម្លាភាពរបស់អង្គជំនុំជម្រះវិសាមញ្ញនិងការចូលរួមរបស់ប្រជាជននៅក្នុងដំណើរការនេះ ។

ការងារភាគច្រើនដើម្បីរៀបចំការចូលរួមរបស់សាធារណជននៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្លាក់ទៅលើមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការសិទ្ធមនុស្សដទៃទៀត ។ គម្រោងមួយចំនួនត្រូវបានបំពេញនៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ដូចជា ÷

◆ *គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្មៈ* គឺជាគម្រោងមួយដែលចងក្រងការរំលោភសិទ្ធិមនុស្សកាលពីអតីតកាលនៅក្នុងតំបន់មួយចំនួននៅក្នុងប្រទេស ដោយបង្កើតបរិយាកាសមួយដែលអនុញ្ញាតឲ្យជនរងគ្រោះនៃអំពើទារុណកម្មអាចចេញមុខនិយាយអំពីតម្រូវការផ្នែកស្មារតីរបស់ខ្លួនក៏ដូចជារបស់ក្រុមគ្រួសារនិងសហគមន៍តាមរយៈការផ្តល់ប្រឹក្សា ។ គម្រោងនេះក៏បានព្យាយាមស្វែងយល់អំពីការយល់ឃើញរបស់អ្នករួចរស់ជីវិតចំពោះការចងចាំនិងយុត្តិធម៌ដើម្បីបង្កើនការផ្សះផ្សាសហគមន៍នៅក្នុងប្រទេស ។

◆ *គម្រោងឯកសាររស់ៈ* គម្រោងនេះនឹងនាំយកប្រជាជនប្រមាណ១២០០នាក់ (ក្នុងមួយក្រុមមានប្រមាណ៣០នាក់និងក្នុងរយៈពេលមួយសប្តាហ៍) ពីខេត្តផ្សេងៗរបស់ប្រទេសឲ្យមកចូលរួមស្តាប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញដែលមានរយៈពេល៣ឆ្នាំ ។ គោលបំណងនេះគឺដើម្បីកសាងសន្ទុះនៃលទ្ធិប្រជាធិបតេយ្យក្នុងការចូលរួមនិងសេរីភាពនៃការទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា ។

◆ *ការិយាល័យព័ត៌មានសាធារណៈ* គម្រោងនេះបានបើកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីខែមេសាឆ្នាំ២០០៤ ដើម្បីអនុញ្ញាតឲ្យអ្នកស្រាវជ្រាវ អ្នកសារព័ត៌មាន សាធារណជនទូទៅអាចមើលឯកសារអំពីរបបខ្មែរក្រហមប្រមាណជាង៦សែនទំព័រ ញត្តិ បទសម្ភាសរបស់អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម និងឯកសារផ្សេងៗទៀតដែលអាចប្រើជាភស្តុតាងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

រដ្ឋាភិបាលកម្ពុជាដែលបានអូសបន្លាយសាលាជំនុំជម្រះក្តីអស់រយៈពេលប្រាំពីរឆ្នាំកន្លងមកហើយនេះ នៅតែជាភាគីមួយដែលស្ទាក់ស្ទើរក្នុងការបិទទំព័រប្រវត្តិសាស្ត្រនិងក្នុងការស្វែងរកយុត្តិធម៌ ។ មូលហេតុនៃការអូសបន្លាយនេះហាក់បីជាហួសពីការដែលថាអ្នកមានតំណែងខ្ពស់នៅក្នុងរដ្ឋាភិបាលបានចូលរួមនៅក្នុងរបបខ្មែរក្រហម ។ អង្គជំនុំជម្រះវិសាមញ្ញទំនងជាបង្កើតបទដ្ឋានយុត្តិធម៌និងភាពស្របច្បាប់មួយដែលខុសប្លែកពីមុន ហើយដែលរដ្ឋាភិបាលកម្ពុជាមិនទាន់ត្រៀមខ្លួនដើម្បីផ្តល់ឲ្យប្រជា

ពលរដ្ឋរបស់ខ្លួនសូម្បីតែបន្ទាប់ពីរយៈពេល២៧ឆ្នាំនៃការកាន់ អំណាចរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏ដោយ ។

នៅក្នុងឆ្នាំ១៩៩០ អង្គការសហប្រជាជាតិបានបង្កើតជាប្រវត្តិសាស្ត្រមួយដោយបានបង្កើតជា "អាជ្ញាធរបណ្តោះអាសន្ន" លើកទីមួយដែលមិនធ្លាប់មានពីមុនមកនៅក្នុងរដ្ឋអធិបតេយ្យភាព ហើយជាបេសកកម្មថែរក្សាសន្តិភាពដែលធំបំផុតរបស់ពិភពលោក ។ នៅពេលនេះអង្គការសហប្រជាជាតិអាចបង្កើតប្រវត្តិសាស្ត្រម្តងទៀតដោយការធានាថាអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមអាចបិទទំព័រប្រវត្តិសាស្ត្រនិងទទួលយុត្តិធម៌ តាមរយៈតម្លាភាពរបស់អង្គជំនុំជម្រះវិសាមញ្ញនិងការចូលរួមយ៉ាងសកម្មរបស់សាធារណជន ។

ដោយសារសាលាជំនុំជម្រះក្តីនេះមានអត្ថន័យផ្សេងសម្រាប់ប្រជាជនកម្ពុជា ការខ្វែងគំនិតគ្នាដែលត្រូវបានគិតថាជាជំពូកឈឺចាប់បំផុតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជានឹងបើកឡើងជាថ្មីម្តងទៀតសម្រាប់ការសាកល្បងមួយយ៉ាងល្អិតល្អន់ ប៉ុន្តែមានមធ្យោបាយជាច្រើនដើម្បីដោះស្រាយការខ្វែងគំនិតទាំងនេះដោយសន្តិវិធីនិងដោយមានការយល់ស្របគ្នាយ៉ាងទូលំទូលាយ ។

ដំណោះស្រាយទាំងនេះប្រហែលជារួមទាំងការវាយតម្លៃដោយអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា របាយការណ៍សារព័ត៌មាន ការវាយតម្លៃដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិនិងអង្គការសិទ្ធិមនុស្ស និងដែលសំខាន់បំផុតគឺទស្សនៈរបស់ប្រជាជនកម្ពុជាថាតើអង្គជំនុំជម្រះវិសាមញ្ញបានបម្រើផលប្រយោជន៍ឲ្យប្រជាជនបានត្រឹមត្រូវដែរឬទេ ។

**ឆូសារ៉ា ថៃថាវ៉ាត់**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

- រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

ព័ត៌មានបន្ថែមសូមទាក់ទងតាមទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# ហេតុអ្វីបានជាយើងប្រើពាក្យ "Tribunal" ជំនួសឱ្យពាក្យ "Trials"?

### ១) *ហេតុអ្វីបានជាយើងប្រើពាក្យ* "Tribunal" *(សាលាជំនុំជម្រះក្តី) ជំនួសពាក្យ* "Trials" *(សវនាការជំនុំជម្រះក្តី)* ?

*នៅទីនេះ ខ្ញុំចង់បែងចែកពាក្យទាំងពីរនេះឲ្យច្បាស់លាស់ ។ ទីមួយ មានស្ថាប័នមួយ (អង្គជំនុំជម្រះវិសាមញ្ញ) ដែលនឹងត្រូវបង្កើតឡើងនៅពេលឆាប់ៗខាងមុខនេះដើម្បីជំនុំជម្រះបទឧក្រិដ្ឋកម្មមួយចំនួនដែលប្រព្រឹត្តនៅក្នុងរយៈកាលដែលបានកំណត់ជាក់ច្បាស់នៅក្នុងប្រវត្តិសាស្ត្រដោយជនដែលដល់មួយចំនួនតូចដែលត្រូវបានចោទប្រកាន់ ។ នៅពេលយើងនិយាយពី "Tribunal" យើងនិយាយដល់ខ្លឹមសារឬដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ "Tribunal" (ឬសាលាជំនុំជម្រះក្តី) ត្រូវបង្កើតឡើងសិនមុនពេលដែល "Trials" (ឬសវនាការ) អាចចាប់ផ្តើម ហើយ "សាលាជំនុំជម្រះក្តី" អាចមានជីវិតមួយរយៈពេលទៀតបន្ទាប់ពី "សវនាការ" ទាំងអស់ត្រូវបញ្ចប់ ។*

*ពេលខ្លះដែលខ្ញុំមិនបានប្រយ័ត្ន ខ្ញុំប្រើពាក្យថា "Khmer Rouge Trials" នៅពេលខ្ញុំនិយាយសំដៅទៅសំណុំរឿងទាំងឡាយដែលនឹងត្រូវជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញ ។ ប៉ុន្តែបើនិយាយថា សំណុំរឿងទាំងអស់នេះជា "EC Trials" គឺច្បាស់ជាងដោយសារតែអតីតសមាជិករបស់បក្សកុម្មុយនិស្តកម្ពុជា របបកម្ពុជាប្រជាធិបតេយ្យ ឬអង្គការខ្មែរក្រហម អាចត្រូវជំនុំជម្រះនៅក្នុងសវនាការនៃប្រព័ន្ធច្បាប់ដទៃទៀត ឬផ្នែកផ្សេងទៀតនៃប្រព័ន្ធច្បាប់កម្ពុជា ។ ឧទាហរណ៍ត្រង់ចំណុចនេះគឺសវនាការកាត់ទោសអតីតមន្ត្រីខ្មែរក្រហមដែលបានសម្លាប់ភ្ញៀវទេសចរណ៍មួយចំនួនក្នុងអំឡុងទសវត្សរ៍១៩៩០ ។*

*ខ្ញុំគិតថា បើប្រើឲ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស គួរតែហៅស្ថាប័នតុលាការនេះថា "EC" (អង្គជំនុំជម្រះវិសាមញ្ញ) ឬ "Tribunal" (សាលាជំនុំជម្រះក្តី) និងត្រូវហៅសវនាការទាំងនោះថា "EC Trials" (សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ) ។*

### ២) *តើយើងគួរប្រើពាក្យ "ខ្មែរក្រហម" ដែរឬទេ?*

*ខ្ញុំប្រើពាក្យនេះនៅក្នុងសៀវភៅមួយដែលបម្រុងនឹងបោះពុម្ពផ្សាយ ដើម្បីធានាថាអ្នកអានដែលមិនមែនជាអ្នកជំនាញអាចយល់ពីអ្វីដែលសរសេរនៅក្នុងសៀវភៅនេះ ។ អ្នកអាននឹងដើរហួសកន្លែងតាំងសៀវភៅជាមិនខានបើគាត់ឃើញសៀវភៅដែលមានចំណងជើងថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ។ ការដាក់ចំណងជើងសៀវភៅថា "សាលាជំនុំជម្រះក្តីខ្មែរក្រហម" (Khmer Rouge Tribunal) នឹងជួយឲ្យអ្នកអានងាយស្រួលយល់អំពីចំណងជើង និងទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអានឲ្យអានសៀវភៅនេះទៀតផង ហើយប្រសិនបើចាំបាច់ យើងអាចផ្តល់ការពន្យល់នៅក្នុងសេចក្តីផ្តើមរបស់សៀវភៅដើម្បីឲ្យពាក្យនេះប្រើប្រាស់បានត្រឹមត្រូវ ។*

*សម្រាប់លក្ខណៈច្បាប់ឬអ្នកជំនាញស្រាវជ្រាវ វាច្បាស់ជាងក្នុងការហៅបុគ្គលទាំងនោះថាជាសមាជិករបស់របបកម្ពុជាប្រជាធិបតេយ្យ ឬសមាជិករបស់បក្សកុម្មុយនិស្តកម្ពុជា ដោយសារតែពាក្យ "ខ្មែរក្រហម" មានន័យមិនសូវច្បាស់លាស់ទេ ។ ដោយសារសាលាជំនុំជម្រះក្តីនេះនឹងជំនុំជម្រះតែសំណុំរឿងនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយសមាជិករបស់របបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ការប្រើប្រាស់ពាក្យ "សាលាជំនុំជម្រះក្តីខ្មែរក្រហម" គឺបង្កប់អត្ថន័យថា យុត្តាធិការរបស់សាលាជំនុំជម្រះក្តីនេះគឺកំណត់ជាពិសេសកាត់សេចក្តីអតីតសមាជិកខ្មែរក្រហម ប៉ុន្តែតាមការពិត យុត្តាធិការនេះកំណត់ត្រឹមតែ "ខ្មែរក្រហម" មួយចំនួនដែលជាមន្ត្រីកាន់តំណែងសំខាន់នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ។*

**ចន ឆរតីអារី**

### អ្វីទៅជា "ខ្មែរក្រហម" ?

***ទស្សនៈទី១ៈ*** *ពេលដែលខ្ញុំនិយាយអំពីខ្មែរក្រហម ខ្ញុំចង់និយាយអំពីអង្គការដែលបង្កើតឡើងដោយ ប៉ុល ពត និងជនទាំងឡាយដែលរួមចំណែកក្នុងអង្គការនោះ ។ ឥឡូវនេះ ប៉ុល ពត ស្លាប់បាត់ទៅហើយ ហើយអង្គការរបស់ប៉ុលពតក៏រលំរលាយ ឬអាចនិយាយបានថាត្រូវបានប្រែក្លាយឲ្យទៅជាអ្វីផ្សេងទៀត*

ដូចជា ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យរបស់ អៀង សារី គាំទ្រដោយប្រជាជនដែលរស់នៅអន្លង់វែង ។

**ក្រេក អិចឆេសាន់**

***ទស្សនៈទី២៖*** ខ្ញុំព្យាយាមមិនប្រើពាក្យ "ខ្មែរក្រហម" ព្រោះពាក្យនេះមានន័យទូលំទូលាយពេកហើយជាពាក្យឥតប្រយោជន៍ ។ ខ្ញុំចូលចិត្តប្រើពាក្យថា "កម្ពុជាប្រជាធិបតេយ្យ" និង "បក្សកុម្មុយនិស្តកម្ពុជា" ។ ខ្ញុំគិតថា សមាជិកភាពរបស់បក្សគឺជាចំណុចសំខាន់សម្រាប់បែងចែកន័យនៃពាក្យនេះឲ្យមានបានច្បាស់ ។ ពាក្យ "ខ្មែរក្រហម" ធ្វើឲ្យមានការភាន់ច្រឡំជាមួយបញ្ហាផ្សេងៗទៀត ។ **ដេវីដ ឆេនដល័រ**

***ទស្សនៈទី៣៖*** ពាក្យថា "ខ្មែរក្រហម" ជាពាក្យដែលបង្កើតឡើងដោយសម្តេចព្រះ នរោត្តម សីហនុ ។ នៅក្នុងសុន្ទរកថាមួយគួរឲ្យជក់ចិត្តនាពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ ព្រះអង្គបានហៅខ្មែរកុម្មុយនិស្តនិងក្រុមឆ្វេងនិយមជាពាក្យបារាំងដែលប្រែមកថា "ខ្មែរក្រហម" ។ នៅពេលជាមួយគ្នានោះដែរ ព្រះអង្គបានហៅក្រុមដែលគាំទ្ររដ្ឋាភិបាលសហរដ្ឋអាមេរិកថាជា "ខ្មែរខៀវ" ។ គួរឲ្យសោកស្តាយ សារពត៌មានផ្សេងៗ ជាពិសេសគឺសារពត៌មានអង់គ្លេសាក់សុង នៅតែប្រើពាក្យថា "ខ្មែរក្រហម" ។ ពាក្យនេះមិនមែនជាពាក្យត្រឹមត្រូវជាក់លាក់សម្រាប់ហៅចលនាបក្សកុម្មុយនិស្តកម្ពុជាឡើយ ហើយក៏មិនមែនពាក្យដែលសម្តេចព្រះ នរោត្តម សីហនុ ប្រើនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ដែរ ។ ពេលដែលខ្ញុំស្ថិតនៅប្រទេសចិន ខ្ញុំតែងតែមានបញ្ហាទាំងជាមួយជនជាតិចិនព្រមទាំងជាមួយសមាជិកខ្មែរក្រហមនៅពេលដែលខ្ញុំប្រើពាក្យនេះ ។ សមាជិកខ្មែរក្រហមស្អប់ពាក្យនេះណាស់ ។ ក្រុមនោះហៅខ្លួនឯងថា "កម្ពុជាប្រជាធិបតេយ្យ" ។

**ចូលីយ៉ូ ជែលរជ្រេស**

***ទស្សនៈទី៤៖*** ពាក្យ "ខ្មែរក្រហម" បម្រើផលប្រយោជន៍ស្មើគ្នារវាងអ្វីដែល "ស" និងអ្វីដែល "ខ្មៅ" នៅក្នុងប្រវត្តិសាស្ត្រ ។ អាចថាវាមានពណ៌ប្រផេះ ។ វាក៏ជាពាក្យដែលស្រពេចស្រពិលរវាងការពិតនិងការក្លែងបន្លំដែរ ។ យើងពុំគួរយកពាក្យ "ខ្មែរក្រហម" មកប្រើប្រាស់នៅក្នុងផ្លូវច្បាប់ទេ ដោយសារថាពាក្យនេះពុំមានភាពជាក់លាក់និងពុំមានអត្ថន័យជាផ្លូវការ ។ យើងគួរតែយកពាក្យ "របបកម្ពុជាប្រជាធិបតេយ្យ" ឬ "បក្សកុម្មុយនិស្តកម្ពុជា" ឬ "គណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា" មកប្រើប្រាស់ជំនួសឲ្យពាក្យ "ខ្មែរក្រហម" នៅក្នុងផ្លូវច្បាប់និងការពិភាក្សាជាផ្លូវការនានា ។ **ឆាំង យុ**

***ទស្សនៈទី៥៖*** ពាក្យថា "ខ្មែរក្រហម" គ្មានន័យទាល់តែសោះ ហើយគួរតែចៀសវាងប្រើពាក្យនេះប្រសិនបើអាចធ្វើបាន ។ យើងគួរតែជំនួសដោយពាក្យអ្វីដែលច្បាស់ហើយមានន័យចំជាងនេះ ឧទាហរណ៍ពាក្យថា "សមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា" "យុទ្ធជន កម្មាភិបាលបក្សនៃរបបកម្ពុជាប្រជាធិបតេយ្យ" ជាដើម ។ល ។ពាក្យ"ខ្មែរក្រហម"ត្រូវបានបង្កើតឡើងដោយ សម្តេចព្រះ នរោត្តម សីហនុ ដើម្បីហៅក្រុមខ្មែរដែលមានគំនិតឆ្វេងនិយម (និយាយឲ្យចំគឺខ្មែរកុម្មុយនិស្ត) ដែលក្នុងគំនិតរបស់ព្រះអង្គផ្ទាល់ ក្រុមនេះមិនចុះញ៉មជាមួយវៀតណាមឡើយ ។ មានខ្មែរមួយក្រុមទៀតមានឈ្មោះថា "ខ្មែរវៀតមិញ" ។ ក្រុមនេះប្រឆាំងនឹងអ្វីដែលព្រះអង្គទ្រង់មានព្រះតម្រិះថាត្រឹមត្រូវ(ដូចជាអ្នកយោធានិយម អ្នកប្រជាធិបតេយ្យ ។ល ។) ។ ពាក្យ "ខ្មែរក្រហម" បានក្លាយជាពាក្យសម្រាប់សម្គាល់ការរំលោភបំពានដែលបន្ទាញពីសារជាតិប្រល័យពូជសាសន៍ ឬក៏យ៉ាងហោចណាស់ត្រឹមជាសារជាតិឃាតកម្មដែរ ។ ដូច្នេះពាក្យនេះគ្រសោបនូវផ្នែកសញ្ញានយោបាយដែលគួរឲ្យគ្រោះថ្នាក់និងគ្មានសុក្រឹតភាព ។ តុលាការមួយប្រហែលជានឹងអាចរកមុខរកឲ្យឃើញច្បាស់ថាតើអ្នកណាខ្លះជាឧក្រិដ្ឋជនប្រល័យពូជសាសន៍ហើយអ្នកណាមិនមែនជាឧក្រិដ្ឋជនប្រល័យពូជសាសន៍ ។ **ស៊ីម រេហ្ស៍រ**

***ទស្សនៈទី៦៖*** ខ្ញុំយល់ថាពាក្យ "ខ្មែរក្រហម" ជាពាក្យកាត់ឲ្យខ្លីមួយដែលគ្រសោបទៅលើព្រឹត្តិការណ៍ប្លែកៗគ្នានៅក្នុងរយៈពេលផ្សេងៗគ្នានៃប្រវត្តិសាស្ត្រកម្ពុជា ។

ក) ជាដំបូងនៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំយល់ថាពាក្យនេះត្រូវបានប្រើប្រាស់ជាដំបូងដោយសម្តេចព្រះ នរោត្តម សីហនុ សំដៅដល់ចលនាបដិវត្តន៍ក្រហមដែលប្រយុទ្ធប្រឆាំងនឹងព្រះអង្គ ។

ខ) នៅក្នុងសម័យ លន់ នល់ ពាក្យ "ខ្មែរក្រហម" សំដៅទៅលើកងកម្លាំងចលនាតស៊ូរួមបញ្ចូលទាំងសម្តេចព្រះ នរោត្តម

សីហនុ រណសិរ្សរួបរួមបង្រួមជាតិ និងរដ្ឋាភិបាលរាជានិយមបង្រួបបង្រួមជាតិ ។

ក) នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ពាក្យ "ខ្មែរក្រហម" ត្រូវបានប្រើប្រាស់សំដៅលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលកំពុងតែកាន់អំណាច ។

ឃ) ចាប់តាំងពីឆ្នាំ១៩៧៩ ពាក្យ "ខ្មែរក្រហម" ត្រូវបានប្រើប្រាស់សំដៅទៅលើសមាសភាពនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់ដែលបន្តការតស៊ូប្រឆាំងនឹងរដ្ឋាភិបាលថ្មី ។

**ហៅឡេន ហ្វាឌីស**

***ទស្សនៈទី៧:*** ពាក្យ "ខ្មែរក្រហម" គឺជាភាសាបារាំងដែលប្រើប្រាស់ដំបូងដោយសម្តេចព្រះ នរោត្តម សីហនុ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ សំដៅដល់ក្រុមខ្មែរកុម្មុយនិស្តនិងអង្គការខ្មែរដែលមានគំនិតឆ្វេងនិយម ។ ពាក្យនេះត្រូវបានយល់ខុសៗគ្នាទៅតាមពេលវេលានិងទស្សនៈនយោបាយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រើពាក្យ"ខ្មែរក្រហម" សំដៅដល់អ្នកដែលធ្លាប់ធ្វើការដើម្បីបង្កើតឬដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។

**ស៊ឹម សុរិយ៉ា និង អៀ ម៉េងទ្រី**

## ការវិវត្តថ្មីៗនៃដំណើរការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហម

◆ ***ថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥:*** ប្រទេសឥណ្ឌូណេស៊ីផ្តល់ប្រាក់១លានដុល្លារមកខាងកញ្ចប់ប្រាក់របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ចំណាយទៅលើអង្គជំនុំជម្រះវិសាមញ្ញ ។

◆ ***ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៥:*** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងឯកឧត្តម ស៊ាន វិសុទ្ធ ជាប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងព្រះរាជក្រឹត្យតែងតាំងលោកស្រី មីសែល លី ជាអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ។

◆ ***ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥:*** ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានឈានដល់ដំណាក់កាលថ្មីមួយទៀត ។ លោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ជ្រើសរើសបេក្ខជនសម្រាប់តំណែងចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ។ បេក្ខជនទាំងអស់នឹងត្រូវធ្វើសម្ភាសនៅដើមខែធ្នូឆ្នាំ២០០៥នេះ ។

◆ ***ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥:*** ប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកការងារតុលាការខ្មែរក្រហមធ្វើសន្និសីទកាសែត ប្រកាសអំពីការឡាយព្រះហស្តលេខារបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលើព្រះរាជក្រឹត្យតែងតាំងឯកឧត្តម ស៊ាន វិសុទ្ធ ជាប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងលោកស្រី មីសែល លី ជាអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ។

◆ ***ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៥:*** លោកស្រី មីសែល លី បានដឹកនាំក្រុមការងាររបស់អង្គការសហប្រជាជាតិមកដល់ទីក្រុងភ្នំពេញដើម្បីបំពេញបេសកកម្មរយៈពេលពីរសប្តាហ៍ (ពីថ្ងៃទី៦ដល់ថ្ងៃទី១៦ ខែធ្នូ) ។

◆ ***ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៥:*** ឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងលោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាល ធ្វើសន្និសីទកាសែតរួមគ្នាដើម្បីប្រកាសអំពីគោលបំណងនៃបេសកកម្មរបស់លោកស្រី លី នៅក្នុងប្រទេសកម្ពុជាពេលនេះ គឺដើម្បីចាប់ផ្តើមដំណាក់កាលថ្មីនៃការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ និងដើម្បីពិនិត្យមើលពេលវេលានិងនីតិវិធីសមស្របដែលអាចចាប់ផ្តើមដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ។

◆ ***ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៥:*** លោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងក្រុមការងាររបស់អង្គការសហប្រជាជាតិ ធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសិក្សាអំពីប្រភពឯកសារនិងមធ្យោបាយដែលមជ្ឈមណ្ឌលនេះអាចផ្តល់ជូនអង្គជំនុំជម្រះវិសាមញ្ញ ។

**សរសេរដោយ ឌី ខេមរិទ្ធ**

# តើអ្នកដែលមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរអាចធ្វើជាសាក្សី នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានដែរឬទេ?

អស់រយៈពេលជិតសាមសិបឆ្នាំមកហើយដែលរបបកម្ពុជាប្រជាធិបតេយ្យត្រូវផ្តួលរំលំពីអំណាច ។ នៅក្នុងរយៈពេលជិតបួនឆ្នាំនៅក្រោមការគ្រប់គ្រងរបស់របបនេះ ប្រជាជនកម្ពុជាប្រឈមនឹងការភ័យខ្លាចសព្វបែបយ៉ាងទាំងអស់ ជាពិសេសភ័យខ្លាចស្លាប់ដោយការខ្វះខាតអាហារ ដោយការធ្វើការងារហួសកម្លាំង ដោយការឃុំឃាំងនិងទារុណកម្ម និងដោយការសម្លាប់ ។ ដោយសារការភ័យខ្លាចទាំងអស់នេះ ប្រជាជនកម្ពុជាភាគច្រើននៅតែមានការប៉ះទង្គិចផ្លូវចិត្តនៅឡើយ ។ មិនថារយៈពេលជាងម្ភៃឆ្នាំបានកន្លងទៅហើយនោះទេ ការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរនេះនឹងនៅតែដក់ជាប់ក្នុងចិត្តប្រជាជនកម្ពុជាអស់មួយជីវិត ។

ភ្លាមៗបន្ទាប់ពីខ្មែរក្រហមត្រូវទម្លាក់ពីអំណាច ប្រជាជនកម្ពុជាមានជម្រើសពីរ គឺត្រូវកសាងជីវិតថ្មីនៅលើទឹកដីបរទេសឬត្រូវត្រឡប់ទៅស្រុកកំណើតវិញ ។ ការសិក្សាថ្មីៗរបស់ *RAND Corporation's Grant Marshall* បានរកឃើញថា ប្រជាជនកម្ពុជាដែលរស់នៅក្នុងសហរដ្ឋអាមេរិកប្រមាណ៦២ភាគរយមានជំងឺប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ (PTSD) ។ សូម្បីតែរស់នៅក្នុងប្រទេសដែលរីកចម្រើនខ្លាំងដូចជានៅសហរដ្ឋអាមេរិក ប្រជាជនកម្ពុជានៅតែប្រឈមមុខនឹងអ្វីដែលខ្លួនធ្លាប់ឆ្លងកាត់កាលពីជាងម្ភៃឆ្នាំមុន បើទោះបីជាអ្នកទាំងនោះមានជីវភាពសមរម្យក៏ដោយ ។

នៅពេលឃើញមានអត្រានៃការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរឡើងខ្ពស់នៅក្នុងចំណោមជនភៀសខ្លួនកម្ពុជានៅក្នុងទឹកដីបរទេស គ្រប់ៗគ្នាប្រាកដជាចង់ដឹងអំពីអត្រានៃជំងឺប្រភេទនេះនៅក្នុងចំណោមប្រជាជនកម្ពុជាដែលរស់នៅក្នុងប្រទេសជាមិនខាន ។ សូម្បីតែបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យធ្លាក់ពីអំណាចក៏ខ្មែរក្រហមនៅតែបន្តបង្កការភ័យខ្លាចដល់ប្រជាជនរហូតដល់ឆ្នាំ១៩៩៩ ។ សង្គ្រាមស៊ីវិលរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជានិងខ្មែរក្រហមបានអូសបន្លាយអស់រយៈពេលជិតពីរទសវត្សរ៍ទៀត ហើយនៅក្នុងអំឡុងពេលនេះ ប្រជាជនកម្ពុជាបន្តរស់នៅក្នុងភាពភ័យខ្លាចដដែល ពោលគឺខ្លាចជាប់កំណែនយោធា ឬខ្លាចបាត់បង់ជីវិតនៅក្នុងការវាយប្រហារជាមួយខ្មែរក្រហម ។ ជាងនេះទៅទៀត សូម្បីតែសព្វថ្ងៃនេះក៏ដោយ ប្រជាជនក្រីក្រដែលរស់នៅតាមទីជនបទដាច់ស្រយាលក៏កំពុងតែមានការភ័យខ្លាចអំពីបញ្ហាគ្រោះខ្វះខាតស្បៀងអាហារថែមទៀត ។ បើពិនិត្យមើលកម្រិតនៃការភ័យខ្លាចដែលប្រជាជនកម្ពុជាជួបប្រទះអស់រយៈពេលប៉ុន្មានទសវត្សរ៍មកនេះ គ្រប់គ្នាប្រាកដជាគិតថាបញ្ហានៃជំងឺប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរប្រាកដជាច្រើនដូចដែលឃើញ


ជនរងគ្រោះដែលមានជំងឺបាក់ស្បាតកំពុងទទួលការផ្តល់ប្រឹក្សាពីអ្នកជំនាញចិត្តសាស្ត្រ

មានក្នុងចំណោមជនភៀសខ្លួនដែលរស់នៅឯសហរដ្ឋអាមេរិកមិនខាន ។

ក៏ប៉ុន្តែ លទ្ធផលនៃការសិក្សារបស់ *RAND* មិនបានធ្វើឲ្យលោក កាស៊ុន ប៊ុណ្ណាត ដែលជានាយកកម្មវិធីជាតិដើម្បីសុខភាពផ្លូវចិត្តរបស់ក្រសួងសុខាភិបាលកម្ពុជា មានការភ្ញាក់ផ្អើលនោះទេ ។ គាត់បែរជាជឿជាក់ថា តាមការពិត ការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរនៅក្នុងចំណោមប្រជាជនកម្ពុជាដែលរស់នៅក្នុងប្រទេសគឺទាបជាងប្រជាជនដែលរស់នៅក្នុងសហគមន៍ខ្មែរនៅឯសហរដ្ឋអាមេរិក ។ គាត់គិតដូច្នេះគឺដោយសារតែវប្បធម៌និងអាកប្បកិរិយារបស់ប្រទេសទាំងពីរខុសគ្នាខ្លាំងពេក ។

ដោយសារតែភាពក្រីក្រ ប្រជាជនកម្ពុជាមិនសូវយកចិត្តទុកដាក់ចំពោះបញ្ហាសុខភាពផ្លូវចិត្តរបស់ខ្លួនឡើយ គាត់គិតតែធ្វើយ៉ាងណាឲ្យមានជីវភាពរស់នៅសមរម្យតែប៉ុណ្ណោះ ។ ប៉ុន្តែបញ្ហាសុខភាពផ្លូវចិត្តនេះមានសារសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជា ជាពិសេសសម្រាប់ពេលដែលមានអង្គជំនុំជម្រះវិសាមញ្ញដើម្បីជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ដោយសារមូលហេតុនេះ យើងត្រូវតែយកចិត្តទុកដាក់បញ្ហាសុខភាពផ្លូវចិត្តឲ្យបានដិតដល់សម្រាប់សាលាជំនុំជម្រះក្តី ។ យើងត្រូវតែយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកទាំងឡាយណាដែលប្រហែលជាត្រូវតុលាការកោះហៅឲ្យឆ្លើយបំភ្លឺនៅក្នុងសវនាការរបស់សាលាជំនុំជម្រះក្តីនេះ ពីព្រោះអ្នកទាំងនោះនឹងត្រូវជីកកកាយឡើងវិញនូវរឿងរ៉ាវឈឺចាប់របស់ខ្លួនកាលពីជាងម្ភៃឆ្នាំមុន ។ គ្រប់គ្នាអាចត្រឹមតែប៉ាន់ស្មានអំពីកំហឹងនិងការភ័យខ្លាចរបស់ខ្លួនដែលត្រូវប្រឈមមុខជាមួយមេដឹកនាំនៃរបបនោះ ។

តើនេះជាបញ្ហាដែរឬទេនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ? តើតុលាការទទួលយកចម្លើយរបស់សាក្សីដែលមានការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដែរឬទេ? នេះគឺជាបញ្ហាមួយដែលត្រូវដោះស្រាយ ប្រសិនបើអ្នកដែលរួចជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យភាគច្រើនមានជំងឺប្រភេទនេះ ។ តើមានរឿងអ្វីកើតឡើងប្រសិនបើមានអ្នកជំទាស់ថាចម្លើយរបស់សាក្សីទាំងនេះមិនអាចយកជាការបានទេ ដោយសារអ្នកទាំងនេះមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ។ មេធាវីរបស់ចុងចោទទំនងជាលើកឡើងអំពីបញ្ហានេះដើម្បីធ្វើឲ្យសាក្សីប្រឆាំងនឹងកូនក្តីខ្លួនលែងយកជាការបាននៅក្នុងតុលាការ ហើយប្រសិនបើចម្លើយរបស់សាក្សីសំខាន់ៗជាច្រើនត្រូវបានបដិសេធន៍ដោយតុលាការដោយសារមូលហេតុស្ថានភាពផ្លូវចិត្តរបស់សាក្សី នោះឱកាសដើម្បីនាំយកមេដឹកនាំខ្មែរក្រហមទៅរកការទទួលខុសត្រូវនឹងត្រូវកាត់បន្ថយជាមិនខាន ។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចែងថានៅពេលដែលច្បាប់ក្នុងស្រុកមិនបានចែងអំពីចំណុចណាមួយ អង្គជំនុំជម្រះត្រូវរកមើលក្បួនច្បាប់និងនីតិវិធីដែលបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ ។ ទាក់ទងនឹងបញ្ហាសាក្សីដែលមានការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានចេញសេចក្តីសម្រេចមួយថា "សម្រាប់មនុស្សម្នាក់ដែលមានជំងឺប៉ះពាល់ស្មារតីធ្ងន់ធ្ងរមិនមែនមានន័យថាចម្លើយដែលគាត់បានផ្តល់ឲ្យតុលាការគឺមិនត្រឹមត្រូវនោះទេ ។ គ្មានមូលហេតុណាមួយដែលថាអ្នកដែលមានជំងឺប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរនេះមិនអាចធ្វើជាសាក្សីដែលយកជាការបាននោះទេ" ។

ជួង សុភារិទ្ធ អ្នកដឹកនាំក្រុមការងារ "ជនរងគ្រោះដោយអំពើទារុណកម្ម" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបន្ទុកផ្តល់ជំនួយស្មារតីដល់អ្នកដែលមានបញ្ហាផ្នែកផ្លូវចិត្ត បានយល់ស្របជាមួយនឹងការអះអាងរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ សុភារិទ្ធ ជឿជាក់ថា ក្រៅពីអាកប្បកិរិយាចម្លែកបន្តិចរបស់អ្នកដែលមានប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដូចជា ការគិតជាប្រចាំអំពីហេតុការណ៍រន្ធត់ ការនឹកឃើញឡើងវិញនូវព្រឹត្តិការណ៍ផ្សេងៗហាក់បីដូចជាព្រឹត្តិការណ៍នោះកើតឡើងម្តងទៀត ការយល់សប្តិអាក្រក់ដេកមិនលក់ និងគេចវេះពីការពិភាក្សា ចម្លើយរបស់សាក្សីប្រភេទនេះគឺអាចយកជាការបាន ។ និយាយម្យ៉ាងទៀត អ្នកដែលមានជំងឺប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរអាចជាសាក្សីដែលអាចទុកចិត្តបាន ។

យើងត្រូវតែធ្វើអ្វីដែលអាចធ្វើទៅបានសម្រាប់អ្នកទាំងអស់នេះ ដើម្បីឲ្យគាត់អាចទទួលបាននូវភាពស្ងប់ស្ងាត់ផ្នែកផ្លូវចិត្ត ហើយការទទួលបានយុត្តិធម៌គឺជាមធ្យោបាយមួយដ៏ប្រសើរបំផុត ។ **ឌី ខេមរិទ្ធិ**

*(អត្ថបទមកពីមិត្តអ្នកអាន)*

# ដំណើរទស្សនកិច្ចដើម្បីការផ្សះផ្សា

នៅថ្ងៃទី២៣, ២៤ និង២៥ ខែកញ្ញា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចមួយដែលពុំធ្លាប់ដែលមានពីមុនមក ។ អ្នកដែលចូលរួមក្នុងដំណើរទស្សនកិច្ចនេះត្រូវបានចែកចេញជាពីរក្រុម ។ ក្រុម “ក” គឺជាអតីតខ្មែរក្រហម ក្នុងនោះមាន ឆ្មាំគុក អ្នកសួរចម្លើយ កម្មាភិបាលបក្ខជននៃបក្សកុម្មុយនិស្តកម្ពុជាដែលមានតួនាទីជាគណៈឃុំ គណៈវរសេនាតូច គណៈវរសេនាធំ និងគណៈកងពល ។ ក្រុម“ខ” គឺជាជនរងគ្រោះដែលបានរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ និងដែលធ្លាប់ជាប់នៅក្នុងមន្ទីរឃុំឃាំង ថែមទាំងមានឪពុកម្តាយ បងប្អូន ប្តី ប្រពន្ធ កូន ឬសាច់ញាតិ ស្លាប់នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ក្រុមទាំងពីរបានធ្វើដំណើរតាមរថយន្តពីរគ្រឿងដាច់ដោយឡែកពីគ្នាក្រោមការដឹកនាំរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសបុគ្គលិកនៃ“គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្មនៅក្នុងរបបខ្មែរក្រហម” និងក្រោមគំនិតផ្តួចផ្តើមដ៏ឆ្លាតវាងវៃរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

អ្វីដែលខ្ញុំស្ងើចសរសើរនិងទឹកស្មានមិនដល់នោះគឺគោលបំណងធំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការនាំយកជនរងគ្រោះនិងជនដៃដល់ឲ្យទទួលស្គាល់នូវការពិតរួមគ្នា ឯកភាពគ្នាហើយផ្សះផ្សាគ្នាឲ្យមានសាមគ្គីជាតិមួយរឹងមាំឡើងវិញ ។ ការធ្វើដូច្នេះទើបជាតិរស់ឯករាជ្យនិងបូរណភាពទឹកដីនៅគង់វង្សស្ថិតស្ថេរទៅបាន ។ ដើម្បីសម្រេចភារកិច្ចដ៏ធំធេងក្នុងការការពារជាតិមាតុភូមិឲ្យគង់វង្សទៅបានលុះត្រាតែមានការសាមគ្គីជាតិមួយរឹងមាំ ។ សាមគ្គីជាតិរឹងមាំលុះត្រាតែជនដៃដល់និងជនរងគ្រោះផ្សះផ្សាគ្នា មានចិត្តសន្តោសយោគយល់និងអធ្យាស្រ័យគ្នា ។ ជនដៃដល់ដែលជាអតីតខ្មែរក្រហមត្រូវទទួលស្គាល់នូវការពិតនិងសម្តែងការសុំអភ័យទោស ជាពិសេសត្រូវហ៊ានប្រឈមមុខនឹងជនរងគ្រោះ ។ តម្លាភាពគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតដែលញុំាងឲ្យជនរងគ្រោះបានធូរស្បើយពីការឈឺចាប់និងឈានទៅបំបាត់គំនុំសងសឹកបាន ។ ទោះជាយ៉ាងណាក៏ដោយ ការសម្តែងនូវការពិតនិងការសុំទោសគឺមិនអាចប្រៀបផ្ទឹមនឹងអ្វីដែលជនរងគ្រោះបានបាត់បង់នោះទេ ។

មូលហេតុដែលនាំឲ្យខ្ញុំសម្រេចចិត្តចូលរួមក្នុងដំណើរទស្សនកិច្ចនេះគឺខ្ញុំចង់ស្វែងយល់បន្ថែមទៀតអំពីការពិតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទីមួយនៃដំណើរទស្សនកិច្ច ខ្ញុំមិនសូវនិយាយស្តីទេ ពីព្រោះខ្ញុំនៅឆ្ងល់និងមិនទាន់យល់ច្បាស់ថាតើដំណើរទស្សនកិច្ចនេះធ្វើឡើងដើម្បីអ្វី ។

ពិតមែនតែខ្ញុំធ្លាប់ជាអតីតកម្មាភិបាលបក្ខជនម្នាក់របស់ខ្មែរក្រហម ប៉ុន្តែមានរឿងរ៉ាវជាច្រើនដែលខ្ញុំមិនដឹងមិនយល់អំពីរបបខ្មែរក្រហម ។ ខ្ញុំមិនដែលបានឃើញមុខអង្គការថ្នាក់លើថ្នាក់ដឹកនាំកំពូលៗរបស់ខ្មែរក្រហម ដូចជា ប៉ុល ពត, នួន ជា ម្តងណាឡើយ ជាពិសេសក្នុងពេលដែលខ្មែរក្រហមកំពុងតែកាន់កាប់អំណាចពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ មេដឹកនាំខ្មែរក្រហមទាំងនោះមានឈ្មោះក្លែងក្លាយពីរ-បី ដូច្នេះឈ្មោះពិតឬប្រវត្តិរបស់មេដឹកនាំខ្មែរក្រហមទាំងនោះយ៉ាងណាក៏ខ្ញុំរឹតតែមិនដឹងទៅទៀត ។

ល្ងាចថ្ងៃទី២នៃដំណើរទស្សនកិច្ច ក្នុងពេលដែលជនរងគ្រោះនិងជនដៃដល់កំពុងតែទស្សនាខ្សែភាពយន្តឯកសារមួយរបស់អ្នកនិពន្ធឈ្មោះ ឫទ្ធី ប៉ាន់ ដែលមានចំណងជើងថា “ស-២១ៈ ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម” ខ្ញុំបានជួបមុខមីងញ៉ និងកូនចៅរបស់គាត់ ដែលកាលពីរបបខ្មែរក្រហមរស់នៅក្នុងភូមិស្រែគ្រួ ឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ តាមពិតខ្ញុំបានភ្លេចមុខគាត់បាត់ទៅហើយ ពីព្រោះកាលដែលខ្ញុំជួបគាត់មានរយៈពេលខ្លីពេក ។ មីងញ៉ ដែលមានវ័យចំណាស់ស្របាលនឹងបងស្រីខ្ញុំ បានលើកដៃជម្រាបសួរខ្ញុំ ។ ខ្ញុំភ្ញាក់ព្រើតនិងរន្ធត់ចិត្តជាខ្លាំង ។ ខ្ញុំសួរទៅគាត់វិញថា “មីងជាអ្នកណា?” ។

មីងញ៉ សំណេះសំណាលនិងសួរសុខទុក្ខខ្ញុំយ៉ាងរាក់ទាក់ កក់ក្ដៅហាក់ដូចជាគ្មានរឿងអ្វីកើតឡើងពីមុនមកសោះរវាងខ្ញុំនិងគាត់ ។ តាមការពិត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្ញុំគឺជាកម្មាភិបាលម្នាក់ ចំណែក មីងញ៉ និងកូនចៅរបស់គាត់ ស្ថិតក្នុងស្ថានភាពជាអ្នកទោស ហើយប្ដីគាត់និងកូនប្រសាររបស់គាត់ត្រូវសន្តិសុខខ្មែរក្រហមសម្លាប់ ។

នៅថ្ងៃទី៣នៃដំណើរទស្សនកិច្ច ក្រុមទាំងពីរបានស្រស់ស្រូបអាហារពេលព្រឹកនៅក្នុងភោជនីយដ្ឋានជាមួយគ្នា ។ បន្ទាប់មក ខ្ញុំ មីងញ៉ និងចៅរបស់គាត់ បានថតរូបជាមួយគ្នាទុកជាអនុស្សាវរីយ៍ ។ នេះជាកាយវិការដ៏ចម្លែកហើយក៏មិនមែនជាការចំអកឡកឡឺយដែរ ប៉ុន្តែគឺជាការបង្ហាញនូវទឹកចិត្តដ៏បរិសុទ្ធដែលបងប្អូនជនរងគ្រោះបានដកកប់ស្រមោលអតីតកាលដ៏ខ្មៅងងឹតបាត់ទៅហើយ ។ នេះអាចចាត់ទុកថាជាដំណើរការផ្សះផ្សាមួយដែលបានឈានចូលមកដល់យ៉ាងឆាប់រហ័សហួសពីការរំពឹងទុក ។ បន្ទាប់មក យើងបន្តដំណើរឆ្ពោះទៅអតីតគុកក្រាំងតាចាន់ដែលជាកន្លែងសម្លាប់មនុស្សស្ថិតនៅក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។

នៅលើរថយន្តពីក្រាំងតាចាន់ឆ្ពោះទៅខេត្តកំពត ប្អូនសែនដែលធ្លាប់ជាអតីតអ្នកទោសនៅគុកក្រាំងតាចាន់ដែរ បាននិយាយប្រាប់ខ្ញុំថា ពេលកំពុងមើលកុន មីងញ៉ អង្គុយនៅខាងក្រោយខ្នងខ្ញុំ ។ គាត់បានចង្អុលមកខ្ញុំហើយប្រាប់កូនចៅរបស់គាត់ថា “កាលនោះបានពូហ្នឹងហើយដែលខស្សាហ៍ហុចបាយនំចំណីឲ្យកូននិងចៅឯង ។ បានគាត់ហ្នឹងហើយបានជួយសម្រួលឲ្យយើងរួចពីស្លាប់និងរស់រានមានជីវិតមកដល់សព្វថ្ងៃនេះ” ។

យើងបានឈប់សម្រាកដើម្បីទទួលទានបាយថ្ងៃត្រង់នៅក្នុងភោជនីយដ្ឋានមួយក្នុងទីរួមខេត្តកំពតរួចទើបបន្តដំណើរទៅទៀត ។ មិនយូរប៉ុន្មានយើងបានទៅដល់រមណីយដ្ឋានទឹកឈូដ៏ល្អប្រណីត ។ យើងបានធ្វើដំណើររួមគ្នា ឆ្លងស្ពានយោល ខ្លះចុះងូតទឹកជ្រោះដ៏ថ្លាឈ្វេង អ្នកខ្លះឈរគយគន់ផ្ទាំងទស្សនីយភាពពណ៌បៃតងខ្ចីនៃរុក្ខជាតិព្រៃភ្នំនារដូវវស្សាតាមជួរភ្នំកំចាយ ។ ដំណើរទស្សនកិច្ចរបស់យើងបានបញ្ចប់ដោយក្ដីសោមនស្សរីករាយក្នុងរយៈពេលបីថ្ងៃពីរយប់ ។

មកដល់ផ្ទះវិញខ្ញុំដេកមិនលក់សោះ ។ ខ្ញុំហាក់បីដូចជារំភើបខ្លាំងពេកចំពោះដំណើរទស្សនកិច្ចដ៏មានសារសំខាន់នេះ ។ អ្វីដែលធ្វើឲ្យខ្ញុំនឹកស្មានមិនដល់នោះគឺវិធីសាស្ត្រប្រកបដោយភាពឈ្លាសវៃនិងទេពកោសល្យខ្ពស់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលអាចធ្វើឲ្យមានការផ្សះផ្សាគ្នារវាងជនរងគ្រោះនិងជនដៃដល់បានយ៉ាងពិតប្រាកដ ។ ពិតជាគួរឲ្យភ្ញាក់ផ្អើលមែន!

ខ្ញុំសោកស្ដាយដែលទស្សនកិច្ចនេះបញ្ចប់ឆាប់រហ័សពេកធ្វើឲ្យខ្ញុំគ្មានឱកាសធ្វើចំណាប់អារម្មណ៍នៅចំពោះមុខជនរងគ្រោះនិងមិនបានសម្ដែងនូវការកោតសរសើរដើម្បីឆ្លើយតបឲ្យអស់ពីចិត្តថ្លើមខ្ញុំចំពោះបងប្អូនជនរងគ្រោះដែលមានអាប្បកិរិយាទន់ភ្លន់ញញឹមញញែមនិងរាក់ទាក់ចំពោះអតីតជនដៃដល់ ។ លើសពីនេះ ខ្ញុំក៏មិននឹកស្មានថាដំណើរការផ្សះផ្សាបែបនេះអាចកើតឡើងមុនពេលមានដំណើរការតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិគ្រោងនឹងធ្វើនោះទេ ។

ករណីនេះបានញ៉ាំងឲ្យខ្ញុំសម្រេចចិត្តសរសេរអំពីការយល់ឃើញរបស់ខ្ញុំដើម្បីជាការបន្ធូរបន្ថយភាពតានតឹងពីក្នុងខ្លួនដែលបណ្ដាលឲ្យខ្ញុំដេកមិនលក់ ។ អត្ថបទចំណាប់អារម្មណ៍របស់ខ្ញុំគឺបង្ហាញពីការពិតមួយចេញពីបេះដូងរបស់ខ្ញុំជូនចំពោះបងប្អូនជនរងគ្រោះជាទីស្រលាញ់រាប់អាន ជាពិសេសអ្នកដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចនេះ ដែលបានប្រែក្លាយពីគំនុំគុំកួនមកជាការផ្សះផ្សាគ្នាវិញ ។ ខ្ញុំសរសេរអត្ថបទនេះក្នុងគោលបំណងជម្រាបជូនអ្នករួមដំណើរទស្សនកិច្ចក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ឲ្យបានយល់ដឹងថាតើក្នុងនាមជាអតីតកម្មាភិបាលនិងបក្ខជនមួយរូបរបស់ខ្មែរក្រហម ខ្ញុំនឹងបងប្អូនជនរងគ្រោះមានស្ថានភាពប្រហាក់ប្រហែលគ្នាឬខុសគ្នាយ៉ាងណា? តើខ្ញុំមានទស្សនៈយ៉ាងណាចំពោះមុខអំពើឃោរឃៅព្រៃផ្សៃទាំងនោះ? តើខ្ញុំអាចជួយអ្វីបានដល់បងប្អូនរងគ្រោះ? តើក្នុងចិត្តខ្ញុំមានវិប្បដិសារីកម្រិតណា? ហើយតើខ្ញុំត្រូវធ្វើអ្វីខ្លះសម្រាប់មនុស្សជំនាន់ក្រោយ?

## ប្រវត្តិរបស់ខ្ញុំនិងគ្រួសារ

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ គ្រួសារខ្ញុំជាវណ្ណៈកសិករថ្នាក់

កណ្តាលដែលមានកម្មសិទ្ធិដីភូមិនិងដីស្រែប្រមាណ៨ហិចតា ហើយទិន្នផលដែលបានទទួលក្នុងមួយរដូវៗមានប្រមាណពី ២៥០ទៅ៣០០ថាំង ។ ផលស្រូវដែលផលិតបានល្មមគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងគ្រួសារ និងសល់បន្តិចបន្តួចដែលអាចឲ្យអ្នកជិតខាងខ្ចីបុលបាន ។

ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់ ប្រុស៦នាក់ ស្រី២នាក់ ។ បងប្រុសទី១គឺជាកសិករ ប្រកបរបរធ្វើចម្ការនៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ។ គាត់បានស្លាប់នៅជំរំខាវអ៊ីដាងក្នុងឆ្នាំ១៩៨៣ ។ បងប្រុសទី២បានបួសរៀនជាអាចារ្យព្រះត្រៃបិដក ក្រោយមកបានលាចាកសិក្ខាបទចូលធ្វើប៉ូលិសសន្តិសុខ (ស្លាប់) ។ បងស្រីទី៣ជាកសិករ បច្ចុប្បន្នជាស្ត្រីមេម៉ាយគ្មានកូនទេ ។ បងប្រុសទី៤ជាកសិករ (ស្លាប់) ។ បងប្រុសទី៥ជានាយទាហានរងក្នុងរបបសង្គមរាស្ត្រនិយម (ស្លាប់ក្នុងឆ្នាំ១៩៧៣) ។ ទី៦គឺជារូបខ្ញុំ ។ ទី៧គឺប្អូនស្រីរបស់ខ្ញុំដែលមានប្តីជាពលទាហានអាកាសចរណ៍ បច្ចុប្បន្ននៅរស់ និងទី៨គឺជាប្អូនពៅរបស់ខ្ញុំ បច្ចុប្បន្ននៅរស់ ។

ឆ្លើយតបនឹងព្រះរាជបន្ទូលអំពាវនាវរបស់សម្តេចព្រះនរោត្តម សីហនុ ខ្ញុំបានសម្រេចចិត្តសុំលាសង្សារជាទីស្រឡាញ់ (បច្ចុប្បន្នជាភរិយាដ៏ល្អរបស់ខ្ញុំ) ទៅចូលរួមក្នុងចលនាតស៊ូរបស់រណសិរ្សរួបរួមជាតិកម្ពុជាដែលដឹកនាំដោយសម្តេចឪ ។ ពេលនោះខ្ញុំមានសមានចិត្តស្វាមីភក្តិចំពោះអង្គសម្តេចឪនិងមាតុភូមិជាទីស្រលាញ់របស់ខ្ញុំខ្លាំងណាស់ ។ ខ្ញុំពុំមែនតស៊ូដើម្បីយកកុម្មុយនិស្តខ្មែរក្រហមទេ ។ ខ្ញុំមិនដែលស្គាល់ខ្មែរក្រហមយ៉ាងម៉េចឬកុម្មុយ-និស្តយ៉ាងម៉េចទេ ។ ត្រឹមតែរបបសង្គមរាស្ត្រនិយមគឺពេកណាស់ទៅហើយសម្រាប់យើង ។ ខ្ញុំយល់ថាអាណានិគមបែបថ្មីរបស់អាមេរិកមានគំនាបធ្ងន់ធ្ងរជាងអាណានិគមបារាំងទៅទៀត ។ ក៏ប៉ុន្តែ ការសម្រេចចិត្តរបស់ខ្ញុំគឺជាភាពល្ងង់ខ្លៅ ពីព្រោះខ្ញុំមិនយល់អ្វីទៅដែលហៅថា «នយោបាយ» ។

ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានយុវជនរណសិរ្សប្រចាំឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។ បន្ទាប់មកខ្ញុំត្រូវបានបញ្ចូលទៅក្នុងសម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា (អ.ក.ស.យុ.វ.ក.ក) ហើយខ្ញុំមានឱកាសបានចូលរួមក្នុងមហាសន្និបាតអបអរសាទរថ្ងៃកំណើតបក្សជារៀងរាល់ឆ្នាំ ពោលគឺខួបលើទី២១ ទី២២ និងបន្តរហូតមកក្នុងឋានៈជាប្រធានយុវជនស្រុក ។

ឆ្លងកាត់ការរៀនសូត្រនយោបាយតាមរយៈប្រជុំតូច-ធំសន្និបាត និងមហាសន្និបាត ខ្ញុំបានយល់ច្បាស់អ្វីដែលហៅថា «នយោបាយ» ជាពិសេសខ្លឹមសារនៃគោលនយោបាយបដិវត្តន៍ប្រជាជាតិបដិវត្តប្រជាធិបតេយ្យ គោលនយោបាយជាយុទ្ធវិធី និងគោលនយោបាយជាយុទ្ធសាស្ត្រ ។ ពេលនោះហើយដែលខ្ញុំចាប់ផ្តើមមានវិប្បដិសារី ។ បើក្រឡេកមើលទៅមាគ៌ាចាត់តាំងគឺខ្ញុំមានប្រវត្តិមិនល្អ ។ ខ្ញុំមិនមែនជាមនុស្សដែលអង្គការបដិវត្តន៍ខ្មែរក្រហមត្រូវការទេ ។ ខ្ញុំបន្ទោសខ្លួនឯងដែលឆោតល្ងង់ ។ ការពិត ការយករណសិរ្សរួបរួមជាតិនិងគោលនយោបាយរណសិរ្សនេះមកប្រើគឺគ្រាន់តែជាយុទ្ធវិធីរបស់ខ្មែរក្រហមប៉ុណ្ណោះ ។ អ្នកដឹកនាំពិតប្រាកដនៃចលនាតស៊ូនេះមិនមែនជាសម្តេចឪទេ ។ សម្តេចឪគ្រាន់តែជាកូនអុកមួយរបស់ខ្មែរក្រហម ។ ព្រះអង្គគឺជាសត្រូវជាគោលដៅរបស់កុម្មុយនិស្តដែលត្រូវតែកម្ទេចឲ្យអស់វណ្ណៈសក្តិភូមិតាមគោលនយោបាយតស៊ូវណ្ណៈរបស់ខ្មែរក្រហម ។

បើគិតតាមគោលនយោបាយនេះ បងប្អូន ឪពុកមាបង្កើតនិងបងប្អូនជីដូនមួយរបស់ខ្ញុំចំនួន៧នាក់ គឺជាខ្មាំងសត្រូវជាមួយនឹងខ្ញុំ ។ ពេលនោះខ្ញុំធ្លាក់ក្នុងស្ថានភាពជាប់ផុង វ័ណ្ឌកខាងនយោបាយ ទៅមុខក៏មិនរួច ថយក្រោយក៏មិនបាន ។ ៨០ភាគរយនៃប្រទេសប្រទេសជាតំបន់រំដោះ ចំណែកឯស្រុក១០៥ (ស្រុកត្រាំកក់) គឺក្លាយជាមូលដ្ឋានបង្អែកដ៏រឹងមាំរបស់ខ្មែរក្រហម ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សម្រែកហ៊ោកញ្ជ្រៀវលាន់កងរំពងបានតែមួយពព្រិចភ្នែកប៉ុណ្ណោះ ។ ខ្ញុំមានអារម្មណ៍សប្បាយផងទុក្ខព្រួយផង ។ សប្បាយព្រោះសង្ឃឹមថាសង្គ្រាមត្រូវបញ្ចប់ ហើយនឹងពុំមានមនុស្សស្លាប់ដោយគ្រាប់កាំភ្លើងបន្តទៀត ។ ព្រួយគឺខ្លាចក្រែងថានឹងមានមនុស្សស្លាប់ច្រើនជាងមុនដោយសារតែនយោបាយប្រកបដោយពិលពុលរបស់អង្គការបក្សកុម្មុយនិស្តកម្ពុជា ។

ក្រោយពីទទួលបានជ័យជម្នះ ខ្មែរក្រហមបានប្រើប្រាស់យុទ្ធវិធីថ្មីមួយទៀតដោយអំពាវនាវឲ្យនាយទាហានចាប់ពីថ្នាក់អនុសេនីយ៍ត្រីឡើងទៅ និងមន្ត្រីរដ្ឋការដែលមានបុណ្យស័ក្តិ

ខ្ពង់ខ្ពស់ មកបង្ហាញមុខដើម្បីអង្គការនាំទៅគាល់សម្តេច សីហនុ និងដើម្បីឲ្យព្រះអង្គចាត់ចែងឲ្យចូលបម្រើការងារតាមតួនាទីរបស់ខ្លួនវិញ ។ ខ្មែរក្រហមបានប្រើប្រាស់ប្រជាប្រិយភាពរបស់សម្តេចឪធ្វើជាយុទ្ធវិធីទាក់ទាញយុទ្ធជនយុទ្ធនារីឲ្យចូលបម្រើកងទ័ព ហើយឥឡូវនេះ ពេលត្រូវការបោសសម្អាតទាហាននិងមន្ត្រីរាជការធំៗ ក៏ខ្មែរក្រហមប្រើប្រាស់ព្រះនាមសម្តេចឪជាយុទ្ធវិធីដែរ ។

ពេលខ្ញុំដឹងច្បាស់ដូច្នេះ ការសប្បាយរបស់ខ្ញុំក្លាយជាទុក្ខ ។ តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេចចំពោះមុខស្ថានភាពបែបនោះ?

ក្រោយពេលខ្មែរក្រហមកាន់កាប់អំណាចទូទាំងប្រទេសបានប្រហែល១០ថ្ងៃ ឪពុកម្តាយរបស់ខ្ញុំបានទទួលឋានៈជាប្រជាជនត្រៀម ហើយបងប្អូនរបស់ខ្ញុំបានទទួលឋានៈជាប្រជាជនផ្ញើ ។ ស្ថានភាពរបស់ខ្ញុំពេលនោះពិតធ្ងន់ធ្ងរណាស់ ។ ខ្ញុំត្រូវតែប្រថុយប្រថានលួចខ្សឹបប្រាប់បងប្អូនមិត្តភក្តិ និងអ្នកដទៃខ្លះទៀត អំពីស្ថានការណ៍ស្រុកទេស ដោយមិនចាំបាច់ពន្យល់ហេតុផលអ្វីឡើយពីព្រោះខ្លាចបែកការណ៍សម្ងាត់ ។ ដូចដឹងស្រាប់ហើយ ប្រសិនបើបែកការណ៍ ជីវិតរបស់ខ្ញុំក៏ត្រូវអស់ដែរ ។ ក្នុងនាមខ្ញុំជាកម្មាភិបាលម្នាក់របស់ខ្មែរក្រហម ខ្ញុំបានប្រើប្រាស់តួនាទីរបស់ខ្ញុំផ្នែកឆែរបញ្ជីប្រវត្តិរូបអ្នកទោសក្នុងគោលបំណងជួយកែសម្រួលកំហុសឆ្គងខ្លះៗរបស់អ្នកទោសទោះបីស្គាល់ឬមិនស្គាល់ក្តី មុននឹងថ្នាក់លើចុះមកមើល ឬពេលដែលថ្នាក់លើមានការធ្វេសប្រហែស ។

នៅឆ្នាំ១៩៧៦ អង្គភាពយុវជនដែលពីមុនមានភារកិច្ចអប់រំអូសទាញយុវជនឲ្យចូលបម្រើកងទ័ព ត្រូវបានប្តូរទៅជាកងចល័តលើកទំនប់ដីកប្រឡាយនៅតាមឃុំ ស្រុក តំបន់ វិញ ។




ខ្លួនខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅជាមួយសមមិត្តលេខាស្រុកទៅបំពេញភារកិច្ចក្នុងភូមិភាគកណ្តាលឬភូមិភាគឧត្តរបន្ទាប់ពីភូមិភាគនេះត្រូវបានខ្មែរក្រហមបំបែកជាពីរ ។

ជាការពិត របបកម្ពុជាប្រជាធិបតេយ្យបានធ្វើប៉ះពាល់មនុស្សទូទៅដោយមិនរើសមុខ ទាំងប្រជាជនថ្មី ប្រជាជនចាស់ យុទ្ធជននិងកម្មាភិបាលដែលធ្លាប់បានជួយឲ្យខ្មែរក្រហមទទួលជ័យជម្នះ និងអតីតខ្មែរក្រហមដែលធ្លាប់បានក្នុងចូលរួមចលនាតស៊ូតាំងពីសម័យតស៊ូនយោបាយផ្ទៃក្នុងសម្ងាត់ដូចជាគណៈស្រុក គណៈតំបន់ គណៈភូមិភាគ សមាជិកមជ្ឈិមបក្ស និងឥស្សរជនធំៗដូចជា វ៉ន វ៉េត, តូច ភឿន, ទីវ អុល, កោក ឆាយ, ហ៊ូ យន់, និង ហ៊ូ នឹម ជាដើម ។ ដូច្នេះបើប្រៀបធៀបរវាងប្រជាជនថ្មីនិងប្រជាជនចាស់ កម្មាភិបាលខ្មែរក្រហមទូទៅ សួរថាតើអ្នកណាប្រសើរជាង?

ចាប់ពីឆ្នាំ១៩៧៦រហូតដល់ឆ្នាំ១៩៧៨ ការចាប់មនុស្សដែលខ្មែរក្រហមយល់ថាខ្មាំងរបស់អង្គការ បានក្លាយជាជំងឺឆ្លងដ៏សាហាវមួយដែលគ្រោះថ្នាក់ជាងជំងឺអេដ៍មួយរយដងទៅទៀត ។ ជំងឺនេះបានរាតត្បាតក្នុងជួរខ្មែរក្រហមខ្លួនឯងតែម្តង ។ សូម្បីតែមេដឹកនាំខ្មែរក្រហមដែលឆ្លាតវៃក្នុងការប្រើនយោបាយក៏ទទួលរងគ្រោះថ្នាក់ដោយសារយុទ្ធវិធីនេះដែរ ។ ការចាប់ខ្លួនខ្មាំងរបស់

អង្គការគឺជាយុទ្ធវិធីងាយបំផុត ពោលគឺថ្នាក់លើចេញលិខិតហៅអ្នកនោះទៅប្រជុំឬហៅទៅជួប ។ ពេលនោះហើយដែលបុគ្គលនោះត្រូវចាប់ខ្លួនបានយ៉ាងងាយស្រួល ។ ឡាំងដែលចាប់ខ្លួនបានសុទ្ធតែត្រូវបញ្ជូនទៅសួរចម្លើយ ។ ប៊ូន ហ៊ឹម ហ៊ុយ អតីតយុទ្ធជននៃមន្ទីរស-២១ (គុកទួលស្លែង) បានប្រាប់ខ្ញុំថា កងសួរចម្លើយនៅមន្ទីរស-២១មានបីក្រុមគឺ ក្រុមត្រជាក់ ក្រុមក្តៅ និងក្រុមអន្ទៀម ។ ប្រសិនបើការសួរចម្លើយនៅក្រុមត្រជាក់មិនបានផលគឺត្រូវបញ្ជូនទៅក្រុមក្តៅ ហើយបើនៅតែមិនបានផលទៀតត្រូវបញ្ជូនបន្តទៅឲ្យក្រុមអន្ទៀម ។ ពេលអ្នកទោសបញ្ជូនមកដល់ក្រុមក្តៅនិងក្រុមអន្ទៀម ការធ្វើទារុណកម្មពិតជាកើតឡើងដើម្បីយកចម្លើយតាមដែលអង្គការចង់បាន ។ ពេលដែលស៊ូទ្រាំនឹងទារុណកម្មមិនបាន ជនរងគ្រោះប្រឌិតចម្លើយសារភាពមិនពិតដោយឆ្លើយដាក់មនុស្សដែលខ្លួនធ្លាប់ស្គាល់ចាប់ពី៥០នាក់ទៅ១០០នាក់ ឬអាចលើសពី១០០នាក់ ។ បន្ទាប់ពីសួរចម្លើយអ្នកទោសត្រូវនាំយកទៅសម្លាប់ ។

ការប្រឈមមុខនឹងជំងឺរាតត្បាតដ៏សាហាវនេះ តើមានអ្នកណាម្នាក់ដែលថាមិនភ័យខ្លាច? ចំពោះខ្ញុំ ថ្វីដ្បិតតែធ្លាប់ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ ប៉ុន្តែខ្ញុំក៏មានប្រវត្តិរូបមិនល្អដែរ ហើយខ្ញុំត្រូវប្រឈមមុខនឹងគ្រោះថ្នាក់យ៉ាងខ្លាំង ។ ខ្ញុំបានរស់នៅឆ្លងកាត់របបដ៏ព្រៃផ្សៃនេះដោយការភ័យព្រួយជាប្រចាំមិនខុសពីជនរងគ្រោះដទៃទៀតទេ ។



ការជជែកដេញដោលគ្នារវាងអតីតកម្មាភិបាលខ្មែរក្រហមនិងជនរងគ្រោះនៅទីតាំងគុកក្រាំងតាចាន់

## ដីរស្លាប់យកចង្អេរបាំង

នៅក្នុងដំណើរទស្សនកិច្ចបីថ្ងៃនោះ ក្រៅពីទស្សនាខ្សែភាពយន្តឯកសារចំនួនពីរ យើងបានដើរមើលទិដ្ឋភាពនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ពេលនោះខ្ញុំបានប្រទះឃើញផែនទីប្រទេសកម្ពុជាមួយផ្ទាំងព្យួរនៅលើជញ្ជាំង ហើយដែលមានរូបឆ្អឹងលលាដ៍ក្បាលជនរងគ្រោះពាសពេញផ្ទៃនៃផែនទីនោះ ដែលបញ្ជាក់ឲ្យឃើញថាអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមមានលក្ខណៈជាប្រព័ន្ធជាខ្សែចង្វាក់រាលដាលទូទាំងប្រទេសកម្ពុជា ។ គុកទួលស្លែង វាលពិឃាតបឹងជើងឯក គុកសង់ គុកវត្តកកោះ និងគុកក្រាំងតាចាន់ គឺជាតឹកតាង ។

ពាក្យចាស់លោកពោលថា “ដីរស្លាប់មិនអាចយកចង្អេរបាំងជិតទេ” ។ អំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលប្រជាពលរដ្ឋខ្មែរជិតពីរលាននាក់ត្រូវខ្មែរក្រហមសម្លាប់ក៏មិនអាចបិទបាំងបានដែរ ។

ក្នុងចំណោមអ្នកចូលរួមដំណើរទស្សនកិច្ចនេះ មានអ្នកខ្លះបដិសេធថាមិនបានឃើញមិនបានដឹងឮអំពីរឿងរ៉ាវទាំងអស់នេះឡើយ ។ សូម្បីតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលជាសមាជិកនៃគណៈកម្មាធិការបក្សកុម្មុយនិស្តកម្ពុជាក៏និយាយថាមិនបានដឹងរឿងរ៉ាវដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមដែរ ។ ដូច្នេះខ្ញុំសូមសួរថា តើនៅពេលនោះអតីតខ្មែរក្រហមទាំងនោះរស់នៅឯណា? បើរស់នៅក្នុងប្រទេស ទោះបីជាមិនបានធ្វើក៏គួរតែបានឃើញឬបានដឹងឮខ្លះដែរតាមរយៈបទឧទ្ទេសនាមរបស់សមមិត្ត

លេខានៃអង្គភាពរបស់ខ្លួន ឬតាមរយៈសន្និបាត មហាសន្និបាត វគ្គរៀនសូត្រធំ-តូចរៀងរាល់ខែនិងរៀងរាល់ត្រីមាស ។

តើមានយុទ្ធជនឬកម្មាភិបាលកងទ័ពណាមួយដែលមិនបានឃើញមិនបានដឹងឮអំពីការបាញ់សម្លាប់មនុស្សទាំងកណ្តាលថ្ងៃទុកឲ្យហើមស្អុយរលួយគ្រប់ទីកន្លែង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥? គុកភ្នំសន្ទុងនៃភូមិភាគនិរតីនិងគុកទួលស្លែងនៅភ្នំពេញ បានផ្តាច់ជីវិតយុទ្ធជនរាប់ម៉ឺននាក់មកពីគ្រប់អង្គភាពរហូតដល់មានអង្គភាពខ្លះត្រូវរំលាយចោលទាំងស្រុង ។

ពាក្យថា "ខ្ញុំមិនបានដឹងឮរឿងរ៉ាវសម្លាប់មនុស្សទេ" ឆ្លុះបញ្ចាំងឲ្យឃើញពីការមិនទទួលស្គាល់ការពិត និងមិនទទួលស្គាល់នូវកំហុសដែលខ្លួនបានធ្វើ ។ បើមិនព្រមទទួលស្គាល់កំហុសគឺមានន័យថាមិនកែប្រែ មិនភ្ញាក់រឭក ។

សម្តីរបស់ ខៀវ សំផន ដែលនិយាយថាមិនបានដឹងឮអំពីការសម្លាប់មនុស្សយ៉ាងរង្គាល ដែលក្នុងនោះរួមមានទាំងសមមិត្តរបស់គាត់ ដូចជា ហ៊ូ យន់, ហ៊ូ នឹម ព្រមទាំងកងទ័ពបដិវត្តន៍ដែលបានធ្វើពលីកម្មដើម្បីដណ្តើមជ័យជម្នះឲ្យខ្មែរក្រហម គឺជាការភូតកុហក ។ ឋានៈជាអតីតសមាជិកមួយរូបរបស់គណៈកម្មាធិការមជ្ឈិមបក្ស ខៀវ សំផន បែរជាមិនបានដឹងអំពីរឿងនេះ គឺជាការមួយគួរឲ្យអស់សំណើចខ្លាំងណាស់ ។ ប៉ុន្តែបើបានដឹងហើយធ្វើពុតជាមិនដឹងវិញនោះ ធ្វើឲ្យសញ្ញាប័ត្រ "បណ្ឌិត" របស់លោកលែងមានន័យអ្វីទាំងអស់ ។

ហេតុការណ៍ធំប៉ុនភ្នំនៅកណ្តាលវាល ខៀវ សំផន ឆ្លើយថាមិនដឹងឮ រីឯរឿងសម្ងាត់បំផុតសូម្បីតែភ្នាក់ងារស៊ើបការណ៍របស់កងខេមរភូមិន្ទដែលមានសមត្ថកិច្ចតាមកម្ទេចចលនាតស៊ូនយោបាយផ្ទៃក្នុងក៏មិនដឹងដែរនោះ បែរជាគាត់ដឹងទៅវិញ ។ ខ្ញុំយល់ស្របជាមួយ ខៀវ សំផន អំពីការដែលថាគាត់មិនបានចូលរួមសម្លាប់មនុស្សដោយផ្ទាល់ដៃ ពីព្រោះគាត់គ្មានតួនាទីប្រព្រឹត្តដោយផ្ទាល់ដៃនោះទេ ប៉ុន្តែគាត់មិនគួរនិយាយថាគាត់មិនបានដឹងឮអំពីការសម្លាប់មនុស្សនោះឡើយ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទម្លាប់មួយដែលខ្មែរក្រហមតែងតែប្រកាន់ខ្ជាប់ជានិច្ចនោះគឺទិតៀន-ស្វ័យទិតៀន និងធ្វើជីវទស្សន៍ ដើម្បីស្វែងរកចំណុចខុសឆ្គងជាគុណសម្បត្តិ និងជាគុណវិបត្តិ ។ ទាក់ទងនឹងអ្វីដែលបានកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការធ្វើទិតៀន-ស្វ័យទិតៀននិងការធ្វើជីវទស្សន៍គឺត្រូវតែឆ្លុះបញ្ចាំងនិងសម្តែងនូវអំពើប្រព្រឹត្តបំពានមកលើជីវិតមនុស្សរាប់លាននាក់ ដែលជាទោសមហាឧក្រិដ្ឋ ពោលគឺមិនត្រូវសម្តែងកំហុសតូចតាចហើយកំសាកនៅចំពោះទោសឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តនោះទេ ។ ព្រះពុទ្ធបានសម្តែងថា "ធ្វើសឹកសង្គ្រាមឈ្នះសត្រូវ១០០ដងមិនស្មើនឹងយកឈ្នះខ្លួនឯងបានម្តង" ។ ឥឡូវនេះ បរិបទទិតៀន-ស្វ័យទិតៀននិងការធ្វើជីវទស្សន៍ដែលជាទម្លាប់របស់ខ្មែរក្រហមសម្រាប់កសាងខ្លួននោះ គួរតែត្រូវបានយកមកធ្វើជាមធ្យោបាយកែប្រែចិត្តគំនិតដើម្បីដុសខាត់សតិអារម្មណ៍ឲ្យក្លាយទៅជាមនុស្សល្អក្នុងសង្គមវិញ ។

ចំណុចលំបាកដែលនៅសេសសល់គឺភាពកំសាកដែលលាក់លៀមកេរ្តិ៍ឈ្មោះជាឃាតកមិនហ៊ានប្រឈមមុខនឹងការពិត ព្រោះខ្លាចអាម៉ាស់និងបាត់បង់កិត្តិយស ។ គំនិតលាក់លៀមគឺជាគំនិតអត្តទត្ថបុគ្គល ការគិតគូរប្រយោជន៍ជាតិទើបជាបរទត្ថបុគ្គល ។

## កត្តាសំខាន់ៗមួយចំនួនដែលនាំឲ្យមានវាលពិឃាតនៅកម្ពុជា

ឈរលើមូលដ្ឋានដែលខ្ញុំបានរស់នៅឆ្លងកាត់ច្រើនរបបគ្រប់គ្រង តាំងពីរបបអាណានិគមនិយមបារាំង សង្គមរាស្ត្រនិយម របបលន់នល់ របបកម្ពុជាប្រជាធិបតេយ្យ របបរដ្ឋកម្ពុជា និងរបបបច្ចុប្បន្ន បានញ៉ាំងឲ្យខ្ញុំត្រិះរិះពិចារណាស្វែងរកការពិតអំពីមូលហេតុសំខាន់ៗដែលបណ្តាលឲ្យមានកើតមានអំពើហិង្សានិងឈានទៅដល់ការសម្លាប់មនុស្សប្រមាណជិត២លាននាក់ ។ ខាងក្រោមនេះគឺជាការយល់ឃើញរបស់ខ្ញុំអំពីមូលហេតុសំខាន់ៗដែលនាំឲ្យមានវាលពិឃាតនៅប្រទេសកម្ពុជា÷

១) ការលូកដៃចូលជ្រៀតជ្រែកពីបរទេសៈ នយោបាយនិងមហិច្ឆតារបស់សហព័ន្ធឥណ្ឌូចិនរបស់បក្សកុម្មុយនិស្តវៀតណាម និងបក្សកុម្មុយនិស្តចិន ។

២) មនោគមវិជ្ជាកុម្មុយនិស្តម៉ាក្សលេនីនៈ ការអប់រំបំផុសវណ្ណៈកម្មករកសិករក្រីក្រនិងទាសករផ្សេងៗទៀតឲ្យមានការ

ឈើចាប់ ដើម្បីក្រោកឡើងតស៊ូប្រឆាំងវណ្ណៈសក្តិភូមិ នាយទុន មូលធន និងឈ្មួញកណ្តាល (ឯកសារសង្គមកម្ពុជានិងឯកសារស្តីអំពីទស្សនៈវណ្ណៈនិងការតស៊ូវណ្ណៈ) ។

៣) *ភាពផ្តាច់ការក្នុងការដឹកនាំៈ* របបកម្ពុជាប្រជាធិបតេយ្យមានចរិតផ្តាច់ការនិយម គ្មានគោលការណ៍កែប្រែអប់រំមនុស្ស ។ អ្វីៗដែលខ្មែរក្រហមចាត់ទុកថាជាទំនាស់បដិបក្ខគឺគ្មានការសម្របសម្រួលទេ ។ ដំណោះស្រាយមានតែម្យ៉ាងគត់គឺ “កម្ទេចចោល” ។

៤) *ការបែកបាក់សាមគ្គីភាពផ្ទៃក្នុងរបស់បក្សៈ* ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានមតិពីរបញ្ច្រាសគ្នា ។ មតិទីមួយដឹកនាំដោយ ហ៊ូ យន់ និង ហ៊ូ នឹម ចង់កសាងសង្គមមួយមានកម្រិតជាក្រុមសាមគ្គីបង្កបង្កើនផល មានលុយចាយ មានផ្សាររដ្ឋ ផ្សារប្រជាជន ដើម្បីដោះដូរផលិតផលពីតំបន់មួយទៅតំបន់មួយ មានប្រាក់ខែ ប្រាក់ឧបត្ថម្ភ កងទ័ពកម្មាភិបាល ។ មតិមួយទៀតជំទាស់ថា ធ្វើដូច្នេះមិនបានទេ ពីព្រោះនាំឲ្យសង្គមឱនថយ មានការបែងចែកវណ្ណៈ នៅមានកម្មសិទ្ធិឯកជន ដែលជាហេតុនាំឲ្យមានអំពើពុករលួយ ។ ដូច្នេះត្រូវអនុវត្តទៅតាមគោលការណ៍មហាលោតផ្លោះមហាអស្ចារ្យទើបអាចយកឈ្នះលើអ្វីៗទាំងអស់ ។

៥) *ជនឱកាសនិយមៈ* ខ្មែរក្រហមខ្លះរំលោភផ្លូវភេទជនរងគ្រោះបន្ទាប់មកសម្លាប់ចោលដើម្បីកុំឲ្យបែកការណ៍ ដូចមានករណីបងស្រី តាំង គីម ត្រូវខ្មែរក្រហមរំលោភគាត់និងនារី៧នាក់ទៀត ហើយមានតែគាត់ម្នាក់ប៉ុណ្ណោះដែលមានជីវិតរស់មកដល់បច្ចុប្បន្ន ។ បើខ្មែរក្រហមចង់រំលោភនារីរូបស្អាតណាម្នាក់ ខ្មែរក្រហមក៏ដាក់ក្នុងបញ្ជីខ្មៅ ពេលនោះបំណងរបស់ខ្មែរក្រហមអាចបានសម្រេច ។ ក៏ប៉ុន្តែករណីនេះមិនមែនជាមាគ៌ារបស់បក្សទេ ដូច្នេះទើបខ្ញុំហៅថា“ឱកាសនិយម” ។

៦) *មោទកភាពបុគ្គលនិយមៈ* កម្មាភិបាលយុទ្ធជនមួយចំនួនល្ងង់ខ្លៅ ឆ្កួតនិយម មានមោទកភាពក្នុងការសម្លាប់មនុស្សដើម្បីចង់បង្ហាញមេដឹកនាំរបស់ខ្លួនថាខ្លួនជាមនុស្សមានជំហរវណ្ណៈដាច់ខាត មិនសម្រុះសម្រួល មិនសន្តិសម័ន្ធ ។ សូម្បីតែបាក់នង្គ័លបាក់ចប ឬលួចដំឡូងហូបដោយសារតែការអត់ឃ្លាន ក៏ត្រូវខ្មែរក្រហមចាត់ទុកថាជាខ្មាំងដែរ ហើយទីបំផុតត្រូវយកទៅសម្លាប់ចោល ។

៧) *ការរើសអើងនៅក្នុងសង្គមចាស់ៈ* ការរើសអើងរវាងមន្ត្រីរាជការនិងប្រជារាស្ត្រ ឬរវាងថៅកែនិងកម្មករ រវាងអ្នកមានទ្រព្យស្តុកស្តម្ភនិងបាវបម្រើ បង្កើតបានជាគំនុំវណ្ណៈ ដែលទាំងនេះក៏ជាកត្តាមួយដែលនាំដល់ការសម្លាប់មនុស្សដែរ ។

៨) *គំនុំផ្ទាល់ខ្លួននិងការសងសឹកៈ* នៅពេលមានឱកាសកាន់អំណាច ខ្មែរក្រហមបានប្រែក្លាយគំនុំផ្ទាល់ខ្លួនទៅជាការសងសឹកចំពោះអ្នកដែលខ្លួនស្អប់ ។ ដូចករណី អាំ ហាន ជាមួយអតីតអ្នករួមថ្នាក់ ។ ដោយសារតែជននោះស្រឡាញ់ អាំ ហាន មិនបានក៏មានគំនិតឈ្នានីសប្តីរបស់ អាំ ហាន ហើយបានយកប្តីរបស់គាត់ទៅសម្លាប់ចោល ។

៩) *ប្រព័ន្ធសន្តិសុខនិងវិធីធ្វើទារុណកម្មសួរចម្លើយៈ* វិធីសាស្ត្របីយ៉ាងក្នុងការសួរយកចម្លើយរបស់ខ្មែរក្រហមនៅមន្ទីរស-២១ ដែលបានរៀបរាប់ដោយ ហ៊ឹម ហ៊ុយ គឺជាយុទ្ធសាស្ត្រមួយគួរឲ្យព្រឺព្រួច ។ វាជាមេរោគឆ្លងដ៏សាហាវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

១០) *អនីតិជននិងភាពល្ងង់ខ្លៅៈ* កុមារនិងអ្នកល្ងង់ខ្លៅត្រូវខ្មែរក្រហមលើកតម្កើងនិងជ្រើសរើសមកបំពាក់បំប៉នឲ្យធ្វើជាអ្នកដឹកនាំ ។ មនុស្សជំពូកនេះមិនចេះគិតគូរពិចារណាទេ ហើយមានចិត្តមោះមុតទៀតផង ។

១១) *ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបក្សៈ* ខ្មាំងទាំងនេះធ្វើសកម្មភាពគ្រប់បែបយ៉ាងដើម្បីផ្តួលរំលំក្បាលម៉ាស៊ីនដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ដូចជាមានផែនការធ្វើរដ្ឋប្រហារ សម្លាប់ថ្នាក់ដឹកនាំដោយដាក់ថ្នាំបំពុល អនុវត្តនយោបាយ“ស្មាស៊ីបាយលាបមាត់ពពែ” ឬពាក្យស្លោក “ដុតឲ្យខ្លោច រោចឲ្យឆៅ” ដើម្បីធ្វើឲ្យរាំងស្ទះដំណើរការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីទប់ស្កាត់នឹងបញ្ហានេះ អង្គការក៏បានចេញនូវនយោបាយបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុងរបស់ខ្លួនគ្រប់មន្ទីរអង្គភាពនានា នៅតាមឃុំ ស្រុក តំបន់ ភូមិភាគ ទូទាំងផ្ទៃប្រទេស ។

ទាំងអស់នេះគឺជាធាតុផ្សំនៃមហាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ ។

## ការកាត់ទោសមេដឹកនាំខ្មែរក្រហម

នៅក្នុងឆ្នាំ១៩៧៩ តុលាការប្រជាជនបដិវត្តន៍កម្ពុជាបានកាត់ទោសបនក្បត់ ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខពីបទប្រល័យពូជសាសន៍ ហើយដែលត្រូវផ្តន្ទាទោសប្រហារជីវិត ។ បន្ទាប់ពីនោះ សង្គ្រាមស៊ីវិលបានអូសបន្លាយអស់រយៈពេលជាង១០ឆ្នាំ ប៉ុន្តែរដ្ឋាភិបាលកម្ពុជាមិនបានយកជ័យជម្នះលើចលនាតស៊ូទ័ពព្រៃខ្មែរសេរីកានិងខ្មែរម៉ូលីណាកាបានឡើយ រហូតទាល់តែមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ទើបសង្គ្រាមរ៉ាំរ៉ៃនេះត្រូវបានបញ្ចប់ ។ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៦ សម្តេចព្រះ នរោត្តម សីហនុ បានប្រទានការលើកលែងទោសដល់ អៀង សារី ។ បន្ទាប់ពីនោះមកអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ពេលវេលា៨ឆ្នាំក្នុងការចរចាដើម្បីបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញមួយ ។ ការចរចាមានសភាពតានតឹងរហូតមានពេលខ្លះអង្គការសហប្រជាជាតិដកខ្លួនចេញដំណើរចរចានេះក៏មាន ។

ខ្ញុំពុំដែលមានសុទិដ្ឋិនិយមទាល់តែសោះចំពោះការនាំយកមេដឹកនាំខ្មែរក្រហមមកវិនិច្ឆ័យទោស ប៉ុន្តែខ្ញុំចង់ឃើញការកាត់សេចក្តីនេះប្រព្រឹត្តឡើងក្នុងពេលឆាប់នេះ តើវាមានសភាពសាំញ៉ាំនិងស្មុគស្មាញយ៉ាងដូចម្តេច? តើឧបសគ្គអ្វីខ្លះទៀតដែលត្រូវប្រឈមមុខ? តើតុលាការនេះជោគជ័យឬក៏បរាជ័យ?

ខ្ញុំដឹងថាច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមបានចូលជាធរមាន ហើយថវិកាសម្រាប់ដំណើរការតុលាការនេះក៏មានគ្រប់គ្រាន់ដែរ ប៉ុន្តែអ្វីដែលនៅខ្វះគឺសុឆន្ទៈពិតប្រាកដរបស់រាជរដ្ឋាភិបាលកម្ពុជា ពីព្រោះចម្លើយរបស់ខ្មែរក្រហមអាចនឹងធ្វើឲ្យប៉ះពាល់ដល់កិត្តិយសនិងលទ្ធិរបស់កុម្មុយនិស្តវៀតណាមនិងចិនដែលសព្វថ្ងៃកំពុងតែមានឥទ្ធិពលខ្លាំងមកលើកម្ពុជា ។

លើសពីនេះទៀត តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចនឹងធ្វើឲ្យប៉ះពាល់ដល់សមិទ្ធផលដែលវៀតណាមសម្រេចបានចាប់តាំងពីឆ្នាំថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩មក ។

## ជនដៃដល់ពិតប្រាកដ និងការទទួលខុសត្រូវ

ខ្ញុំសូមធ្វើការកត់សម្គាល់អំពីដំណើរការវិវត្តន៍របស់ខ្មែរក្រហមចាប់ពីពេលដែលលទ្ធិកុម្មុយនិស្តហូរចូលមកកម្ពុជានិងរហូតមកដល់បច្ចុប្បន្ននេះ ដើម្បីឲ្យបងប្អូនកាន់តែយល់ច្បាស់ថាតើនរណាជាជនដៃដល់ពិតប្រាកដដែលស័ក្តិសមនឹងទទួលទោស ។

ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះមានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗជាច្រើនបានកើតមានឡើង ។ កោះសន្តិភាពត្រូវភ្លើងសង្គ្រាមឆាបឆេះខ្ទេចខ្ទីក្លាយទៅជាផេះផង់ ។ ប្រជាពលរដ្ឋខ្មែរបានបាត់បង់ជីវិតអស់ប្រមាណជិត១លាននាក់នៅក្នុងសមរភូមិពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។ ចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យបាត់បង់ជីវិតមនុស្សប្រមាណជិត២លាននាក់ទៀត ។ ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បក្សកុម្មុយនិស្តវៀតណាមបានលូកដៃជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជាដោយអនុវត្តនយោបាយសហព័ន្ធឥណ្ឌូចិនលេបត្របាក់ទឹកដីខ្មែរ បណ្តាលឲ្យប្រជាពលរដ្ឋកម្ពុជាស្លាប់និងរងរបួសអស់ជាច្រើននាក់ទៀត ។

## អ្វីដែលខ្ញុំត្រូវធ្វើសម្រាប់មនុស្សជំនាន់ក្រោយ

ប្រសិនបើជនរងគ្រោះចោទសួរខ្ញុំថា ក្នុងនាមលោកជាអតីតខ្មែរក្រហមម្នាក់ដែរ តើលោកបានឃើញបានដឹងឮអំពីការសម្លាប់យ៉ាងរង្គាលប្រជាពលរដ្ឋខ្មែរដែរឬទេ? ប្រសិនបើចម្លើយរបស់ខ្ញុំដូចលោក ខៀវ សំផន ឬដូចអតីតខ្មែរក្រហមភាគច្រើននោះ នោះគឺមិនខុសពីដំរីស្លាប់យកចង្អេរបាំងនោះឡើយ ។ ខ្ញុំនឹងមិនធ្វើដូច្នេះទេ ។

ពីមុនខ្ញុំធ្លាប់គិតថា ខ្ញុំពិបាកនឹងធ្វើអ្វីៗសម្រាប់ជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ ពោលគឺខ្ញុំមានការខ្វល់ខ្វាយណាស់ ។ ឥឡូវកង្វល់នេះបានរលាយបាត់ហើយបន្ទាប់ពីខ្ញុំបានចូលរួមដំណើរទស្សនកិច្ចដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប្រសិនបើប្រវត្តិសាស្ត្រដ៏អប្រិយរបស់ខ្មែរក្រហមត្រូវបានដឹកកប់បាត់ វាជាប្រការមួយគួរឲ្យសោកស្តាយជាទីបំផុត ។

ដើម្បីទុកជាមរតកប្រវត្តិសាស្ត្រនិងទុកជាមេរៀនសម្រាប់ក្មេងជំនាន់ក្រោយ អ្វីដែលខ្ញុំយល់ថាខ្ញុំគួរតែធ្វើគឺរួមចំណែកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចងក្រងប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះ ។ **អៀប ឌុច**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនទ្វេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៍មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង ៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមនិស្សិតធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


ក្រុមដូនជីប្រជុំនៅបន្ទប់ព័ត៌មានសាធារណៈ

# ខ្ញុំខ្លាចខ្មែរក្រហម

ខ្ញុំកើតនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៨០ ក្នុងខេត្តកំពង់ស្ពឺ ជិតពីរឆ្នាំបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យឬរបបខ្មែរក្រហមផុតរលត់ទៅ ។ ទោះបីជារបបកម្ពុជាប្រជាធិបតេយ្យរលំរលាយនៅខែមករាឆ្នាំ១៩៧៩ហើយក៏ដោយ ក៏កងកម្លាំងខ្មែរក្រហមដែលសេសសល់នៅតែបន្តអុកឡុកបង្កអសន្តិសុខនិងបំភិតបំភ័យប្រជាជននៅតាមជនបទមួយចំនួនដែរ ។ នៅក្នុងកុមារភាពរបស់ខ្ញុំ អ្វីដែលខ្ញុំភ័យខ្លាចបំផុតគឺនៅពេលឮថា ខ្មែរក្រហមវាយលុកចូលដល់ភូមិដែលខ្ញុំរស់នៅ ។

ឪពុករបស់ខ្ញុំគឺជាមន្ត្រីនៅក្នុងជួររដ្ឋាភិបាល ។ គាត់មានភារកិច្ចជាច្រើនដែលត្រូវបំពេញ ប៉ុន្តែនៅពេលនោះខ្ញុំដឹងម្យ៉ាងថាគាត់មាននាទីយាមសាលាស្រុកនិងដើរល្បាតក្នុងព្រៃដើម្បីទប់ស្កាត់ការវាយឆ្មក់ពីសំណាក់ក្រុមខ្មែរក្រហម ។ គាត់និយាយប្រាប់ម្តាយខ្ញុំនិងខ្ញុំជារឿយៗ អំពីការប្រយុទ្ធជាមួយខ្មែរក្រហម ។ កាលណោះខ្ញុំនៅក្មេងណាស់ ខ្ញុំមិនដឹងអំពីស្ថានការណ៍ស្រុកទេសយ៉ាងណាទេ ប៉ុន្តែពេលដែលខ្ញុំឮអំពីជ័យជម្នះរបស់រដ្ឋាភិបាល ខ្ញុំធូរស្បើយក្នុងចិត្ត ។


ញាណ សុជាតិ ថតឆ្នាំ១៩៨៣

ឪពុករបស់ខ្ញុំមានឱកាសសម្រាន្តនៅផ្ទះតិចតួចណាស់ ។ ពេលមកផ្ទះម្តងៗ គាត់មិនឲ្យអ្នកណាដឹងថាគាត់មកទេ សូម្បីតែស្បែកជើងក៏គាត់មិនហ៊ានដោះទុកនៅមាត់ទ្វារដែរ ។

ពេលដែលឪពុកខ្ញុំមិននៅផ្ទះ ម្តាយរបស់ខ្ញុំភ័យខ្លាចណាស់ ។ ម្យ៉ាងគាត់បារម្ភអំពីសុខទុក្ខរបស់ឪពុកខ្ញុំ ម្យ៉ាងទៀតគាត់បារម្ភអំពីសុវត្ថិភាពរបស់កូនៗនៅឯផ្ទះ ។ ពេលវាយលុកចូលភូមិណាមួយ កងទ័ពខ្មែរក្រហមឆក់ប្លន់ទ្រព្យសម្បត្តិប្រជាជន និងសម្លាប់អ្នកណាដែលធ្វើការបម្រើរដ្ឋាភិបាល ។ ប្រសិនបើខ្មែរក្រហមចូលមកដល់ភូមិរបស់ខ្ញុំ ផ្ទះរបស់ខ្ញុំគឺជាគោលដៅដំបូងបង្អស់ ព្រោះឪពុកខ្ញុំជាមន្ត្រីរដ្ឋាភិបាល ។

ម្តាយខ្ញុំបានហៅអ្នកភូមិម្នាក់ឬពីរនាក់មកសម្រាន្តនៅផ្ទះខ្ញុំរាល់ពេលដែលឪពុករបស់ខ្ញុំមិននៅផ្ទះ ។ ខ្ញុំនៅចាំថា ព្រលប់មួយប្រហែលជាម៉ោង៥ឬ៦ មានដំណឹងថា កងទ័ពខ្មែរក្រហមបានចូលមកជិតដល់ភូមិរបស់ខ្ញុំហើយ ។ យប់នោះឪពុករបស់ខ្ញុំក៏មិននៅផ្ទះទេ ហើយអ្នកភូមិដែលធ្លាប់មកសម្រាន្តនៅផ្ទះរបស់ខ្ញុំក៏មិនហ៊ានមកព្រោះគាត់ត្រូវនៅជួបជុំនិងថែរក្សាគ្រួសាររបស់គាត់ដែរ ។ ម្តាយរបស់ខ្ញុំតឿនបង្ខំខ្ញុំនិងប្អូនៗហូបបាយពេលល្ងាចយ៉ាងប្រញាប់ប្រញាល់ ។ គាត់រៀបចំបង្វេចមានសម្លៀកបំពាក់ខ្លះៗនិងម្ហូបអាហារបន្តិចបន្តួច ហើយនាំកូនៗទៅស្នាក់នៅផ្ទះរបស់អ៊ុំខ្ញុំម្នាក់ទៀតក្នុងភូមិជាមួយគ្នា ។ ខ្ញុំនៅចាំថាយប់នោះ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំឲ្យពាក់អាវពណ៌ប្រផេះ ។

នៅសាលា ខ្ញុំត្រូវបានគ្រូបង្រៀនឲ្យស្អប់ខ្ពើមខ្មែរក្រហម ។ ខ្ញុំនៅចាំមេរៀនមួយដែលមានចំណងជើងថា «យើងស្គាល់ហើយ» ។ មេរៀននោះរៀបរាប់ពីអំពើព្រៃផ្សៃដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាក្នុងអំឡុងពេលដែលខ្លួនកាន់កាប់អំណាច ។ ពេលដែលខ្ញុំអានមេរៀននោះ ខ្ញុំអាណិតអាសូរជនរងគ្រោះជាខ្លាំង ។ ខ្ញុំចេះតែបារម្ភថារបបខ្មែរក្រហមនិងវិលត្រឡប់មកវិញម្តងទៀតកាប់សម្លាប់ប្រជាជនកម្ពុជាខ្លាំងក្លាជាងមុន ហើយខ្ញុំក៏នឹងត្រូវស្លាប់ដែរ ។ កុមារដែលមានអាយុស្របាលខ្ញុំនៅពេលនោះសុទ្ធតែបានទទួលការអប់រំបែបនេះ ។

ការភ័យខ្លាចរបស់ខ្ញុំបានរលាយបាត់នៅពេលដែលក្រុមបេសកកម្មជាន់ខ្ពស់របស់អង្គការសហប្រជាជាតិមកធ្វើការងារជាលើកដំបូងនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩១ ។ **ញាណ សុជាតិ**

# រួចពីស្លាប់

នាងខ្ញុំឈ្មោះ មាស ផល្លី អាយុ៤៨ឆ្នាំ បច្ចុប្បន្នជាគ្រូបង្រៀនថ្នាក់ទី៦ នៅសាលាបឋមសិក្សាបារាយណ៍ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ខ្ញុំសូមសរសេរអំពីជីវិតពិតរបស់ខ្ញុំនៅក្នុងរបបប៉ុលពត ។ មុននឹងខ្ញុំស្លាប់ទៅខ្ញុំចង់ឲ្យកូនចៅនិងប្រជាជនខ្មែរបានដឹងអំពីការលំបាករបស់ខ្ញុំ ។

ឈ្មោះហៅក្រៅរបស់ខ្ញុំគឺ អាផល ឪពុកខ្ញុំឈ្មោះ មាស ចន ម្តាយឈ្មោះ នូ សារុន បងប្រុសទី១ឈ្មោះ មាស វ៉ាន់នី បងប្រុសទី២ឈ្មោះ មាស ចាន់ទី ទី៣គឺរូបនាងខ្ញុំ មាស ផល្លី ទី៤ប្អូនប្រុសឈ្មោះ មាស ចាន់ថុល ទី៥ ប្អូនស្រីឈ្មោះ មាស ផល្លា ទី៦ប្អូនស្រីឈ្មោះ មាស ប៊ុនស៊ី ទី៧ប្អូនស្រីឈ្មោះ មាស សាវ៉ាត ទី៨ ប្អូនស្រីឈ្មោះ មាស ស្រីម៉ាប់ ទី៩ប្អូនស្រី ឈ្មោះ មាស ស្រីវឿន ទី១០ប្អូនស្រី ឈ្មោះ មាស ស្រីខួច ។ សរុបទាំងឪពុកម្តាយនិងរូបខ្ញុំផងមាន១២នាក់ ។


មាស ផល្លី បច្ចុប្បន្ន

នៅក្នុងអំឡុងឆ្នាំ១៩៧២ ខ្ញុំមានអាយុ១៣ឆ្នាំ ។ ក្រុមគ្រួសាររបស់ខ្ញុំបានភៀសខ្លួនពីស្រុកកំណើតគឺភូមិដា ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ទៅតាមក្រុមទាហានចេនឡា ។ យើងសម្រាកនៅកំពង់ថ្មបីយប់ទើបដើរទៅទៀតរហូតដល់ខេត្តកំពង់ធំ ។ នៅខេត្តកំពង់ធំយើងខ្ញុំជួបតែការភ័យខ្លាចដោយសារគ្រាប់ផ្លោងរបស់ខ្មែរក្រហម ។ កាលនោះមានឧទ្ធម្ភាគចក្រមកដឹកប្រជាជនទៅទីក្រុងភ្នំពេញក្រោមការគ្រប់គ្រងរបស់ លន់ នល់ ។ សមាជិកគ្រួសារខ្ញុំជិះយន្តហោះបែកគ្នា ពីរថ្ងៃក្រោយទើបបានជួបជុំគ្នាវិញ ។ មកដល់ភ្នំពេញ ឪពុកខ្ញុំនិងបងប្រុសពីរនាក់ចូលធ្វើទាហាន ។ ឪពុកខ្ញុំមាននាទីជាអ្នកបើកឡាន ។ បងប្រុសខ្ញុំម្នាក់បានស្លាប់នៅក្នុងសមរភូមិព្រែកអញ្ចាញនាជាយក្រុងភ្នំពេញ ។

ក្រុមគ្រួសារខ្ញុំរស់នៅភ្នំពេញបានជាងពីរឆ្នាំត្រូវខ្មែរក្រហមបង្ខំឲ្យចេញពីភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ យើងចេះតែដើរទៅមុខ យប់កន្លែងណាដេកកន្លែងនោះ មិនដឹងជាប៉ុន្មានថ្ងៃទេខ្ញុំមិនចាំ ទើបមកដល់ភូមិដា ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

មកដល់ភូមិកំណើតយើងនឹកស្មានថាបានសេចក្តីសុខ ប៉ុន្តែផ្ទុយស្រឡះពីការគិត ។ ដោយឪពុកខ្ញុំចេះជួសជុលម៉ាស៊ីនគ្រប់ធុននិងចេះបើកឡានផង អង្គការបានបញ្ជូនគាត់ទៅធ្វើការនៅភូមិភាគ (ខេត្តកំពង់ចាម) ។ យូរៗម្តង គាត់មកលេងម្តាយខ្ញុំនិងប្អូនៗខ្ញុំនៅផ្ទះ ។ បងប្រុសឈ្មោះ មាស វ៉ាន់នី ត្រូវបញ្ជូនទៅកងចល័តនៅទំនប់ខាងកើតកំពង់ថ្ម ។ ចំណែករូបខ្ញុំក៏ចូលកងចល័តដែរ លើកទំនប់ ធ្វើស្រែ ដកសំណាប មិនដែលបាននៅជួបជុំបងប្អូនទេ ។ ប្អូនប្រុសឈ្មោះ មាស ចាន់ថុល ទៅធ្វើចម្ការនៅចម្ការអណ្តូង ។ ម្តាយខ្ញុំនិងប្អូនៗផ្សេងទៀតនៅជុំគ្នា ។

ថ្ងៃមួយ ពេលដែលខ្ញុំកំពុងដកសំណាបនៅវាលបុស្សស្បូវ ប្រធានកងខ្ញុំប្រាប់ថាៈ "មិត្តផល! មិត្តឯងធ្វើការល្អ ហេតុនេះអង្គការឲ្យមិត្តឯងរៀបគ្រួសារឥឡូវនេះ" ។ ខ្ញុំឆ្លើយថាៈ "មិត្តបង ឲ្យខ្ញុំរៀបគ្រួសារជាមួយអ្នកណាបើខ្ញុំមិនដែលស្គាល់គេផង" ។ មេកងតបថាៈ "ឥឡូវនេះគេមិនបាច់ឲ្យស្គាល់គ្នាយូរទេនាំតែខាតពេលវេលា" ។ ដោយខ្លាចមិនហ៊ានប្រកែក ខ្ញុំបង្ខំចិត្តមករៀបគ្រួសារក្នុងសម្លៀកបំពាក់ពណ៌ខ្មៅបង់កក្រមា នៅក្នុងរោងបាយ ភូមិត្នោត ស្ថិតនៅក្នុងឃុំទ្រៀល ។

ពិធីរៀបការពេលនោះមានគូស្រករដែលត្រូវរៀបចំនួន៧គូ ហើយគូខ្ញុំគឺជាគូចុងក្រោយបង្អស់ ។ ប្តីខ្ញុំឈ្មោះ ប្រាក់ ទិន ជាប្រជាជនថ្មីដែរ ។ គាត់មានបងប្រុសម្នាក់ឈ្មោះ ប្រាក់ យុត និងម្តាយមេម៉ាយឈ្មោះ យាយយង់ ។ យើងទាំងពីរនាក់មិន

ដែលស្គាល់គ្នាទេពីមុនមក ។ ពេលរៀបការរួច ខ្ញុំមករស់នៅខាងប្តីនៅភូមិញ្ញោ ។ ចាប់ពីពេលនោះមកខ្ញុំបែកពីឪពុកម្តាយបងប្អូន ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ឪពុកខ្ញុំបានមកសួរសុខទុក្ខខ្ញុំនៅភូមិញ្ញោ ហើយផ្តាំខ្ញុំថាៈ «អាផល! បើបាត់ប៉ាយូរប៉ាស្លាប់ហើយ ។ បងប្រុសឯងត្រូវគេសម្លាប់បាត់ហើយ ព្រោះគេថាប៉ះពាល់សីលធម៌» ។ និយាយតែប៉ុណ្ណេះឪពុកខ្ញុំក៏ត្រឡប់ទៅវិញបាត់រហូតទៅ ។ ប្តីប្រពន្ធខ្ញុំរស់នៅភូមិញ្ញោទាំងការភ័យខ្លាច ។ អ្នកភូមិអាណិតអាសូរយើងទាំងពីរ បានឲ្យស្លឹកកណ្តបនិងកូនឈើខ្លះៗ ហើយប្តីខ្ញុំទៅច្រូតចែងម៉ែងពីវាលទន្លេដុំយកមកក្បៀបធ្វើជញ្ជាំងសង់បានជាកូនខ្ទមមួយនៅលើដីដែលអ៊ំស្រីម្នាក់ឲ្យស្នាក់នៅជាបណ្តោះអាសន្ន ។

យើងរស់នៅក្នុងកូនខ្ទមនោះបានប្រហែល៣-៤ខែ ។ យប់មួយ ប្តីខ្ញុំសួរខ្ញុំថាៈ «អាផល! នាងសុខចិត្តរត់ទៅជាមួយខ្ញុំទេ?» ខ្ញុំឆ្លើយថាៈ «ខ្ញុំមិនហ៊ានទៅទេ ខ្ញុំខ្លាចណាស់ទឹកច្រើនយ៉ាងនេះ» ។ គាត់និយាយថាៈ «បើអ៊ីចឹងយើងបែកគ្នាហើយ ។ បងជាប្រុសមួយរូបដែរមិនឈរឱបដៃឲ្យគេសម្លាប់នោះទេ បើថ្ងៃក្រោយនៅមានជីវិតបងមករកអូនវិញ» ។ គាត់និយាយអ៊ីៗច្រើនទៀតតែខ្ញុំមិនចាំ ណាហត់នឿយក្នុងការងារ ហើយនៅក្នុងវ័យ១៧ឆ្នាំផងងុយគេងច្រើនផង ក៏លង់លក់ទៅ ។ លុះព្រឹកឡើងខ្ញុំភ្ញាក់ដើម្បីទៅដកស្ទូង ពេលចេញមកដល់របងខ្ទមស្រាប់តែឃើញមួកស្លឹកត្នោតដែលគាត់ពាក់ធ្វើការរាល់ថ្ងៃដាក់លើរបងមុខខ្ទម ខ្ញុំក៏យកមួយនោះមកមើល ហើយក៏យល់ថាគាត់ទៅចោលខ្ញុំហើយ ។ ខ្ញុំភ័យណាស់រត់ទៅសួរម្តាយក្មេក ។ យាយយំឆ្លើយថាៈ «កុំមាត់កូន វាទៅពីរនាក់បងប្អូនវាបាត់ហើយ» ។ ខ្ញុំក្តុកក្តួលចិត្តជាខ្លាំង ប៉ុន្តែនៅតែទៅដកស្ទូងដូចធម្មតា ។ ចាប់ពីពេលនោះមកឈ្លបភូមិតាមដានខ្ញុំរាល់យប់ ។

ខ្ញុំរស់នៅម្នាក់ឯងរហូតដល់ចុងឆ្នាំ១៩៧៧ ។ ថ្ងៃមួយប្អូនប្រុសខ្ញុំឈ្មោះ មាស ចាន់ថុល ដែលធ្វើការនៅចម្ការអណ្តូងបានមកលេងផ្ទះនៅភូមិដាក្នុងថ្ងៃឈប់សម្រាក ។ ទើបតែដើរមកដល់ដើមភូមិ មីងម្នាក់ឃាត់វាថាៈ «ចាន់ថុល ឯងមករកអី? ម៉ាក់ឯងនិងប្អូនៗទាំងអស់របស់ឯងត្រូវខ្មែរក្រហមដឹកតាមរទេះគោយកទៅសម្លាប់អស់ហើយ ។ ឈ្លបប្រាប់ថាយកទៅនៅជាមួយប៉ាឯង ។ ចាន់ថុល កុំចូលភូមិដាអី ប្រញាប់ដើរទៅរកបងស្រីឯងនៅភូមិញ្ញោទៅ» ។ ចាន់ថុល ថ្លែងអំណរគុណអ្នកមីងនោះ ហើយដើរទៅទិសខាងជើងសំដៅទៅភូមិញ្ញោ ។ វាអង្គុយលើលូមួយតាមថ្នល់ជាតិ សម្លឹងមើលទៅភូមិញ្ញោ គិតក្នុងចិត្តថា «ប្រហែលជាបងខ្ញុំមិននៅរស់ទេមើលទៅ គាត់ប្រាកដជាស្លាប់បាត់ហើយ» ។ មួយសន្ទុះក្រោយមកវាបានឃើញដូនចាស់ម្នាក់ក៏សួរថាៈ «យាយៗ បងខ្ញុំឈ្មោះ ផល គាត់នៅដែរឬទេ?» ជីដូនឆ្លើយៈ «វានៅទេ ចៅឯងចូលទៅ» ។ ចាន់ថុល ត្រេកអរខ្លាំងណាស់ ។ ពេលជួបខ្ញុំ វាយំផងឱបខ្ញុំផងហើយនិយាយថា «បងអើយ ម៉ាក់យើងនិងប្អូនៗទាំងអស់ត្រូវគេសម្លាប់ហើយ» ។ យើងអង្គុយយំពីរនាក់បងប្អូន ។ ពេលនោះ ប្រធានភូមិញ្ញោដើរចូលមកប្រាប់ខ្ញុំថាៈ «មិត្តឯងទៅប្រាប់ប្រធានភូមិដាទៅកុំឲ្យគេរកហើយគេចោទថាភូមិយើងលាក់ខ្មាំង» ។ ព្រដូចនោះ ខ្ញុំដើរតម្រង់ទៅភូមិដាដើម្បីប្រាប់ប្រធានភូមិថា ចាន់ថុល នៅជាមួយខ្ញុំ ។ ពេលដើរចេញមកវិញ អ្នកភូមិម្នាក់អួសដៃខ្ញុំទៅរកកន្លែងស្ងាត់ហើយប្រាប់ថាៈ «អាផល! ឯងមកធ្វើអី? ប្រញាប់ត្រឡប់ទៅវិញទៅ ម៉ាក់ឯងនិងប្អូនឯងទាំងអស់គេដឹកតាមរទេះគោយកទៅសម្លាប់អស់ហើយ ។ នៅតាមផ្លូវ គាត់បោចអំពៅនៅលើរទេះបោះឲ្យគេ ហើយលើកដៃសំពះលាគេថាគាត់លាស្លាប់ហើយ» ។ ព្រដូចនោះខ្ញុំដើរត្រឡប់មកភូមិញ្ញោវិញយ៉ាងប្រញាប់បំផុត ។

យើងពីរនាក់បងប្អូននៅជុំគ្នាបានតែពីរថ្ងៃ ។ ថ្ងៃមួយយើងនាំគ្នាទៅស្ទូចត្រីនៅអូរមួយខាងជើងភូមិ ។ តាំងពីតូចរហូតដល់ធំខ្ញុំមិនដែលស្ទូចបានត្រីទេ ប៉ុន្តែថ្ងៃនោះខ្ញុំស្ទូចបានត្រីច្រើនណាស់ មានត្រីឆ្តោ ត្រីអណ្តែង បើថ្លឹងទៅបានប្រហែលជិតពីរគីឡូក្រាម ។ ពីរនាក់បងប្អូនត្រេកអរណាស់ យើងនិយាយគ្នាថា យកត្រីនេះទៅប្រឡាក់ហើយអាំងហូបជាមួយពោតក្រហមប្រហែលជាឆ្ងាញ់ហើយ ។ ពេលរសៀលម៉ោងប្រហែលជាងបួន យើងដើរត្រឡប់មកភូមិវិញ ។ ពុទ្ធោអើយ! អ្វីដែលគិតត្រូវរលាយអស់ ។ គ្រាន់តែមកដល់ខ្ទមវិញស្រាប់តែមានមនុស្សទៅតាមហៅថា «ចាន់ថុល មានគេមករក» ។ ពេលនោះព្រលឹងខ្ញុំហាក់ដូចជាធ្លាក់ពីលើចុងឈើ ។ ខ្ញុំភ័យណាស់ ។ យើងទាំងពីរនាក់ដើរទៅកណ្តាលភូមិក៏ឃើញ អាពៀន ប្រធានភូមិដា ឈរសម្លឹងមករកប្អូនខ្ញុំ

ហើយប្រាប់ថា «យើងមកយកចានថុលទៅវិញ» ។ គ្រាន់តែឮប៉ុណ្ណោះ ប្អូនខ្ញុំយល់ច្បាស់ថាវាប្រាកដជាស្លាប់ហើយ ។ វាសម្លឹងមុខខ្ញុំហើយពោលថា «បងស្រី! យើងបែកគ្នាហើយ ខ្ញុំលាហើយ» ។ ខ្ញុំយំឱបប្អូន ហើយប្រាប់អាពឿនថាៈ «មិត្តបងយកខ្ញុំទៅផង ខ្ញុំមិនអាចរស់នៅម្នាក់ឯងបានទេ» ។ អាពឿន ឆ្លើយថាៈ «យើងមិនយកមិត្តឯងទៅទេ ព្រោះយើងមិនក្តាប់មិត្តឯងឯណា ។ យើងយកតែមិត្តថុលទេ យើងក្តាប់អ្នកណាយើងយកតែអ្នកនោះ» ។ ថាហើយវាបង្ខំឲ្យប្អូនប្រុសខ្ញុំឡើងជិះលើកង់របស់វា ។ ប្អូនខ្ញុំបង្ហូរទឹកភ្នែកមើលមកខ្ញុំមិនឈប់ ។ មីងម្នាក់នៅភូមិញ្ញោបានចាប់ខ្ញុំបំបែកពីប្អូន ។ អាពឿនឌុបប្អូនខ្ញុំចេញពីភូមិញ្ញោនៅពេលថ្ងៃរៀបលិច ផ្ទៃមេឃមានពណ៌ក្រហមដូចមាសហាក់ដូចជាក្តៅចិត្តជាមួយខ្ញុំដែរ ។ ផ្លូវចេញពីភូមិញ្ញោបត់បែនក្វិចក្វក់អមដោយកូនត្នោតតូចៗ ខ្ញុំតាមមើលប្អូនម្តងបាត់ម្តងឃើញរហូតដល់ថ្ងៃលិចបាត់មើលលែងឃើញទើបខ្ញុំដើរសំដៅមករកកូនខ្ទមវិញទាំងល្ហិតល្ហៃនិងអស់សង្ឃឹម ។

ខ្ញុំរស់នៅម្នាក់ឯងក្នុងកូនខ្ទមដោយមានការផ្តល់ជាកម្លាំងចិត្តពីអ្នកភូមិ ។ ខ្ញុំខិតខំធ្វើការងារមិនដែលដែលហ៊ានសម្រាកសូម្បីតែមួយថ្ងៃ ។ កងចល័តពិសេសរបស់ខ្ញុំត្រូវទៅជីកប្រឡាយលើកទំនប់នៅទួលភ្នំទ្រាំងដែលស្ថិតនៅប្រមាណបីបួនគីឡូម៉ែត្រខាងកើតភូមិញ្ញោ ។ ទួលភ្នំទ្រាំងសម្បូរទៅដោយថ្មធំៗ ដូច្នេះយើងត្រូវបំបែកថ្មហើយលើកចេញដោយហុចបន្តគ្នាជាខ្សែ ។ ដោយការធ្វេសប្រហែស ខ្ញុំបានធ្វើឲ្យរបូតថ្មពីដៃធ្លាក់ត្រូវមេជើងខ្លួនឯងមុតហូរឈាមរហាម ។ ប្រធានកងនារីបានឲ្យខ្ញុំទៅសម្រាកនៅក្នុងរោង ហើយយកចិត្តទុកដាក់ខ្នះខ្នែងព្យាបាលរបួសខ្ញុំរហូតបានជាសះស្បើយ ។ ចាប់តាំងពីថ្ងៃនោះមក រាល់ពេលសម្រាកខ្ញុំតែងតែសម្រាកជាមួយប្រធានកងនារី ហើយច្រៀងតិចៗឲ្យគាត់ស្តាប់ បទស្នេហ៍មួយពាន់ដង បុរីជូឡុង ចម្ការសំរោង ។ យូរៗទៅប្រធានកងនារីអាណិតស្រលាញ់ខ្ញុំ មិនសូវឲ្យខ្ញុំទៅធ្វើការនៅខាងក្រៅទេ គាត់ឲ្យខ្ញុំនៅក្នុងរោងដេរម្ជុលស្លឹកត្នោតឬចាក់ស្រោមពិល ស្រោមដែកកេះ ។ ស្ត្រីមូលដ្ឋានមួយចំនួនផ្ដែផ្ដាំឲ្យខ្ញុំថាៈ «មិត្តផលមិនដែលចេញទៅធ្វើការទេ» ។ ប្រធានកងនារីឆ្លើយថាៈ «យើមីក្របី! ហងកុំចេះដឹងរឿងគេ ទៅធ្វើការទៅ» ។

ចប់ភារកិច្ចជីកប្រឡាយភ្នំទ្រាំង កងចល័តត្រឡប់មកភូមិវិញ ។

ដើមឆ្នាំ១៩៧៨ យាយតាពីរនាក់ជាចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិញ្ញោហៅខ្ញុំទៅរស់នៅជាមួយគាត់ ក្រោមការទំនុកបម្រុងនិងទទួលខុសត្រូវរបស់គាត់ ។ កាលនោះអង្គការឲ្យខ្ញុំដាំបាយនៅរោងបាយភូមិញ្ញោ ។ ពាក់កណ្តាលឆ្នាំ១៩៧៨ទឹកទន្លេឡើងធំជន់ជោរព័ទ្ធជុំវិញភូមិ ។ ជីដូនខាងម្តាយខ្ញុំដែលរស់នៅភូមិឈើលុំង ឃុំតាំងក្រសាំង ស្រុកសន្ទុក (សព្វថ្ងៃគាត់នៅរស់នៅឡើយ មានអាយុ៩០ឆ្នាំហើយ) បានឮថាខ្ញុំនៅរស់ម្នាក់ឯងនៅភូមិញ្ញោ ក៏អុំទូកជាមួយយាយម្នាក់ទៀតទៅរកខ្ញុំ ។ ជីដូនខ្ញុំឃើញភ្លាមគាត់យំរហូត រួចគាត់ផ្តាំផ្ញើនិងយាយតាដែលចិញ្ចឹមខ្ញុំឲ្យគាត់ជួយមើលថែគាត់ផង ។

ចុងឆ្នាំ១៩៧៨ ថ្ងៃមួយខ្ញុំកំពុងតែដាំបាយនៅក្នុងរោងបាយកណ្តាលភូមិ ។ ខ្ញុំឃើញកុមារីពីរនាក់ ម្នាក់អាយុប្រហែល១០ឆ្នាំ ម្នាក់ទៀតអាយុប្រហែល៧ឆ្នាំ ។ គ្រាន់តែក្រឡេកឃើញកុមារីទាំងពីរនាក់ភ្លាម ខ្ញុំហាក់ដូចជាស្រឡាញ់ណាស់ ព្រោះក្មេងទាំងពីរមានសាច់ឈាមមុខមាត់ស្រដៀងប្អូនរបស់ខ្ញុំ ។ ខ្ញុំយកកុមារីនេះមកអង្គុយលើភ្លៅឱបដោយក្តីស្រឡាញ់ ។ ប៉ុន្មានថ្ងៃក្រោយមក ចាស់ៗនិងយាយតាចិញ្ចឹមចាត់ចែងឲ្យខ្ញុំរៀបការជាមួយឪពុករបស់កុមារីនោះ ។ គាត់ឈ្មោះ នួន វណ្ណៈ ជាបុរសពោះម៉ាយមានកូន៥នាក់ ប្រុសបីនាក់ ស្រីពីរនាក់ ។ យើងទាំងពីររៀបការនៅក្នុងរោងបាយភូមិញ្ញោក្នុងសម្លៀកបំពាក់ខ្មៅបង់កក្រមារបៀបជាកងចល័ត ។ ថ្ងៃស្អែកឡើង កូនប្រុសច្បងរបស់គាត់ត្រូវអង្គការបញ្ជូនទៅធ្វើកងទ័ពហើយបាត់ខ្លួនរហូតដល់សព្វថ្ងៃ ។ តាំងពីរៀបការរួចមក ខ្ញុំហាក់ដូចជាបានធូរស្រាលខ្លះព្រោះកុមារីទាំងពីរនេះខស្សាហ៍ទៅជញ្ជាត់បានកូនត្រីតូចៗយកមកលីងហូបជាមួយបាយដែលខ្ញុំយកទៅផ្ទះ ។

ដាច់ឆ្នាំ១៩៧៨ចូលដល់ខែមករាឆ្នាំ១៩៧៩ យប់មួយនោះ ខ្ញុំឮស្នូរខ្ទររន្ទើដីយ៉ាងខ្លាំងនៅតាមផ្លូវជាតិលេខ៦ ។ នោះគឺជាសន្ទឹករថពាសដែក ។ ប្រជាជនខ្សឹបខ្សៀវគ្នាថា «ដាច់ហើយដាច់របបប៉ុលពតហើយ» ។ ខ្ញុំហៅគ្នាមកជុំប្រមូលបាយដែលនៅសល់ទាំងប៉ុន្មានចាក់ចូលកន្ត្រកមួយរួចគេចខ្លួនពួនក្បែរៗភូមិ ។ ព្រឹកឡើងស្រាប់តែឃើញប្រជាជនផ្អើលទៅដណ្តើមអង្ករ អំបិល

ចានឆ្នាំង របស់របរនៅក្នុងរោងបាយ ហើយសើចសប្បាយនិយាយគ្នាថា «យើងទាំងអស់គ្នាផុតពីស្លាប់ហើយ! យើងរស់ហើយ!» ។

យើងទាំងអស់គ្នាចាប់ផ្តើមកសាងជីវិតថ្មី ។ ខ្ញុំឈប់រស់នៅភូមិញ្ញោរទៀតហើយ យើងនាំគ្នាមករស់នៅភូមិកំញ៉ាតនៅក្នុងឃុំដដែល ។ ខ្ញុំដាក់ពាក្យសុំធ្វើជាគ្រូបង្រៀន ។ នៅឆ្នាំ១៩៨០ ខ្ញុំសម្រាលបានកូនប្រុសម្នាក់ដាក់ឈ្មោះ នួន វីរៈ ។ ម្តាយក្មេកខ្ញុំ (យាយយង់) ស្រលាញ់ខ្ញុំនិងកូនខ្ញុំណាស់ ។ គាត់បានជួយមើល វីរៈ ជាប់ជាប្រចាំ ។ ពេលដែល វីរៈ មានអាយុ១១ខែ ក្រសួងអប់រំបានតម្រូវឲ្យខ្ញុំទៅរៀនវគ្គបណ្តុះបណ្តាលគរុកោសល្យរយៈពេល៣ខែនៅវិទ្យាល័យកំពង់ធំ ។ ថ្ងៃនោះខ្ញុំបី វីរៈ ដោយមានកូនស្រីរបស់ប្តីខ្ញុំជួយយួរកាតាបផង ទៅជម្រាបលាម្តាយក្មេកថា «ម៉ែ! ខ្ញុំលាទៅរៀនហើយ ។ សូមម៉ែនៅទីនេះចុះ» ។ ម៉ែឆ្លើយតបថា «អើ! ទៅចុះកូនសូមឲ្យបានសេចក្តីសុខ ។ បើកូនមានប្រាក់ខែកូនធ្វើបុណ្យផងទៅ ប្រាថ្នាកើតជាតិណាៗកុំឲ្យព្រាត់គ្នាដូចជាតិនេះទៀត» ។ ខ្ញុំដើរចេញទៅទាំងហូរទឹកភ្នែកបណ្តើរ ។ បីខែក្រោយមក ខ្ញុំត្រឡប់ទៅភូមិកំញ៉ាតវិញ អ្នកភូមិប្រាប់ខ្ញុំថា យាយយង់ វិលទៅស្រុករបស់គាត់វិញហើយ ។ ខ្ញុំក៏បាត់ដំណឹងរបស់គាត់រហូតដល់សព្វថ្ងៃ ។

បច្ចុប្បន្ននេះខ្ញុំរស់នៅភូមិបារាយណ៍តូច ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានកូនបង្កើត៥នាក់ ស្រីម្នាក់ ។

សូមឲ្យការសរសេរនេះចងចាំក្នុងបេះដូងកូនខ្មែររហូត ។

**មាស ផល្លី**

បារាយណ៍តូច ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥

# ធ្វើអ្វីគ្រប់យ៉ាងឱ្យតែបានរស់

ព្រលឹមស្រាងៗថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំចេញទៅធាក់ស៊ីក្លូជាធម្មតាដើម្បីរកប្រាក់សម្រាប់រៀនសូត្រ ។ ព្រឹកនេះមានម៉ូយជិះស៊ីក្លូខ្ញុំច្រើនជាងធម្មតា ហើយបានតម្លៃថ្លៃទៀតផង ។ ប៉ុន្តែបន្តិចក្រោយមកមានសភាពផ្អើលឈូឆរខុសសព្វដងនិងឮស្នូរគ្រាប់កាំភ្លើងរន្ទាន់គ្រប់ទិសទី ។ ខ្ញុំប្រញាប់ធាក់ស៊ីក្លូយ៉ាងលឿនត្រឡប់ទៅកន្លែងស្នាក់នៅកុដិលេខ១៥វត្តប្រយូរវង្ស ។ បន្ទាប់ពីការរោទ៍ឡោភិតភ័យបន្តិចមក សភាពការណ៍ប្រែជាធូរស្រាលបន្តិចវិញ ។ ប្រជាពលរដ្ឋសប្បាយរីករាយ ប្រមូលគ្នាឈរកកកុញលើចិញ្ចើមមហាវិថីព្រះនរោត្តម ទះដៃអបអរសាទរ ខ្លះលើកក្រណាត់ស ខ្លះដោះអាវស គ្រវីដាក់កងទ័ពខ្មែរក្រហមដែលហៅថា «កងទ័ពរំដោះ» ព្រោះគិតថាចប់សង្គ្រាមហើយ ។ ខ្ញុំនិងព្រះសង្ឃនៅក្នុងវត្តក៏ចេញមកឈរគ្រវីដៃដែរ ។

### ដើរចូលចន្លោមបិសាចអាវខ្មៅ

ភ្លាមៗនោះ អ្វីៗប្រែជាផ្ទុយពីការគិត ។ កងទ័ពខ្មែរក្រហមដែលមានសម្លៀកបំពាក់ពណ៌ខ្មៅនិងមួរជើងខោម្ខាងដូចៗគ្នាកាន់អាវុធគ្រប់ធុន ដើរជាពីរជួរតាមមហាវិថីព្រះនរោត្តមពីត្បូងទៅជើងឆ្ពោះទៅវិមានឯករាជ្យ បានបង្ហាញទឹកមុខនិងបញ្ចេញពាក្យសម្តីគួរឲ្យព្រឺខ្លាច ។ បុរសម្នាក់កំពុងតែជិះម៉ូតូយឺតៗក្បែរចិញ្ចើមថ្នល់ ។ កងទ័ពខ្មែរក្រហមម្នាក់យកកាំភ្លើងភ្ជង់ក្បាលបុរសនោះ បញ្ជាឲ្យគាត់ចុះពីលើម៉ូតូ ដោះនាឡិកានិងខោអាវចេញទុកតែខោខ្លី បន្ទាប់មកដកហូតយករបស់របរទាំងអស់នោះ ហើយទាត់គាត់ពីរជើងព្រមទាំងគំរាមថា «បើមិនចង់ងាប់ទេឆាប់ចេញឲ្យឆ្ងាយទៅ!» ។ បន្ទាប់មក កងទ័ពខ្មែរក្រហមបាញ់កាំភ្លើងខ្លីសំដៅមកហ្វូងមនុស្សដែលឈរត្រៀបត្រា ហើយស្រែកទាំងកំហឹងថា «ឆាប់ចេញពីភ្នំពេញភ្លាម ប្រយ័ត្នយន្តហោះអាមេរិកមកទម្លាក់គ្រាប់បែក តែបីថ្ងៃទៀតអង្គការនឹងឲ្យចូលមកវិញ» ។

ប្រជាជនប្រញាប់ប្រញាល់រៀបចំអីវ៉ាន់ អ្នកខ្លះមានការឃឹតយ៉ាវដោយរង់ចាំបងប្អូនមកជុំគ្នា ចំណែកខ្ញុំក៏មិនទាន់បានចេញភ្លាមដែរ ព្រោះនៅលៃលករកចង្ហាន់ថ្ងៃត្រង់ប្រគេនលោក ។ ពេលនោះកងទ័ពខ្មែរក្រហមបានស្រែកខ្លាំងៗ តឿនយើងឲ្យ

ចេញហើយបាញ់កាំភ្លើងផ្គក់ធុន M៧៩ មួយគ្រាប់បណ្តាលឲ្យរបួសមនុស្សជាច្រើនរួមទាំងព្រះសង្ឃផង ។

នៅវេលាម៉ោង១០ព្រឹកថ្ងៃនោះ រូបខ្ញុំ បងប្រុសខ្ញុំ ព្រមទាំងលោកគ្រូមេកុដិព្រះនាម លឿង សុខ និងអ្នករួមកុដិបួននាក់ទៀត បានចាកចេញពីវត្តយ៉ាងតក់ក្រហល់ឆ្ពោះទៅក្បាលថ្នល់ជាមួយនឹងហ្វូងមនុស្សដ៏កកកុញ ។ យើងមិនអាចធ្វើដំណើរលឿនបានទេដោយសារចង្អៀតពេក ។

មកដល់វង្វង់មូលក្បាលថ្នល់ ខ្ញុំឃើញសាកសពទាហាននិងប្រជាជនដែលទើបតែស្លាប់ថ្មីៗនៅរដូករណែលតាមដងផ្លូវនិងលើចិញ្ចើមថ្នល់ ។ ភ្លាមនោះ ខ្ញុំឮស្នូរកាំភ្លើងជាច្រើនគ្រាប់នៅឯគល់ស្ពានព្រះមុនីវង្ស ។ មនុស្សបួននាក់បានដួលស្លាប់ភ្លាមមួយរំពេចដោយសារតែគាត់ព្យាយាមឆ្លងស្ពានព្រះមុនីវង្សខណៈដែលកងទ័ពខ្មែរក្រហមមិនអនុញ្ញាត ។

នៅក្រោមកម្ដៅថ្ងៃក្ដៅហែង ក្បួនមនុស្សចង្អៀតណែនដូចកាតំរំកិលទៅមុខយឺតៗជួនកាលឈប់ម្ដងៗ ហើយឮសំឡេងស្រែកសួររកឪពុកម្ដាយបងប្អូននិងសំឡេងក្មេងៗស្រែកយំដោយសារឃ្លានអាហារ ។ កងទ័ពខ្មែរក្រហមបាញ់កាំភ្លើងបញ្ចិតៗក្បាលប្រជាជនដើម្បីបង្ខំឲ្យទៅមុខឲ្យលឿន ។

ពេលរសៀលខ្ញុំមកដល់តាខ្មៅ ។ នារីខ្មែរក្រហមម្នាក់កាន់គ្រាប់បែកមួយគ្រាប់នៅក្នុងដៃ ស្ទុះមកក្របួចកអាវខ្ញុំហើយសម្លុតសួរថា “ឯងជាពួកកុម្ម៉ង់ដូមែនទេ?” ខ្ញុំឆ្លើយទាំងភិតភ័យថា “មិនមែនទេ ខ្ញុំជាសិស្សសាលា” ហើយខ្ញុំដកកាតសិស្សមកបង្ហាញ ។ នារីនោះមិនរវល់មើលកាតរបស់ខ្ញុំទេ ប៉ុន្តែច្រានខ្ញុំទៅក្រោយស្ទើរដួល ។ ឃើញសភាពមិនស្រួលបែបនេះ ខ្ញុំដើរប្រជ្រៀតយ៉ាងលឿនទៅរង់ចាំលោកគ្រូនិងសិស្សរួមកុដិនៅខាងមុខ ។ ខ្ញុំធ្វើដំណើរពីតាខ្មៅមកស្រុកស្អាង ក្រាំងយ៉ូវ រហូតដល់ព្រៃល្វា ស្រុកព្រៃកប្បាសខេត្តតាកែវ ដោយឈប់សម្រាកតាមផ្លូវអស់បីថ្ងៃបីយប់ ។ នៅតាមផ្លូវខ្ញុំបានឃើញសាកសពជាច្រើនដែលមើលទៅទំនងជាអ្នកចេញពីទីក្រុង ។ សពខ្លះហើមប៉ោងនិងមានសម្លៀកបំពាក់ទាហាន ។ កងទ័ពខ្មែរក្រហមបានឆែកឆេរប្រជាជនហើយដកហូតយកសម្ភារល្អៗដោយប្រើពាក្យថា “អង្គការស្នើ” ។ អ្នកណាដែលតវ៉ាមិនព្រមប្រគល់របស់ឲ្យតាមការស្នើ ត្រូវបាញ់សម្លាប់នៅនឹងមុខមនុស្សម្នា ឬចងបណ្តើរយកទៅបាត់ ។ ខ្ញុំមិនបានបាត់បង់អ្វីទេ ព្រោះក្នុងបង្វេចរបស់ខ្ញុំមានតែអង្ករនិងកញ្ចប់តែស្ករសម្រាប់ជាចង្ហាន់លោកប៉ុណ្ណោះ ។

## ប្រធានភូមិកំណាចអាចសម្លាប់មនុស្សរាប់រយនាក់

មកដល់ស្រុកកំណើតភ្លាម ខ្ញុំនិងបងខ្ញុំត្រូវបានប្រធានភូមិឈ្មោះ តាំង កោះហៅទៅសាកសួរនិងបង្ខំឲ្យខ្ញុំនិយាយអំពីការងារនៅក្នុងរបបលន់នល់ ដោយសន្យាថាអង្គការហៅទៅធ្វើការវិញ ។ ខ្ញុំនៅតែឆ្លើយដដែលៗថាខ្ញុំជាសិស្សសាលាស្នាក់នៅវត្តលោក ។ អ្នកដែលបានប្រាប់ត្រង់អំពីការងាររបស់ខ្លួនត្រូវអង្គការបញ្ជូនទៅបាត់រហូត ។ ពេលព្រលប់ កងឈ្លបនិងប្រធានភូមិប្រជុំគ្នាដោយមានខ្សែចំណង ចបកាប់ កាំបិត ហើយហៅបុរសនិងយុវជនខ្លះ (ជាប្រជាជនថ្មីទើបមកពីភ្នំពេញ) ទៅរៀនសូត្រ ។ អ្នកខ្លះត្រូវយកទៅទាំងគ្រួសារសូម្បីតែកូនតូចៗដោយប្រាប់ថាផ្លាស់ទីកន្លែងរស់នៅ ប៉ុន្តែអ្នកទាំងនោះត្រូវអង្គការសម្លាប់ទាំងអស់ ។

នៅឯការដ្ឋានជីកប្រឡាយ អង្គការភូមិ (ប្រធានភូមិនិងកងឈ្លប) ដើរចុះដើរឡើងលើខ្នងទំនប់មើលប្រជាជនធ្វើការ ហើយមកអង្គុយជក់បារីជុំគ្នាជិតកងយុវជន១៧មេសា ។ ឃើញដូច្នោះខ្ញុំគិតតែខំកាប់ដីមិនហ៊ានងើបមុខទេ ទោះបីស្រេកទឹកឬឈឺនោមក៏ទ្រាំសិនដែរ ។ អង្គការភូមិជជែកគ្នាសើចក្អាកក្អាយ និយាយលេងសប្បាយអំពីការសម្លាប់មនុស្ស ។ ជួនកាលអ្នកទាំងនោះនិយាយខ្លាំងៗទំនងចង់ឲ្យខ្ញុំឮថា “ពួកខ្មាំងសេ.អ៊ី.អានិងពួកអាកម្មសិទ្ធិស្ទួនត្លួវាទៅខ្លះហើយពីយប់មិញ ចាំមើលនៅមានអាណាខ្លះទៀត ។ ពួកវាទៅតែ៩ខែ១០ថ្ងៃត្រឡប់មកវិញហើយ” ។ ខ្លះទៀតនិយាយថា “ថ្លើមមនុស្សឆាលោតពេញខ្ទះរ៉ឺយ” ។ ឮសម្ដីសាហាវយង់ឃ្នងបែបនោះខ្ញុំធ្វើការផងភ័យផងហាក់ដូចជាគ្មានព្រលឹងក្នុងខ្លួន ។

យប់មួយ អង្គការមិនឲ្យប្រជាជនទៅជីកប្រឡាយទេ ប៉ុន្តែឲ្យប្រជាជនទូទាំងឃុំទៅចូលរួមមិទ្ទីងក្នុងបរិវេណវត្តអង្គាញ់ ។ អង្គការកំណត់ឲ្យប្រជាជនដើរជាជួរតាមក្រុមតាមកង ។ ប្រជាជនចាស់និងប្រជាជនថ្មីអង្គុយដាច់ដោយឡែកពីគ្នា ។

ខ្ញុំទៅដល់កន្លែងមិទ្ទីងឃើញមានចងទង់ពណ៌ក្រហមពាស

ពេញ ភ្លើងអគ្គិសនីភ្លឺព្រោងព្រាត លាយឡំនិងសម្រែក "ជយោ!" "ប្តេជ្ញា!" តាមមេក្រុយ៉ាងកងរំពង ។ នៅទល់មុខហ្វូងមនុស្សមាន រោងសង់ខ្ពស់ពីដីបន្តិច ប្រធានឃុំ ប្រធានភូមិ មេកង អង្គុយលើ កៅអីជង្គ្រង់ខ្នា ។ នៅសសរោងខាងមុខមានអ្នកទោសម្នាក់ដែល គ្រប់គ្នាស្គាល់ថាឈ្មោះ អាន ត្រូវចងឆ្កាងដាក់ច្រវាក់ដៃជើង និងមានកងឈ្លបប្រដាប់ដោយអាវុធ (កាំភ្លើង កាំបិតចុងស្រួច) ឈរពីក្រោយខ្នង ។ បន្ទាប់ពីមេកងម្នាក់ឡើងនិយាយអំពីសកម្មភាព របស់ អាន ដែលអង្គការចោទថាក្បត់បដិវត្តន៍រួចមក តំណាង តាមភូមិតាមកងបានឡើងស្រែកថ្កោលទោស ទះដៃហ៊ោកញ្ជ្រៀវ ក្នុងន័យប្រមាថអាយុជីវិតអ្នកទោសថា "ប្តេជ្ញាកម្ទេចក្បាល អាអាន! ត្រូវតែកាត់ក្បាលអាអាន! យកអាអានទៅធ្វើជី!..." ។ អង្គមិទ្ទីងទះដៃស្រែកបន្ទោរព្រមៗគ្នា ។ កងឈ្លបក៏សម្លាប់ អ្នកទោសភ្លាមៗ នៅនឹងកន្លែង រួចហើយប្រជាជនក៏បំបែកជួរ ទៅតាមកន្លែងរៀងៗខ្លួន ។

## រស់ទាំងស្រេកឃ្លាន ឆ្លើយថាមានហូបឆ្អែត

អង្គការខ្មែរក្រហមបានបញ្ជូនយុវជនយុវនារីរួមទាំងរូបខ្ញុំផង ទៅលើកទំនប់ធំមួយឈ្មោះ កំពង់ចក នៅខាងកើតព្រៃល្វា ។ ទម្រាំលើកទំនប់នោះរួចមនុស្សជាច្រើនបានបាត់បង់ជីវិតក្រោម ការធ្វើទារុណកម្មនិងការកាប់សម្លាប់ ។ បន្ទាប់មកអង្គការបញ្ជូន កងចល័តទៅបឹងភ្នំអង្គរបុរី ។ នៅទីនោះអង្គការប្រមូលផ្តុំមនុស្ស រាប់ពាន់នាក់ហើយដាក់ឈ្មោះថា "កងចល័តភាគនិរតី" ។ អង្គការ បង្ខំឲ្យកងចល័តធ្វើការនៅក្នុងទឹកទាំងថ្ងៃទាំងយប់ ហើយឲ្យដេក ផ្ទាល់ដីហាលសន្សើម ។ យើងទទួលបានបបរាវតែមួយ"កា" ប៉ុណ្ណោះក្នុងមួយពេល ។ ទោះបីជាតំបន់នោះសម្បូរត្រីសាច់ យ៉ាងណាក៏ដោយ ក៏អង្គការហាមដាច់ខាតមិនឲ្យនរណាម្នាក់ ចាប់ត្រីឬសត្វអ្វីធ្វើជាអាហារដែរ ។ បើហ៊ានល្មើសនឹងត្រូវធ្វើ ទារុណកម្មឬត្រូវសម្លាប់ចោល ។ ពេលកំពុងធ្វើការ បើនរណាម្នាក់ ចាប់បានអណ្តើកឬពស់ថ្លាន់ មេកងប្រមូលយកទៅធ្វើជាអាហារ ឆ្ងាញ់របស់គេ ហើយប្រាប់យើងថា យកពស់ថ្លាន់និងអណ្តើក ទៅបរទេសដើម្បីដូរយករថភ្លើងនិងត្រាក់ទ័រមកប្រើប្រាស់ ។

ថ្ងៃមួយ មេខ្មែរក្រហមឈ្មោះ "ម៉ុក" ទៅមើលកន្លែងដែល កងចល័តខ្ញុំធ្វើការ ។ "ម៉ុក" ចុះពីលើរថយន្តក្នុងសម្លៀកបំពាក់ ពណ៌ខ្មៅចំហឡេវអាវខាងក្រោមពេញអាវយឺតពណ៌សពីក្នុង ក្រវាត់ចង្កេះក្រមាសូត្រពណ៌ស្វាយ ដើរលើខ្នងទំនប់ដោយមាន កងការពារក្មេងៗបីនាក់ស្ពាយកាំភ្លើងដើរតាមពីក្រោយ ។ កងចល័ត សម្រុកធ្វើការងារកាន់តែខ្លាំង ហើយលបមើល តាម៉ុក ម្តងៗ ។ តាម៉ុក សួរថា "មិត្តទាំងអស់គ្នាហូបឆ្អែតទេ?" យើងឆ្លើយព្រម គ្នាថា "ឆ្អែត" ។ យើងមិនហ៊ាននិយាយការពិតទេ ព្រោះខ្លាច ស្លាប់ ។ តាម៉ុក បន្តទៀតថា "បន្តិចទៀតយើងនឹងមានបាយហូប មួយថ្ងៃបីពេល មួយពេលម្ហូបបីមុខ ព្រមទាំងមានម៉ាស៊ីនលាន ចាននិងម៉ាស៊ីនបញ្ចុកបាយទៀតផង" ។

## ទោះស្លាប់ក៏ដោយឲ្យតែបានហូបឆ្អែត

ពីមួយថ្ងៃទៅមួយថ្ងៃ មនុស្សនៅក្នុងកងចល័តស្លាប់ជាបន្ត បន្ទាប់ដោយជំងឺ ស្រេកឃ្លាន ពស់ចឹក បាត់ខ្លួន...។ល។ រាងកាយ របស់ខ្ញុំស្គមទៅៗ សក់ជ្រុះស្ទើរគ្មានសល់ ខោអាវពុកផុយរយ៉ៃ ពេលដើរត្រូវតែកាន់ឈើច្រត់ដើម្បីទប់ខ្លួន ។ គ្រប់គ្នាលបលួច ហូបចំណីអាហារទាំងឆៅ ទាំងសត្វនៅរស់ ទាំងស្លឹកឈើព្រៃ ចេះតែទំពាលេបឲ្យពេញក្រពះ ។ ជួនកាលហូបបបរសាបរយៈ ពេលបួនប្រាំថ្ងៃ មេកងប្រាប់ថាអង្គការដឹកអំបិលមកមិនទាន់ ។ នៅពេលតម្រង់ជួរចូលហូបបបរម្តងៗ មេកងមេក្រុមដើរឆែក មើលហោប៉ៅឬចង្កេះខោ មិនឲ្យមានលាក់កម្មសិទ្ធិចំណីអាហារ ក្រៅពីអ្វីដែលអង្គការកំណត់ឲ្យទេ ។ អ្នកដែលមានម្ហូបជាប់មក ជាមួយដូចជា ក្តាម ខ្យង កូនកង្កែប... ត្រូវមេកងចាប់ដកហូត យកមកជាន់ឈ្លីនឹងជើង ហើយចាប់វាយធ្វើទារុណកម្មបង្អត់ អាហារមួយពេលថែមទៀត ។

យុវជនក្នុងក្រុមខ្ញុំម្នាក់ត្រូវមេកងចោទថាបន្ទំហូបបបរ ពីរដង ហើយចាប់ចងដៃទៅក្រោយឲ្យដេកផ្កាប់ប៉ុន្តែងើបមុខឡើង រួចហើយមេកងយកស្បែកជើងកង់ឡានទះកំផ្លៀងនិងវាយមាត់ រហូតដល់សន្លប់ បន្ទាប់មកសែងយកទៅបាត់ ។

ព្រលប់មួយ ក្រោយពីចុងភៅចែកបបររួច គ្រប់គ្នាកំពុងតែ រង់ចាំសម្លមកដល់ ។ មេកងរបស់ខ្ញុំឈ្មោះ ទូច ដើរទៅមករាប់ ចំនួនមនុស្ស ព្រមទាំងមានកាន់បាយក្តាំងនៅដៃទំពាផង ។ ឃើញ ទូច ហូបដូចនោះខ្ញុំឃ្លានណាស់ក៏ដួសបបររបស់ខ្ញុំហូបពីរបីម៉ាត់ ដែរ ស្រាប់តែ ទូច ស្ទុះមកចាក់ខ្ញុំយ៉ាងដំណំ ហើយស្រែកឲ្យខ្ញុំថា

“ឃើញអញស៊ីប្រញាប់តែស៊ីតាមអញដែរ! ចង់ងាប់ឬ?” ។

ថ្ងៃបន្ទាប់មក ពេលល្ងាចឡើងពីធ្វើការ ខ្ញុំកំពុងតែតម្រង់ជួរចាំបបរ ស្រាប់តែឃើញកងទ័ពខ្មែរក្រហមពីរបីនាក់ ម្នាក់កាន់កាំភ្លើង ម្នាក់កាន់កាំបិតចុងស្រួច ម្នាក់កាន់ខ្សែអង្រឹង ដើរតម្រង់មករកខ្ញុំ ។ ពេលមកកៀក កងទ័ពទាំងនោះមិនចាប់ខ្ញុំទេ ប៉ុន្តែចាប់អ្នកដែលនៅជាប់នឹងខ្ញុំចងស្លាបសេកយ៉ាងតឹងហើយបណ្តើរចេញទៅដោយចោទថា ពីយប់មិញបានទៅលួចបាយសល់ដែលទុកសម្រាប់ឲ្យជ្រូកនៅមន្ទីរពេទ្យរបស់អង្គការ ។ សូម្បីតែអ្នកដែលលួចដណ្តើមបាយជាមួយឆ្កែរបស់មេកងក៏ត្រូវស្លាប់ដែរ ។ មនុស្សក្នុងកងជាច្រើននាក់ត្រូវឈ្លបចាប់ចងបណ្តើរយកទៅដោយសារតែលួចហូបក្រៅពីរបបអង្គការកំណត់ ។ អ្នកដែលលួចបាយក្តាំង ស្ករត្នោត អំបិល ឬដំឡូង អង្គការបានយកចំណីដែលលួចនោះក្នុងបរិមាណច្រើនលើសលប់ ដូចជា បាយក្តាំងមួយកញ្ជើធំ ស្ករត្នោតមួយពាង ឬអំបិលមួយចានធំ យកមកឲ្យអ្នកលួចនោះហូបតែមួយពេលឲ្យអស់ បើហូបមិនអស់នឹងត្រូវយកទៅសម្លាប់ ។ តើអ្នកណាហូបអស់? នេះជាការផ្ដាញ់ផ្ដាលរបស់អង្គការដ៏មហិមា ។

នៅរដូវវស្សា ខ្ញុំធ្វើការក្នុងទឹកទាំងយប់ទាំងថ្ងៃ ឈ្លើងទាមពាសពេញខ្លួនប្រាណ ចំណែកនៅរដូវប្រាំងវិញក្តៅហួតហែងរកតែទឹកហូបស្ទើរពុំបាន ។ ពីមួយថ្ងៃទៅមួយថ្ងៃ សុខភាពរបស់ខ្ញុំកាន់តែខ្សោយទៅៗ ។ ខោអាវមានតែមួយសម្រាប់រុំខ្លួនស្ទើរតែពុំជិត ។ រដូវរងាខ្ញុំត្រជាក់ស្ទើរតែគាំងដង្ហើម ។ ថ្ងៃមួយ ពេលត្រឡប់មកពីធ្វើការខ្ញុំដើរក្រោយគេ ហើយក្រឡេកឃើញខោអាវដែលពាក់នៅនឹងទីងមោងចាំចាបនៅល្អគ្រាន់បើ ខ្ញុំក៏ដូរយកខោអាវរបស់ទីងមោងមកពាក់វិញបានកក់ក្តៅជាងមុនបន្តិច ។

## ភ្នំសន្ទុង អន្ទង់មរណៈ

នៅខែ៣ ឆ្នាំ១៩៧៧ កងចល័តភាគនិរតីត្រូវអង្គការបញ្ជូនទៅនៅភ្នំសន្ទុង ។ នៅទីនោះគ្មានប្រជាជនរស់នៅទេ មានតែកងចល័តភាគនិងកងទ័ពខ្លះៗ ដែលអង្គការចោទថាមានកំហុស ។ នៅជុំវិញភ្នំមានកងទ័ពដែលប្រដាប់ដោយកាំភ្លើងយាមកាមយ៉ាងតឹងរ៉ឹង ។ មេធំខ្មែរក្រហមប្រចាំភ្នំសន្ទុងឈ្មោះ សឿន និង សេង ដែលកាន់កាំភ្លើងជាប់នឹងដៃជានិច្ចកាល ។ អង្គការប្រមូលមនុស្សផ្តុំគ្នាបែកក្រុមបែកកងសាជាថ្មី រួចប្រកាសប្រាប់ថា “ពួកឯងទាំងអស់គ្នាជាពួកដែលមានមេក្បត់អង្គការទើបត្រូវបញ្ជូនមកទីនេះ ដើម្បីរែងស្មែរើសយកតែដើមៗ អាណាចុងៗធ្លាក់ទៅក្រោម អាណាស្រូវរើសឲ្យមាន់ស៊ី ។ ពេលនេះបើពួកឯងគោរពចលនាបដិវត្តន៍មិនជាប់ទេនោះ កង់ប្រវត្តិសាស្ត្រនឹងកិនកម្ទេច” ។

ខ្ញុំនៅក្នុងកងលេខ៥៣ មេកងឈ្មោះ សាត ។ សមាជិកក្នុងកងនោះភាគច្រើនជាកងចល័តមកពីស្រុកអង្គរជ័យ ខេត្តកំពត ។

## គេចពីភ្នំសន្ទុងមកជាប់ដង់កងឈ្លប

យប់មួយ ខ្ញុំពិគ្រោះស្ងាត់ៗជាមួយឈ្មោះ សុង ដែលដេកក្បែរគ្នា អំពីគំនិតរត់គេចចេញពីភ្នំសន្ទុង ។ ខ្ញុំប្រាប់ សុង ថា “យើងត្រូវតែចេញនៅពេលថ្ងៃបន្ទំជាមួយអ្នកធ្វើការ ព្រោះពេលយប់យើងមិនដឹងថាកងទ័ពយាមនៅកន្លែងណាខ្លះទេ ។ បើយើងជួបខ្មែរក្រហមតាមផ្លូវទុកឲ្យខ្ញុំនិយាយតែម្នាក់ឯងបានហើយ ក្រែងលោកុហកមិនស្របគ្នា” ។

ព្រលឹមស្រាងៗពេលចេញទៅធ្វើការ ខ្ញុំនិង សុង បានគេចចេញពីជួរដោយប្រាប់អ្នកយាមថាទៅបត់ជើង ហើយក៏ដើរបង្ហួសឡើងផ្លូវធំសំដៅទៅផ្លូវជាតិលេខ២ ។ ព្រឹកភ្លឺច្បាស់ យើងចេញផុតបរិវេណភ្នំសន្ទុងមកដល់ភូមិអង្គតាភោគ បានជួបឈ្លបខ្មែរក្រហមក្មេងៗ២នាក់កាន់កាំបិតអង្គុយយាមនៅគុម្ពឫស្សីក្បែរផ្លូវ ។ ខ្ញុំធ្វើជាសួរឈ្លបទាំងពីរនាក់នោះថា “មិត្តមានឃើញក្រុមកាប់ឫស្សីធ្វើដងចបដើរមកមុននេះទេ?” ឈ្លបទាំងពីរនាក់សម្លឹងមុខខ្ញុំហើយឆ្លើយថា “មិនឃើញទេ” ។ ដឹងថាមិនអាចទៅមុខបាន ខ្ញុំក៏ធ្វើជាត្រឡប់មកក្រោយរកមេក្រុមវិញដើម្បីគេចរកផ្លូវផ្សេងទៀត ។ ឈ្លបទាំងពីរមិនព្រមឲ្យយើងបកក្រោយទេ ហើយឃាត់ខ្លួនយើងទាំងពីរនាក់នាំទៅទីទួលមួយ ។ ទៅដល់ទួលនោះ ឈ្លបទាំងពីរបញ្ជាឲ្យខ្ញុំទាំងពីរនាក់រែកដីនៅបាតត្រពាំងដ៏ជ្រៅមួយ ដោយមានឈ្លបម្នាក់អង្គុយយាម ចំណែកម្នាក់ទៀតទៅរាយការណ៍ឲ្យប្រធានឃុំ ។ ពេលថ្ងៃត្រង់ ឈ្លបអនុញ្ញាតឲ្យខ្ញុំទាំងពីរនាក់ឡើងមកហូបបបរគោកមួយចម្អែត ហើយបញ្ចូលក្នុងរោងមួយចាក់សោពីខាងក្រៅជាប់ ។

រសៀលគងភ្នំ ខ្ញុំលួចមើលតាមប្រហោងជញ្ជាំងឃើញនិរសារឃុំជិះសេះមកដល់ បន្ទាប់មកឃើញប្រធានឃុំជិះកង់មក

តាមក្រោយ ។ កងឈ្លបចាក់សោហើយនាំយើងទាំងពីរនាក់ទៅជួបប្រធានឃុំ ។ ខ្ញុំភ័យណាស់ ប៉ុន្តែខំតាំងស្មារតីធ្វើដូចធម្មតា ។ ប្រធានឃុំមើលមុខខ្ញុំហើយនិយាយថា "ឯងទាំងពីរនាក់ត្រឡប់ទៅភ្នំសន្ទុកវិញទៅ យើងរវល់ណាស់គ្មានអ្នកជូនទៅទេ ប៉ុន្តែមុននឹងទៅឯងត្រូវតែជម្រះស្មៅក្បែរទ្រុងទានេះឲ្យហើយសិន" ។ ពុសម្ដីនេះខ្ញុំត្រេកអរណាស់ ព្រោះបើឈ្លបនាំខ្លួនទៅដល់គុកភ្នំសន្ទុកនោះ ខ្ញុំទាំងពីរនាក់ពិតជាមិនរស់ទេ ព្រោះអ្នកដែលរត់ចេញពីភ្នំសន្ទុកហើយត្រូវឆ្មាំចាប់បាននឹងត្រូវសម្លាប់ចោលភ្លាម ។

ខ្ញុំនិង សុង ជម្រះស្មៅតែមួយភ្លែតហើយភ្លាមរួចក៏លាប្រធានឃុំចេញដំណើរ ។ យើងដើរតម្រង់ភ្នំសន្ទុក ប៉ុន្តែចេះតែលួចងាកមើលក្រោយក្រែងមានអ្នកតាមឃ្លាំមើល ។ ព្រលប់មកដល់យើងដើរបានឆ្ងាយផុតកន្ទុយភ្នែក ក៏រំកិលចុះក្នុងប្រឡាយទឹកសំណររហូតដល់យប់ងងឹតទើបលូនចូលព្រៃរពាក់ ។ មេឃងងឹតសូន្យ ភ្លៀងរលឹមស្រិចៗ ខ្ញុំរងាញ័រ ដំបៅនៅជើងត្រូវបន្លាឆ្កូតហូរឈាមសស្រាក់ ។ ម្ដងនេះខ្ញុំនិង សុង ដើរតាមផ្លូវកាត់តម្រង់ទៅរកផ្លូវជាតិ ។ ចៃដន្យយើងជួបក្បួនឡានដឹកកងទ័ពខ្មែរក្រហម យើងដើរឆ្លងទឹកគេចចុះឡើងរហូតវង្វេងផ្លូវ ។ មាន់រងាវយើងមកដល់ចំណុចដដែល គឺផ្លូវបំបែកទៅភ្នំសន្ទុក ។ យើងទាំងពីរនាក់អស់កម្លាំងខ្លាំងណាស់ លបចូលចម្ការដំឡូងមីដកហូបឆៅមួយចម្អែតទើបចេញដំណើរទៅទៀត ។

ព្រឹកព្រលឹមឡើង យើងដើរមកដល់ខ្នងទំនប់ថ្មសផ្លូវឆ្ពោះទៅអង្គរបូរី ។ ពេលនោះយើងឃើញកងទ័ពខ្មែរក្រហមដេរដាសកំពុងដកស្ទូងពេញវាលស្រែ ។ កម្មាភិបាលខ្មែរក្រហមម្នាក់កំពុងអង្គុយលើម៉ូតូលើខ្នងទំនប់ តាមសម្លឹងមើលមកខ្ញុំទាំងពីរនាក់ ប៉ុន្តែយើងតាំងអារម្មណ៍ដើរទៅធម្មតា ។ លុះដើរហួសបន្តិចកម្មាភិបាលនោះហៅខ្ញុំមកវិញហើយសួរថា "មើល៍អាពីរនាក់ឯងមកពីណាទៅណា?" ។ ខ្ញុំឆ្លើយថា "ខ្ញុំទើបចេញពីពេទ្យមិនដឹងកងក្រុមទៅណាអស់" ។ កម្មាភិបាលនោះសម្លុតខ្ញុំ "ពេទ្យកំពង់យោលនៅឯកើតហេតុអ្វីបានជាឯងដើរមកពីលិច?" ខ្ញុំដោះសាថា "ពេលចេញពីពេទ្យខ្ញុំទៅផ្ទះមីងខ្ញុំនៅភូមិអង្គរខ្មុរ តែមិនជួបគាត់ឥឡូវខ្ញុំទៅផ្ទះវិញ" ។ កម្មាភិបាលរូបនោះចុះពីលើម៉ូតូមកចង្អុលខ្ញុំ "ពួកកងរបស់ឯងទៅភ្នំសន្ទុកអស់ហើយ ពេលនេះមិនឲ្យអ្នកណាចេញពីពេទ្យទៅផ្ទះទេ ឥឡូវចុះស្រែធ្វើការភ្លាម!" ។

## បានរួចពីជង់មកជាប់នៅភ្នំសន្ទុកវិញដដែល

ខ្ញុំនៅជាមួយកងទ័ពខ្មែរក្រហមធ្វើការទាំងយប់ទាំងថ្ងៃ (ពេលថ្ងៃដកស្ទូង ពេលយប់រែកដីដំបូក) ប៉ុន្តែមានបាយហូបឆ្អែតម្ហូបឆ្ងាញ់ ។ ខ្ញុំខំប្រឹងធ្វើការណាស់ព្រោះសង្ឃឹមថាបាននៅទីនេះយូរ ប៉ុន្តែបានប្រហែល១០ថ្ងៃប៉ុណ្ណោះ កម្មាភិបាលកងទ័ពខ្មែរក្រហមបញ្ជូនខ្ញុំទាំងពីរនាក់តាមរថយន្តយោធាមួយគ្រឿងដែលដឹកថ្មពីភ្នំសន្ទុកមកធ្វើស្ពានលូ ឲ្យទៅភ្នំសន្ទុកវិញដដែល ។ ពេលទៅដល់ស្នាក់ការធំនៅភ្នំសន្ទុក ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហមឈ្មោះ សឿន និង សេង ដែលខ្ញុំស្គាល់ច្បាស់ ប៉ុន្តែខ្ញុំធ្វើពុតជាមិនស្គាល់ ។ ឈ្មោះ សឿន កាន់កាំភ្លើងខ្លីនៅដៃ ដើរមកចង្អុលមុខខ្ញុំហើយនិយាយថា "យី! មើលមុខអាពីរនាក់នេះដូចជាធ្លាប់នៅភ្នំសន្ទុក" ។ ខ្ញុំតាំងអារម្មណ៍ហើយឆ្លើយថា "ខ្ញុំមិនដែលស្គាល់ភ្នំសន្ទុកទេ" ។ ភ្លាមនោះអ្នកបើកឡានក៏បន្ថែមថា "អាពីរនាក់នេះទើបចេញពីពេទ្យកំពង់យោល ហើយមកងវរៈបានផ្ញើតាមឡានខ្ញុំមក" ។ សឿន សម្លឹងមុខខ្ញុំម្ដងទៀតហើយបញ្ជាឲ្យឈ្លបយកខ្ញុំទាំងពីរនាក់ទៅដាក់ក្នុងផ្ទះមួយចាក់សោទុកសិន ។

## ទទួលទារុណកម្ម រង់ចាំមរណា

ខ្ញុំជាប់នៅក្នុងផ្ទះមួយបិទជិតចាក់សោពីខាងក្រៅ ។ នៅក្នុងផ្ទះនោះមានខ្នោះជើង ច្រវាក់ ដំបង រំពាត់ កាំបិត ឧបករណ៍ធ្វើទារុណកម្មគ្រប់ប្រភេទ ។ មនុស្សជាច្រើនជាប់នៅក្នុងផ្ទះនោះដៃជើងជាប់ច្រវាក់ ខ្លះមានឈាមហូរពេញខ្លួន ។ អ្នកទាំងនោះភាគច្រើនជាអតីតកងទ័ពខ្មែរក្រហម ។ មួយថ្ងៃក្រោយមកឈ្លបនាំខ្ញុំទៅកន្លែងមួយផ្សេងទៀត ។ អង្គការបង្ខំឲ្យខ្ញុំវាយថ្មនិងសែងថ្ម ។ របបអាហារដែលខ្ញុំទទួលបានគឺបបររាវលាយព្រលឹតឬដើមចេក ។ ជួនកាលអង្គការបង្អត់អាហារអ្នកទោសមួយថ្ងៃឬពីរថ្ងៃដោយនិយាយថា ប្រជាជនកំពុងតែខ្វះខាត អង្គការចែករំលែកស្រូវអង្ករទៅឧបត្ថម្ភគាត់សិន ។ អ្នកទោសគ្មានអ្វីហូបក្រៅពីចាប់សត្វល្អិតឬបូតស្លឹកឈើមកហូបបំពេញក្រពះ ។

ខ្លួនខ្ញុំកាន់តែទ្រុឌទ្រោមទៅ មេកងធ្វើទារុណកម្មខ្ញុំកាន់តែខ្លាំង ។ ដើម្បីចៀសវាងទារុណកម្ម ខ្ញុំខំធ្វើការខ្លាំងបំផុត ទោះបីជារែកថ្មពីរបង្គីមិនរួចក៏ខំយកបង្គីមួយចងខ្សែវែងពាក់លើស្មា

ហើយដាក់ថ្នូសទៅដែរ ។ ឆ្មាំខ្មែរក្រហមម្នាក់ៗមានកាំភ្លើងខ្លីមួយដើមនិងដំបងប្អូរំពាត់ ព្រមទាំងចំពាមកៅស៊ូមួយផង បានប្រើអ្នកទោសឲ្យកាយដីឥដ្ឋលញ់ធ្វើគ្រាប់ឃ្លីហាលឲ្យស្ងួត ។ ឆ្មាំប្រើប្រាស់គ្រាប់នោះមកបាញ់អ្នកទោសនឹងចំពាមកៅស៊ូជាការកម្សាន្តសប្បាយ ។ ពេលខ្លះឆ្មាំបាញ់ប្អូវាយទាត់ធាក់អ្នកទោសរហូតដល់ដួលដេកសន្លប់នៅនឹងកន្លែងធ្វើការក៏មាន ។ អ្នកទោសខ្លះត្រូវឆ្មាំវាយបែកឈាមពេញខ្លួន ហើយចងបណ្តើរតាមបណ្តោយការដ្ឋានស្រែកអាក្រោសថា “កុំយកគំរូតាមខ្ញុំព្រោះខ្ញុំទំនាស់ជាមួយអង្គការ” ។ ថ្ងៃមួយ កម្មាភិបាលខ្មែរក្រហមឈ្មោះ សឿន មកពិនិត្យការដ្ឋានដោយនាំឆ្កែធាត់ៗ៣ក្បាលមកជាមួយផង ។ សឿន បានបង្ហោរឆ្កែឲ្យខាំអ្នកទោសពីរនាក់ដែលដើរយឺតរហូតដល់អ្នកទោសនោះប្រកាច់ស្លាប់ភ្លាម ។

នៅពេលព្រឹក ខ្មែរក្រហមប្រើអ្នកទោសដែលនៅមានកម្លាំងគ្រាន់បើឲ្យជីករណ្តៅធំៗ ។ ពេលរសៀលអូសសាកសពអ្នកដែលស្លាប់ទម្លាក់ក្នុងរណ្តៅនោះរួចកាយដីលុបវិញ ស្អែកឡើងឲ្យកាប់រណ្តៅថ្មីទៀត ។

ពេលព្រលប់ដល់ម៉ោងសម្រាកពីការងារ អង្គការប្រមូលមនុស្សមកតម្រង់ជួរដើម្បីរាប់ចំនួន ។ បុរសនិងស្ត្រីឈរដោយឡែកពីគ្នា ។ ពេលរាប់ចំនួនអ្នកទោស ឆ្មាំប្រើពិលវាយក្បាលអ្នកទោសពីដើមទៅចុងជួរដោយស្រែកខ្លាំងៗថា “១ ២ ៣...” ។ ជួនកាលរាប់ច្រឡំ ឆ្មាំចាប់ផ្តើមរាប់សាថ្មីឡើងវិញ ។ ខ្ញុំដែលឈរនៅដើមជួរជួនកាលត្រូវពកក្បាលពីរដងក៏មាន ។ បន្ទាប់ពីរាប់ចំនួនរួចហើយ ឆ្មាំបញ្ជូនអ្នកទោសបុរសចូលក្នុងរោងដែលមានខ្នោះជើងរាប់រយកំពុងតែរង់ចាំនិងមានដែកវែងស៊កតាមប្រឡោះខ្នោះរួចហើយចាក់សោនៅចុងម្ខាងទៀត ។ ចំណែកអ្នកទោសស្ត្រីត្រូវរុញបញ្ចូលរោងវែងៗដែលមានជញ្ជាំងធ្វើអំពីដីឥដ្ឋគ្មានបង្អួច ហើយចាក់សោពីក្រៅ ។ អ្នកណាដែលដើរមិនរួចឆ្មាំមិនរវល់ដាក់ខ្នោះជើងទេ បណ្តោយឲ្យដេកដួលនៅកន្លែងណាក៏ស្រេចតែចិត្ត ព្រោះនៅបរិវេណខាងក្រៅមានឆ្មាំយាមច្រើនណាស់ មិនបារម្ភខ្លាចអ្នកទោសរត់ទេ ។ ពេលជិតភ្លឺ ឆ្មាំផ្ទុកញ្ញែ


ការដ្ឋានមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ដាស់អ្នកទោសឲ្យក្រោកឡើង ដោះខ្នោះហើយឲ្យតម្រង់ជួររាប់ចំនួនរួចទៅធ្វើការ ។

### បានរស់ព្រោះទឹកជាត់បាយនិងទឹកដូងខ្ចី

កម្លាំងខ្ញុំកាន់តែចុះខ្សោយ មិនយូរប៉ុន្មានក៏ដើរលែងរួច ។ ខ្ញុំព្យាយាមស្គាត់ជួបមិត្តម្នាក់ឈ្មោះ ស៊ិន ។ ស៊ិន និងខ្ញុំរំកិលមកដេកក្បែរគ្នាក្រោមផ្ទះមួយដែលនៅមិនឆ្ងាយប៉ុន្មានពីរោងចុងភៅ ។ អ្នកដែលឈឺដើរមិនរួច អង្គការមិនប្រើឲ្យធ្វើការងារទេ គឺទុកឲ្យស្លាប់ដោយខ្លួនឯង ។ បបររាវបន្តិចបន្តួច ជួនមានជួនអត់ ខ្ញុំកខ្វេសកខ្វាសរកអាហារបន្ថែម (សត្វល្អិតនិងស្លឹកឈើ) ដើម្បីបំពេញក្រពះរង់ចាំសេចក្តីស្លាប់ ។

ព្រឹកមួយ ខ្ញុំអស់កម្លាំងស្ទើរដាច់ខ្យល់ ដៃជើងកម្រើកមិនរួច ភ្នែកខ្ញុំស្រវាំង ត្រចៀកខ្ញុំហ៊ឹងស្តាប់អ្វីមិនឮ ។ ខ្ញុំបិទភ្នែកសំងំ ។ ពេលខ្ញុំដឹងខ្លួនឡើងវិញឃើញ ស៊ិន អង្គុយជិតក្បាលខ្ញុំ ដៃម្ខាងកាន់ត្រឡោកដូងមួយ ដៃម្ខាងកាន់ស្លាបព្រា បញ្ចុកទឹកបាយឲ្យខ្ញុំ ។ ស៊ិន និយាយខ្សាវៗប្រាប់ខ្ញុំថា «អម្បាញ់មិញខ្ញុំបានទៅសុំទឹកបាយដែលចុងភៅជាត់ចោល (បាយដែលដាំសម្រាប់មេកង) យកមកបញ្ចុកឲ្យឯង» ។ ខ្ញុំអួលដើមកនិយាយមិនចេញ ទឹកភ្នែករមៀលមកប្រោក ។ ស៊ិន ក៏ស្រក់ទឹកភ្នែកដែរ ។ បីថ្ងៃក្រោយមក ពេលជិតភ្លឺស្រាងៗខ្ញុំឃើញ ស៊ិន ស្លាប់បាត់ទៅហើយ ។ ខ្ញុំបួងសួងឲ្យ ស៊ិន បានទៅកាន់សុគតិភព ហើយកុំមកចាប់កំណើតនៅលើភពផែនដីដ៏ចង្រៃនេះទៀត ។

អង្គការប្រមូលអ្នកដែលដើរមិនរួចទៅដាក់ក្នុងរោងវែងៗ (រោងប្រក់ស្លឹក គ្មានជញ្ជាំង) ឲ្យដេកជាជួរ បុរសម្ខាង ស្ត្រីម្ខាង ទល់ជើងគ្នា ។ ម្នាក់ៗមានរូបរាងកាយស្គមស្គាំងស្បែកដណ្តប់ឆ្អឹង ក្បាលរលីងគ្មានសក់ ភ្នែករូង ថ្ពាល់ជត មុខខ្វូងដូចខ្មោច ក្លិនស្អុយឆ្អេះឆ្អាប ចៃសាច់ចេញតាមថ្នេរខោអាវ ខ្លួនប្រាណកើតដំបៅរមាស់ពាសពេញ ពេលកម្រើកកឬដៃជើងម្តងៗឮស្នូរប្រេសប្រស់ដូចកង់បែកគ្រាប់ ។ រយៈពេលពីរឬបីថ្ងៃម្តងមានកម្មាភិបាលពេទ្យក្មេងៗ (អាយុក្រោម១០ឆ្នាំ) យកថ្នាំទឹកពណ៌ក្រហមឬសក្នុងដបទឹកក្រូចមកចាក់ឲ្យ ។

ថ្ងៃមួយ ខ្ញុំអស់កម្លាំងជាពន់ពេក បិទភ្នែកស្ទើរដេកលក់ស្ទើរសន្លប់ ។ ពេលខ្ញុំដឹងខ្លួនឡើងវិញឃើញដូងខ្ចីពីរផ្លែព្យួរនៅចុងជើងខ្ញុំធ្វើជាសេរ៉ូមដោតបញ្ចូលសរសៃជើងរបស់ខ្ញុំ ។ ឃើញខ្ញុំដឹងខ្លួន កម្មាភិបាលពេទ្យដោះសេរ៉ូមនោះចេញហើយចាក់ទឹកដូងដែលនៅសល់ឲ្យខ្ញុំផឹក ។ ខ្ញុំមានកម្លាំងប្រើស ។ ចាប់ពីពេលនោះមកខ្ញុំក៏បានរស់បន្តទៀតនៅកណ្តាលចំណោមសាកសព ។

### ដេកមិនរួចសោះនៅចន្លោះខ្មោច

ល្ងាចថ្ងៃមួយ អ្នកទោសដែលនៅជាប់ខាងស្តាំដៃខ្ញុំត្រដរខ្យល់ស្លាប់យ៉ាងវេទនា ។ អង្គការមិនទាន់យកសាកសពចេញទៅព្រោះរណ្តៅដែលជីកប្រចាំថ្ងៃនោះពេញអស់ទៅហើយ ត្រូវរង់ចាំរណ្តៅថ្មីនៅថ្ងៃស្អែក ។ ពាក់កណ្តាលយប់ អ្នកទោសដែលនៅខាងឆ្វេងដៃរបស់ខ្ញុំចាប់ផ្តើមកន្ត្រាក់ដៃជើង ដកដង្ហើមឮសូរគ្រូកក្រុក មួយសន្ទុះក៏ស្លាប់ទៀត ។ ពេលនោះខ្ញុំមិនអាចរំកិលទៅណាបានទេព្រោះចង្អៀតណែនពេក ម៉្លោះហើយទ្រាំដេកនៅចន្លោះខ្មោច ។ ពេលជិតភ្លឺសាកសពទាំងពីរត្រជាក់ស្រេប ធាតុអាកាសក៏កាន់តែរងា ។ ខ្ញុំទ្រាំមិនបានក៏ទាញកំណាត់ភួយស្តើងមួយផ្ទាំងពីលើខ្លួនសាកសពមកដណ្តប់ទើបបានកក់ក្តៅខ្លះ ។ សពទាំងពីរត្រូវស្រមោចក្រហមរោមពេញមុខមាត់និងភ្នែក ។

ព្រឹកឡើងទើបនារីពេទ្យធាត់ៗពីរនាក់កាន់ស្នែងឬអង្រឹងបាវក្រចៅមកសែងសាកសពយកទៅកប់ ។ គេសែងសាកសពម្តងពីរ គឺមួយដាក់ផ្ងារ ហើយមួយដាក់ផ្កាប់ពីលើ ។ ទៅដល់មាត់រណ្តៅគេឈរទល់មុខគ្នាយោលសាកសពហើយក្រឡាប់ចាក់ចូលទៅក្នុងរណ្តៅ ។ កន្លែងកប់សាកសពនៅមិនឆ្ងាយពីរោងដែលខ្ញុំដេកប៉ុន្មានទេ ដូច្នេះខ្ញុំអាចមើលឃើញគ្រប់សកម្មភាពទាំងអស់ ។

### ស្លាប់ទៅជាខ្មោចហើយអង្គការទាញយកប្រយោជន៍ទៀត

មនុស្សនៅក្នុងរោងកាន់តែហោចទៅៗ ។ ៦ឬ៧ថ្ងៃក្រោយមក អង្គការប្រមូលអ្នកជំងឺផ្សេងទៀតមកដាក់បំពេញវិញដដែល ។ អ្នកដែលមានកម្លាំងគ្រាន់បើត្រូវខ្មែរក្រហមបញ្ជាឲ្យទៅគាស់រណ្តៅយកខ្មោចមកដុត ហើយអ្នកដែលមានកម្លាំងតិចតួចដូចខ្ញុំដែលអាចអង្គុយឬគោងដើរបានខ្លះ អង្គការឲ្យអង្គុយដំឆ្អឹងដែលដុតហើយនោះដើម្បីយកទៅធ្វើជីដាក់ដំណាំ ។ អង្គការចាត់ទុកថាជីធ្វើពីមនុស្សគឺជាជីពិសេស ល្អលេខ១ ។

### ភ្នំជ្រៃហូឡោ លំនៅចុងក្រោយ

ក្នុងខែ២ ឆ្នាំ១៩៧៧ អង្គការប្រមូលអ្នកទោសដែល

សេសសល់ពីស្លាប់នៅភ្នំសន្ទុងទៅជួបជុំគ្នានៅកន្លែងមួយ ។ ថ្ងៃនោះ អង្គការមិនឲ្យយើងធ្វើការងារអ្វីទេ ព្រមទាំងចែកបបរឲ្យច្រើនជាងសព្វដងទៀតផង ។ ហូបបបររួចមួយសន្ទុះ រថយន្តធុនធំ (គ្មានដំបូល) ចំនួនប្រាំគ្រឿងបានមកដល់ ។ ខ្មែរក្រហមចាត់ចែងឲ្យអ្នកទោសឡើងឡាន អ្នកណាដែលឡើងមិនរួចឈ្លបចាប់បោះឡើង ។ ទាំងខ្ញុំទាំងអ្នកឯទៀតមិនដឹងថាអង្គការបញ្ជូនទៅទីណាទេ ចេះតែសំងំស្ងៀមក្នុងរថយន្ត ។

រសៀលថ្ងៃជិតលិច រថយន្តទៅដល់ភ្នំមួយដែលខ្ញុំស្គាល់ថាជាភ្នំជ្រៃហ្វូញ្ញោ ។ ឈ្លបប្រគល់មនុស្សឲ្យមេកងថ្មីនៅទីនោះ ចំណែកអ្នកដែលដើរមិនរួចនិងសាកសពដែលស្លាប់លើឡានត្រូវឈ្លបដឹកយកទៅបាត់ ។

## មិនបានរស់ព្រោះតែចង់ឆ្អែតម្តងទៀត

មេកងថ្មីបែងចែកមនុស្សជាកងជាក្រុមសាជាថ្មី ។ រួចហើយមេកងបញ្ជាឲ្យមនុស្សទាំងអស់ដើរជាជួរទៅហូបបាយនៅក្នុងរោងមួយ (រោងគោ) ។ មេកងណែនាំថា “ពេលនេះអង្គការឲ្យបងប្អូនហូបឆ្អែតបរិបូរណ៍ ប៉ុន្តែដាច់ខាតមិនឲ្យយកបាយម្ហូបចេញក្រៅទេ” ។ ដោយក្តីស្រេកឃ្លានពេក យប់នោះខ្ញុំហូបបាយជាមួយសម្លក្តៅយ៉ាងឆ្អែតហល់ ស្ទើរតែក្អួតចេញមកវិញ ប៉ុន្តែខ្ញុំមិនហ៊ានវេចខ្ចប់ទេ ទោះជាឃើញបាយម្ហូបនៅសល់ច្រើនយ៉ាងណាក៏ដោយ ។ មានអ្នកខ្លះបានលួចដុំបាយដាក់ក្នុងហោប៉ៅ ឬម្ហូរនឹងចង្កេះខោ ខ្លះខ្ចប់នឹងស្លឹកឈើយកទៅតាមខ្លួន ។

ក្រោយពេលហូបបាយរួច មេកងឲ្យអ្នកទោសដើរជាជួរតាមច្រកមួយងងឹតឈឹង ។ ទៅដល់កែងផ្លូវបត់មួយស្រាប់តែមានឈ្លបខ្មែរក្រហមជាច្រើននាក់ឈរចាំនៅទីនោះ បញ្ឆាំងពិលឆែកអ្នកទោសទាំងអស់ ។ អ្នកដែលលាក់បាយម្ហូបត្រូវបំបែកចេញឲ្យដើរផ្លូវផ្សេង ហើយអ្នកទាំងនោះក៏បាត់ខ្លួនរហូត ។ អ្នកដែលគ្មានកំហុសត្រូវឈ្លបនាំទៅភូមិរាំងឲ្យធ្វើការងារស្រាលៗ ប៉ុន្តែបបរក៏បានតិចដែរ ។ អ្នកទោសស្លាប់និងបាត់ខ្លួនជាបន្តបន្ទាប់ អ្នកដែលនៅរស់កាន់តែហោចទៅៗ ។

## ស្លាប់ឬរស់ព្រោះតែពាក្យពីរម៉ាត់

មេកងឈ្មោះ គេន ចាត់ឲ្យខ្ញុំថែទាំគោមួយក្បាលដែលស្គមយ៉ាងខ្លាំង ហើយឲ្យខ្ញុំទៅដេកតែម្នាក់ឯងនៅក្នុងរោងមួយនៅចុងភូមិ ។ គេន ដាក់កំហិតខ្ញុំថា “ច្រូតស្មៅឲ្យគោនេះស៊ីបំប៉នវាឲ្យធាត់ ។ បើគោនេះងាប់ ឯងក៏ងាប់ជាមួយគោនេះដែរ” ។ ខ្ញុំខំច្រូតស្មៅខ្ចីៗល្អៗឲ្យគោ ជួនកាលបញ្ចុកគោថែមទៀត ប៉ុន្តែយូរៗទៅគោនេះមិនស៊ីស្មៅសោះ ។ វាកាន់តែដាបទៅៗរហូតដល់ដើបឈរលែងរួច ។ ខ្ញុំគិតក្នុងចិត្តថា ខ្ញុំបានរួចពីរណ្តៅមរណៈនៅភ្នំសន្ទុង ប៉ុន្តែខ្ញុំអាចស្លាប់តាមគោនៅជ្រៃហ្វូញ្ញោនេះហើយ ។

ល្ងាចថ្ងៃបន្ទាប់ អង្គការហៅប្រមូលអ្នកទោសទាំងអស់មកជួបជុំគ្នានៅឯវាលស្រែក្បែរភូមិ ។ មេកងឲ្យមនុស្សឈរលាយឡំគ្នារាប់រយនាក់ហើយប្រកាសថា អ្នកណាចង់ទៅធ្វើការនៅការដ្ឋានខាងមុខទៅឈរតម្រៀបជួរនៅម្ខាង អ្នកណាដែលចង់ធ្វើការនៅភូមិត្រូវទៅឈរនៅម្ខាងទៀត ។ ខ្ញុំរារែក តើត្រូវទៅមុខឬនៅភូមិ ។ មួយសន្ទុះខ្ញុំសម្រេចចិត្តថាត្រូវតែទៅការដ្ឋានទោះបីធ្វើការធ្ងន់ប៉ុន្តែបានហូបគ្រាន់បើបន្តិច បើនៅភូមិបបររាវម្យ៉ាងទៀតគោដែលខ្ញុំមើលថែក៏មិនសង្ឃឹមថារស់ដែរ ។ យុវជនភាគច្រើនដែលពីមុនធ្វើការនៅការដ្ឋានមានចិត្តចង់ធ្វើការនៅភូមិវិញ ព្រោះឮថាការងារស្រាល ។ មិត្តខ្ញុំម្នាក់ឈ្មោះ ហ៊ុយ បានយកស្នុកស្លឹកត្នោតសម្រាប់ដាក់បាយមកដូរយកចានពីខ្ញុំ រួចក៏ទៅចូលជួរអ្នកនៅភូមិ ។

មេកងប្រកាសឲ្យសម្រេចចិត្តឲ្យច្បាស់លាស់ ហើយឈប់ផ្លាស់ប្តូរជួរទៀត រួចហើយក៏បញ្ជាឲ្យអ្នកស្ម័គ្រចិត្តធ្វើការនៅមុខចេញដំណើរទៅការដ្ឋាន ។ ពេលពួកខ្ញុំចេញដំណើរផុតបន្តិចឈ្លបខ្មែរក្រហមលើកកាំភ្លើងភ្ជង់អ្នកនៅភូមិហើយចងបណ្តើរជាខ្សែទៅផ្លូវផ្សេង ។ ព្រឹកស្អែកឡើង មុនពេលចេញទៅធ្វើការមេកងប្រកាសប្រាប់ពួកខ្ញុំថា “ពួកអ្នកនៅភូមិសុទ្ធតែអ្នកខ្ជិលច្រអូស ខ្លាចការងារលំបាក ឥឡូវអង្គការយកពួកវាទៅទម្លាក់ជ្រោះអស់ហើយ” ។

## ស៊ូដួលនៅការដ្ឋានឲ្យតែបានរស់

មេកងបង្ខំឲ្យយើងធ្វើការទាំងថ្ងៃទាំងយប់ ប៉ុន្តែការហូបចុកមិនគឺងតែងពេកទេ ។ នៅការដ្ឋានបានមួយខែ ខ្ញុំបាក់កម្លាំងទ្រុឌទ្រោមរហូតដួលដេកនៅកន្លែងធ្វើការ ។ មេកងបញ្ជូនខ្ញុំទៅមន្ទីរពេទ្យមួយ ដែលនៅទីនោះមានថ្នាំបន្តិចបន្តួចនិងមានរបប

ហូបផ្អែតក្នុងមួយថ្ងៃពីរពេល គឺពេលព្រឹកនិងថ្ងៃត្រង់ ឯពេលល្ងាចគ្មានទេ ។

ខ្ញុំសម្រាកនៅមន្ទីរពេទ្យបាន១០ថ្ងៃមានកម្លាំងគ្រាន់បើ ។ អង្គការបញ្ជូនខ្ញុំទៅវាយថ្មនៅសហករណ៍មួយនៅប៉ែកខាងត្បូងភ្នំ បន្ទាប់មកឲ្យខ្ញុំទៅឃ្វាលគោនៅសហករណ៍មួយផ្សេងទៀត ។

## ព្រាត់ហើយព្រាត់ទៀត

ថ្ងៃមួយ (ប្រហែលថ្ងៃទី៥ឬទី៦ខែមករា) អង្គការរៀបចំពិធី «មហាហូប» នៅគ្រប់កងគ្រប់សហករណ៍ទាំងអស់ គឺអង្គការធ្វើនំបញ្ចុកឲ្យប្រជាជនហូបផ្អែតមួយពេល ។ មិនទាន់ទាំងបានហូបផងស្រាប់តែមេខ្មែរក្រហមសំខាន់ៗរត់បាត់អស់ ប្រជាជនផ្អើលឈូឆរ ។ ខ្ញុំឃើញយន្តហោះហោះទៅមក មេកងមេក្រុមបង្ខំឲ្យប្រជាជនរត់ទៅទិសខាងលិចសំដៅព្រៃភ្នំ ។ ខ្ញុំរត់ទៅជាមួយប្រជាជនដោយដឹកគោយកទៅផង ។ ពេលទៅដល់ជើងភ្នំ ឆ្លៀតឱកាសពុំមានខ្មែរក្រហមនៅជិតខ្ញុំក៏គេចខ្លួនត្រឡប់ក្រោយវិញតម្រង់មកផ្លូវជាតិលេខ៣ (ម្តុំត្រាំខ្នារ) ។

ខ្ញុំធ្វើដំណើរកាត់សមរភូមិប្រយុទ្ធរវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម ហើយមកដល់ផ្ទះនៅឯស្រុកព្រៃកប្បាសនៅពេលព្រលប់ ដោយស្តាយស្ទុកស្ទឹកគ្មោតមួយមានអង្ករប្រហែលមួយកំប៉ុង ខោអាវរហែករយ៉ៃ ដណ្តប់ក្រណាត់មួយផ្ទាំងដែលខ្ញុំរើសបានតាមផ្លូវ ។ ឪពុកម្តាយខ្ញុំមើលខ្ញុំស្ទើរពុំស្គាល់ ។ យើងទាំងអស់គ្នាយំសស្រាក់ដោយរំភើប ។

យប់នោះ នៅក្រោមពន្លឺចង្កៀងខ្វាញ់ត្រី ដោយមានកំសៀវទឹកធ្វើឆ្នាំងបាយ ដ្តិលទឹកធ្វើចាន យើងបានហូបបាយជុំគ្នាយ៉ាងឆ្ងាញ់ជាងពេលណាៗទាំងអស់ ។ ឪពុកខ្ញុំមានប្រសាសន៍ថា «នៅបាត់តែកូនស្រី២នាក់ទៀតទេ គ្រួសារយើងនឹងបានជួបជុំគ្នាទាំងអស់វិញហើយ» ។

មិនបានមួយសប្តាហ៍ផង កងទ័ពវៀតណាមដកថយទៅវិញ កម្មាភិបាលខ្មែរក្រហមមានមេឃុំ មេភូមិ មេកងឈ្លបបានត្រឡប់មកគ្រប់គ្រងភូមិឃុំវិញហើយកាប់សម្លាប់ប្រជាជនយ៉ាងក្រពុលមុខ ។ បងប្រុសខ្ញុំត្រូវមេភូមិនិងមេកងឈ្លបចាប់ចងនៅពេលថ្ងៃត្រង់យកទៅធ្វើទារុណកម្មនិងសម្លាប់ចោល ។ យប់នោះ ឪពុកខ្ញុំនិងបងថ្លៃរបស់ខ្ញុំដែលកំពុងតែមានផ្ទៃពោះត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់នៅក្បែរភូមិយ៉ាងឃោរឃៅ ។

ខ្ញុំរស់នៅទាំងត្រដរ នឿយហត់ អស់រយៈពេល១៣០០ថ្ងៃនិង១៣០០យប់ ដោយគ្មានស្បែកជើងពាក់ មិនដែលមានខោអាវលើសពី១សម្រាប់ជាប់ខ្លួន មិនដែលឃើញមុខខ្លួនឯងដូចម្តេចព្រោះគ្មានកញ្ចក់ឆ្លុះ មិនដែលមានសាប៊ូប្រើសូម្បីតែម្តង ។ ជិតបួនឆ្នាំ (បីឆ្នាំប្រាំបួនខែ) រស់នៅក្រោមរបបដឹកនាំបិសាចអាវខ្មៅគឺមានតែការស្រេកឃ្លាន ទុក្ខព្រួយ តក់ស្លុត រន្ធត់ ឈឺចាប់ខ្លោចផ្សា លំបាកវេទនាទាំងផ្លូវកាយផ្លូវចិត្ត ។ ជីវិតខ្ញុំនៅក្នុងរបបខ្មែរក្រហមគឺ «ពេលព្រលឹមដឹងថាខ្លួនខ្ញុំបានរស់មួយយប់ ដល់ពេលព្រលប់ដឹងថាបានរស់មួយថ្ងៃ» ។

**ស៊ឹម សុទ្ធ ហៅ កុយ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ ម៉ោង៧ៈ៣០-៧ៈ៤៥ ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **លី សុផល**

# សេចក្ដីប្រកាសរកប្អូនប្រុសឈ្មោះ ឡាំ សំអ៊ិន


ឡាំ យឿន
មុនឆ្នាំ១៩៧៥

នាងខ្ញុំឈ្មោះ ឡាំ យឺន អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិឡទឹកត្រី ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុនរបបកម្ពុជាប្រជាធិបតេយ្យរស់នៅភូមិក្រងផ្ដិល ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ នាងខ្ញុំសូមសួររកប្អូនប្រុសឈ្មោះ ឡាំ សំអ៊ិន ដែលបានបែកគ្នាក្នុងពេលខ្មែរក្រហមជម្លៀស ពីប្រឡាយមាសទៅស្រុកកំពង់លែង ។ មុនរបបកម្ពុជាប្រជាធិបតេយ្យ ប្អូនបួសជាសង្ឃនៅវត្តប្រឡាយមាសក្នុងស្រុកកំណើតបានបីវស្សា បន្ទាប់មកលាចាកសិក្ខាបទនៅឆ្នាំ១៩៧៥ក្នុងអាយុ២១ឆ្នាំ ។

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ខ្ញុំបានទទួលដំណឹងពីឈ្មោះ ឆឹង កូន និង លោកពូស៊ុន នៅក្នុងភូមិជាមួយគ្នាថាគាត់បានជួប សំអ៊ិន នៅសំឡូតខេត្តបាត់ដំបង ហើយបានបបួល សំអ៊ិន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ សំអ៊ិន ប្រកែកថាមិនហ៊ានមកទេខ្លាចខ្មែរក្រហមឃើញតាមផ្លូវសម្លាប់ចោល ។ ខ្ញុំថែមទាំងដឹងទៀតថា ប្អូនបានប្តូរឈ្មោះពី ឡាំ សំអ៊ិន ទៅជា អ៊ិន កំសត់ ។ បើប្អូន ឡាំ សំអ៊ិន បានឃើញសេចក្ដីប្រកាសនេះ ឬញាតិមិត្តណាបានដឹងដំណឹងអំពី ឡាំ សំអ៊ិន ឬ (អ៊ិន កំសត់) សូមមេត្តាផ្ដល់ដំណឹងមកនាងខ្ញុំនៅភូមិឃុំខាងលើ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារលេខ ០២៣ ២១០ ៣៥៨ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្ដីប្រកាសរកក្មួយប្រុសឈ្មោះ វ៉ាង

នាងខ្ញុំឈ្មោះ ឆេម អាយុ៨៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិថ្មី ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង សូមសួររកក្មួយប្រុសឈ្មោះ វ៉ាង ដែលបែកគ្នានៅព្រៃប្រតូច ពេលដែលខ្មែរក្រហមជម្លៀសចេញពីជ្រោយគោ ។ បើក្មួយបានទទួលដំណឹងនេះសូមទាក់ទងមីងតាមអាសយដ្ឋានខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ។ សូមអរគុណ ។

# សេចក្ដីប្រកាសរកក្មួយឈ្មោះ អាគុយ

នាងខ្ញុំឈ្មោះ សំ ស៊ីម អាយុ៨៨ឆ្នាំ រស់នៅភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង សូមសួររកក្មួយប្រុសឈ្មោះហៅក្រៅ អាគុយ ដែលបានបែកគ្នានៅម្តុំគោមកាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ពេលដែលខ្មែរក្រហមជម្លៀសចេញពីភូមិប៉ាតឡាង ។ បើក្មួយបានទទួលដំណឹងនេះសូមមកជួបមីងតាមអាសយដ្ឋានខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្ដីប្រកាសរកបងប្រុសឈ្មោះ សុផា

នាងខ្ញុំឈ្មោះ នង ស៊ីម អាយុ៣៨ឆ្នាំ រស់នៅភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង សូមសួររកប្អូនប្រុសឈ្មោះ សុផា ដែលបែកគ្នាពេលខ្មែរក្រហមជម្លៀសចេញពីភូមិ ។ បើប្អូនប្រុសបានទទួលដំណឹងនេះសូមមករកបងតាមអាសយដ្ឋានខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិបានសម្រេចយកបញ្ញាការដ្ឋានកងទ័ពជើងគោកដែលទើបនឹងសាងសង់ថ្មី នៅឯជាយក្រុងភ្នំពេញធ្វើជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

DC-Cam Main Office: #66, Preah Sihanouk Blvd, Tonle Basac, Chamkar Morn, Phnom Penh, Cambodia. Tel: (855) 23 211 875, Fax: (855) 23 210 358, Email:dccam@online.com.kh, Homepage: www.dccam.org.